ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- នួន ជា
- ឧក្រិដ្ឋកម្មសង្គ្រាម

[illegible]

លេខ១ ខែមករា ឆ្នាំ២០០០

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៣ ខែមីនា ឆ្នាំ២០០០


## មាតិកា


-សំបុត្រៈ ការដាក់ឲ្យទទួលខុសត្រូវ.................................. ១

**ផ្នែកឯកសារ**

-ជនជាតិចាមរងគ្រោះក្រោមការឃោសនារបស់ខ្មែរក្រហម....... ២

-អ្នកបកប្រែភាសាចិន ឡុង មុយ.................................. ៤

-ភូមិចន្រ្ទាធ្លាក់ក្នុងវិនាសសកម្មសង្រ្គាម.............................. ៩

-ជនជាតិភាគតិច «ភ្នង» និងឧក្រិដ្ឋកម្ម.............................. ១២

-ម៉ៅជឿន ហៅ លី ត្រូវធ្វើទារុណកម្មបង្ខំឲ្យឆ្លើយ.............. ១៤

-នួន ជា ................................................................ ១៩

**ផ្នែកប្រវត្តិសាស្ត្រ**

-មន្ទីរ ស-២១........................................................ ២១

-គ្រោះថ្នាក់នៃអព្យាក្រឹតភាព........................................ ២៥

**ផ្នែកច្បាប់**

-ច្បាប់សង្រ្គាម........................................................ ២៩

-ឧក្រិដ្ឋកម្មសង្រ្គាម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា..... ៣៣

-វិធានស្ដីអំពីភ័ស្ដុតាង.................................................. ៣៨

-គំរូមួយនៃភ័ស្ដុតាងឯកសារ.......................................... ៤២

**វេទិកាពិភាក្សាជាសាធារណៈ**

-ការវិវត្តន៍ថ្មីៗជុំវិញច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម......... ៤៦

-ការយល់ដឹងរបស់ខ្ញុំចំពោះខ្មែរក្រហម.................................. ៥១

-ព្រឹត្តិការណ៍ដ៏សំខាន់អំពីប្រទេសឈីលី.............................. ៥៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

-គ្រួសាររបស់ខ្ញុំក្រោមរបប ប៉ុល ពត............................ ៥៥

**លិខិតមិត្តអ្នកអាន**

-លិខិតពីខេត្តក្រចេះ.................................................... ៦០

**សិល្បៈខ្មែរក្រហម (ចម្រៀង)**

-អគ្គការបដិវត្តន៍ជាដួងព្រលឹងនៃប្រជាជនកម្ពុជា................គ្របក្រោយ




**រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា**
**និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង**


# រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងពត៌មាននៃរដ្ឋាភិបាលកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន

លេខ ០២៩១ពម.៩៩ ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩








**វាគ្មិនលេខនេះៈ** អេលីហ្សាបែត វ៉ាន់ស្កាក់, រីដ ប្រដឌី, សាស្ត្រាចារ្យ ដេវីត ឆេនដល័រ, រេមិន ចូហាន់សិន, ពៅ ដាស៊ីល, យែនតុន ក្លែមម័រ, ចន ឆីឆរអារី, សាស្ត្រាចារ្យ ស៊ីវ ហេឌ័រ,ពៅ ដារ៉ា **អ្នកនិពន្ធនិងស្រាវជ្រាវៈ** សាន់ កល្យាណ, លី សុជល, ដួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** អែម សុឃីម **និពន្ធនាយករងទី១ៈ** ដាត កុសល **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** សួរ ប៊ុនស៊ូ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ីម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ទ្រី សុភក្តិ

## សំបុត្រ:

# ការដាក់ឱ្យទទួលខុសត្រូវនៅចំពោះមុខច្បាប់

អ្នកជំនាញច្បាប់ជាតិ និងអន្តរជាតិ ដែលបានត្រួតពិនិត្យករណីខ្មែរក្រហមបានធ្វើការសន្និដ្ឋានថា មេដឹកនាំខ្មែរក្រហមមុខជានឹងត្រូវបានយកមកធ្វើការជំនុំជម្រះក្ដីតាមច្បាប់អំពីបទឧក្រិដ្ឋមួយចំនួនដែលបានប៉ះពាល់ដល់ជីវិតមនុស្សជាង១លាននាក់ នៅក្រោមការកាន់អំណាចរបស់ខ្លួនរវាងឆ្នាំ១៩៧៥-១៩៧៩ ។ លទ្ធផលស្រាវជ្រាវដ៏សំខាន់មួយក្នុងចំណោមលទ្ធផលសំខាន់ៗទាំងអស់ គឺការបំភ្លឺនូវអ្វីដែលជាអាថ៌កំបាំងនៃខ្សែសង្វាក់ដឹកនាំដែលតាមរយៈនោះរបបខ្មែរក្រហមបានកាប់សម្លាប់មនុស្សអស់រាប់លាននាក់ ។ ជារបាយការណ៍សង្ខេបមេដឹកនាំខ្មែរក្រហមបានបង្កើតបណ្ដាញសម្លាប់មនុស្សទូទាំងប្រទេស ។ តាមរយៈបណ្ដាញនេះ ពួកមេដឹកនាំខ្មែរក្រហមបានផ្ដាច់ជីវិតមនុស្សទាំងសត្រូវពិតប្រាកដ និងមនុស្សដែលពួកខ្លួន«ស្រមើស្រមៃ»ថាជា «សត្រូវបក្សកុម្មុយនិស្ត» ក្នុងកម្រិតជាមធ្យម ៥២០០នាក់ ក្នុងមួយសប្ដាហ៍ជាបន្តឥតដាច់ក្នុងរយៈពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ។ ប្រជាជនប្រហែល១លាននាក់ទៀតស្លាប់ដោយការមិនយកចិត្តទុកដាក់របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ តាមរយៈការបង្អត់អាហារ ជំងឺនិងការបង្ខំឲ្យធ្វើការបាក់កម្លាំង ។ ភស្តុតាងឯកសារការិយាធិបតេយ្យនៃរបបខ្មែរក្រហមបានចង្អុលបង្ហាញច្បាស់ថា មេដឹកនាំខ្មែរក្រហមទាំងអស់មានការពាក់ព័ន្ធទៅនឹងមហាឧក្រិដ្ឋកម្មជាប្រវត្តិសាស្ត្រនេះ ។ ក៏ប៉ុន្តែជាង២០ឆ្នាំ បន្ទាប់ពីរបបនេះត្រូវបានផ្ដួលរំលំពីអំណាច មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ទាំងមូលបន្តទទួលភាពរួចទោសចំពោះតួនាទីរបស់ពួកខ្លួននៅក្នុងអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ មានមូលហេតុជាច្រើនដែលធ្វើឲ្យភាពរួចទោសពុំអាចគាស់រំលើង ឬបំបែកបាន ។ ក៏ប៉ុន្តែការដែលមិនថាពុំមានការពុះពារប្រឹងប្រែងដើម្បីនាំយកជនជាប់ចោទមកកាត់ទោសពុំមែនជារឿងត្រឹមត្រូវឡើយ ។ លទ្ធផលដ៏សំខាន់បំផុតមួយដែលចេញមកពីតុលាការឯករាជ្យមួយលើរឿងក្ដីរបបប្រល័យពូជសាសន៍សម្រាប់ប្រទេសកម្ពុជា គឺឥទ្ធិពលរបស់តុលាការនេះមកលើ «វប្បធម៌នៃភាពរួចទោស»នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ អស់រយៈពេលប្រមាណ៣ទសវត្សរ៍កន្លងមកនេះ បុគ្គលិករាជការកម្ពុជាជាច្រើនរួមទាំងអ្នកនយោបាយ ប៉ូលិស ទាហាន ហើយជាពិសេសប្រជាជនកម្ពុជា ធម្មតាបានរស់នៅក្នុងបរិយាកាសមួយដែលយាយីក្នុងជីវិតដោយភាពរួចទោសយ៉ាងអយុត្តិធម៌ ។ អ្នកខ្លាំងយកអ្វីដែលខ្លួនអាចយកបាន រីឯអ្នកខ្សោយវិញទទួលរងនូវអ្វីដែលខ្លួនត្រូវទទួលរងហើយពុំមាននរណាម្នាក់សង្ឃឹមថា «ច្បាប់» នឹងចូលមកធ្វើអន្តរាគមន៍ដើម្បីកែលម្អស្ថានភាពនេះឡើយ ។ ការដាក់ទណ្ឌកម្មលើមេដឹកនាំខ្មែរក្រហម គឺជាវិធីមួយដ៏មានប្រសិទ្ធិភាពបំផុតដែលកម្ពុជាអាចចាប់ផ្ដើមធ្វើឲ្យវប្បធម៌នៃភាពរួចទោសអាចសឹករេចរឹលទៅបាន ហើយកសាងកម្ពុជាដោយផ្អែកលើច្បាប់ ។ យើងអាចធ្វើដូច្នេះបានយ៉ាងសក្ដិសិទ្ធដោយអនុញ្ញាតឲ្យសហគមអន្តរជាតិចូលរួមក្នុងដំណើរការជំនុំជម្រះក្ដីមេដឹកនាំខ្មែរក្រហមដោយស្មើភាពគ្នា ។



**ឆាំង យុ**

# ជនជាតិចាមរងគ្រោះក្រោមការឃោសនារបស់ខ្មែរក្រហម

«***មានការដូរជនជាតិចាមជាមួយប្រេងរបស់ប្រទេសជាមិត្ត***» នេះគឺជាល្បិចនយោបាយពិសេសរបស់ខ្មែរក្រហមក្នុងការធ្វើឲ្យជនជាតិចាមបង្ហាញមុខនិងងាយស្រួលប្រមូលផ្តុំដើម្បីជម្លៀសចាប់ទោសកំហុសនិងសម្លាប់ចោល ។

ពាក់ព័ន្ធទៅនឹងនយោបាយជម្លៀសប្រជាជនចាមមិនថានៅទីក្រុងឬនៅតាមជនបទឡើយសុទ្ធតែត្រូវបានជម្លៀសចេញពីភូមិកំណើតនិងបំបែកជាក្រុមតូចៗឲ្យរស់នៅលាយឡំជាមួយប្រជាជនខ្មែរ ។

ខុកញ៉ា សុះ កំរី ប្រធានគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជាបានឲ្យដឹងថាដើមហេតុដំបូងនៃការជម្លៀសជនជាតិចាម គឺបណ្តាលមកពីបាតុភាពនៃការបះបោរប្រឆាំងនឹងខ្មែរក្រហមនៅភូមិ «ស្វាយឃ្លាំងនិងកោះផល» ខេត្តកំពង់ចាម ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ។ លោកខុញ៉ា កំរី បានមានប្រសាសន៍ថា «ក្រោយពីមានការបះបោរនៅកោះផលនិង ស្វាយឃ្លាំង រួចមកការនិទានប្រាប់ និងការបំភ័យប្រជាជនចាម ទូទាំងប្រទេសក៏កើតមានឡើង ហើយលើកឧទាហរណ៍គំរាមនិងបង្ក្រាបចលនាបះបោរដោយនិយាយថា **ប្រយ័ត្នដូចកោះផល ដែលក្លាយជាកោះផេះនោះ**» ។

ដើម្បីដោះស្រាយឲ្យមានការធូរស្រាល បន្ទាប់ពីមានការបះបោររួច បងប៉ុល (ប៉ុល ពត) បានបញ្ជាឲ្យជម្លៀសជនជាតិចាមចេញពីភូមិភាគបូព៌ាឲ្យទៅនៅភូមិភាគឧត្តរ ប៉ុន្តែភាគឧត្តរមិនព្រមទទួលយកជនជាតិចាមទេ ។ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ សមមិត្តឆុន បានផ្ញើទូរសារលេខ១៥ទៅឲ្យ បងប៉ុល (ប៉ុល ពត) ដែលមានចម្លងជូន នួន ជា មានសេចក្តីថា ខាងស្រុកស្ទឹងត្រង់ និងព្រែកប្រសព្វស្ថិតនៅក្នុងភូមិភាគឧត្តរមិនព្រមទទួលយកជនជាតិចាមពីស្រុកឆ្លូង ឃុំពាមជីលាំង និងស្រុកក្រូចឆ្មារទេ «ដាច់ខាតមិនព្រមទទួលយកប្រជាជនឥស្លាមទេ យកតែខ្មែរសុទ្ធ» ។ ឆុន ក៏បានឲ្យយោបល់ប្រាប់ទៅប៉ុលវិញថា «ពាយ័ព្យ និងឧត្តរត្រូវទទួល ដើម្បីបំបែកប្រជាជនឥស្លាមចេញពីដងទន្លេមេគង្គឲ្យបរិយាកាសធូរស្រាលខ្លះ»... ដកនេះជាគោលការណ៍ដូចបងបានពិភាក្សាជាមួយខ្ញុំរួចជាស្រេចហើយ ...ជាគោលការណ៍ខាងភូមិភាគដកប្រជាជនចំនួន៥ម៉ឺននាក់ប្រគល់ឲ្យឧត្តរ ។ ដូច្នេះប្រជាជនឥស្លាមនៅសល់ក្នុងភូមិភាគបូព៌ាជាង១សែននាក់ទៀត ។ យើងដកតែចំណុចសំខាន់ៗតាមដងទន្លេ និងព្រំដែន ឯខាងស្រុកត្បូងឃ្មុំមិនដកទេ» ។ ទូរលេខនេះបញ្ជាក់ថា ប្រជាជនចាមដែលបានជម្លៀសទៅដល់ស្រុកស្ទឹងត្រង់និងព្រែកប្រសព្វ ហើយនៅរង់ចាំមតិរបស់បងប៉ុល និងភូមិភាគឧត្តរដើម្បីដោះស្រាយ ។ វាសនានៃជនជាតិចាមដែលត្រូវជម្លៀសហើយមិនបានទទួលយកនោះស្ថិតនៅក្នុងការស្រាវជ្រាវនៅឡើយទេ ។

ភាគច្រើននៃការជម្លៀសនោះទៀតសោត ខ្មែរក្រហមបានប្រើល្បិចកលបោកបញ្ឆោតតាមការបំផុសពាក្យចចាមអារ៉ាមមួយថាប្រជាជនចាមនឹងត្រូវឲ្យចេញទៅរស់នៅ ប្រទេសឥស្លាម ដូចជា ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងអារ៉ាប់ ដោយឲ្យប្រទេសទាំងនោះនាំយកប្រេងមកឲ្យកម្ពុជាវិញដើម្បីជាថ្នូរ ។ ប្រជាជនចាមជាច្រើនភូមិសុទ្ធតែបានឮពត៌មាននេះស្ទើរគ្រប់ៗគ្នា ។ លោក ម៉ាត់ ទូល័ស នៅភូមិចាមលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល បាននិយាយថា «ដំបូងឡើយគឺ ឮតាមអ្នកធ្វើការជាមួយពួក ប៉ុល ពត នោះ ហើយដល់ក្រោយមកគេចោទថាលេចឮតាមប្រជាជនគ្នាឯងទៅវិញ ។ តាមការពិត អស់លោកនោះហើយជាអ្នកនិយាយចេញតៗគ្នាទៅដល់ពេលចេញខ្លាំងឮគ្រប់ៗគ្នាគេថាមិនមែនគេវិញគេថាប្រជាជននេះចង់បះបោរ» ។

តាមរយៈពត៌មានចចាមអារ៉ាមនេះ ពួកខ្មែរក្រហមបានទទួលជោគជ័យមួយផ្នែកធំក្នុងការជម្លៀសប្រជាជនចាមទូទាំងប្រទេស ពីព្រោះស្ថិតក្នុងស្ថានភាពតឹងតែងជនជាតិចាមគ្រប់រូបរមែងចង់រស់នៅទីកន្លែងមួយដែលអាចផ្តល់សេចក្តីសុខសាន្តសម្រាប់ខ្លួន ។ ឆ្លៀតឱកាសនេះហើយខ្មែរក្រហមបានធ្វើការកត់ឈ្មោះប្រជាជនក្នុងភូមិ ហើយបែងចែកជាក្រុមតូចៗរួចបញ្ជូនទៅតាមវគ្គមានមុននិងក្រោយដោយប្រាប់ថាអ្នកដែលមានឈ្មោះ

ក្នុងបញ្ជីនោះនឹងត្រូវបញ្ជូនទៅបរទេស ។

អ្នកស្រី ម៉ាត់ សាតាស់ អ្នកភូមិពោធិព្រះឥន្ទ ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម បានឲ្យដឹងថាអង្គការបានចុះឈ្មោះគ្រួសារគាត់ក្នុងបញ្ជីជម្លៀសលើកដំបូងក្នុង ខែតុលា ឆ្នាំ១៩៧៥ ។ ពេលព្រឹកព្រលឹមនាថ្ងៃមួយ គ្រួសារគាត់និងអ្នកភូមិចំនួន៣៨គ្រួសារត្រូវបានដឹកតាមរថយន្តធំទៅឈប់នៅស្រុកឆ្លូងខេត្តក្រចេះ ។ អ្នកស្រី សាតាស់ បានមានប្រសាសន៍ថាៈ

«យើងទាំងអស់គ្នាសប្បាយចិត្តណាស់ ដោយកម្មាភិបាលខ្មែរក្រហមប្រាប់ឲ្យឡើងកាណូតជាបន្តទៀតដើម្បីទៅភ្នំពេញនឹងបានជិះយន្តហោះទៅប្រទេសក្រៅ ។ វាហាក់ដូចជាការពិតព្រោះកាណូតទាំងអស់បែរមុខសំដៅទៅទិសខាងភ្នំពេញ ប៉ុន្តែពេលកាណូតចេញឆ្ងាយពីច្រាំងត្រូវបត់ក្បាលទៅទិសផ្សេងវិញ ។ ទីបំផុតខ្ញុំត្រូវបានគេបញ្ជូនឲ្យទៅរស់នៅក្នុងព្រៃភ្នំក្នុងទឹកដីខេត្តក្រចេះ» ។

ចំណែកឯភូមិចាមចំនួនបួន គឺភូមិចាមលើ ភូមិចាមក្រោម ភូមិពោធិទន្លេ និងភូមិទួលសង្កែ ក្នុងស្រុកកោះធំ ខេត្តកណ្តាល បានរំដើបរំជួលតាមរយៈពាក្យចចាមអារ៉ាមនេះ ហើយម្នាក់ៗនឹកសង្ឃឹមក្នុងចិត្តថាខ្លួនជិតបានឆ្លងផុតពីការកៀបសង្កត់សាសនា និងទុក្ខសោកទាំងឡាយ ព្រោះជិតបានទៅប្រទេសក្រៅ ។

លោក ម៉ាត់ ទូល័ស បានមានប្រសាសន៍បន្ថែមទៀតថា «គ្រប់ៗគ្នាទាំងអស់ក៏នាំគ្នាផ្ញើសម្ភារទ្រព្យ... 

ព្រឹត្តិការណ៍គួរឲ្យខ្លោចផ្សាមួយទៀត បានកើតឡើងនៅភូមិសាច់សូរ (តាស៊ូ) ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម ។ លោក ស្រេង មូហាំម៉ាត់ និយាយថា «ពួក ប៉ុល ពត បានប្រកាសថា ជនជាតិចាមត្រូវប្តូរជាមួយប្រេងប្រទេសអារ៉ាប់ ។ ប្រជាជនចាមបានឡើងពេញកប៉ាល់ បន្ទាប់មកកប៉ាល់បានចេញឆ្ងាយពីច្រាំងរួចប្រានទម្លាក់ក្នុងទឹកទន្លេមេគង្គ ។ ប្រជាជនចាមប្រមាណជា១០០០នាក់ ត្រូវបានស្លាប់ក្នុងពេលនោះនាដើមឆ្នាំ១៩៧៦» ។

លោក អ៊ីប្រាហ៊ីម ជាអ្នកនេសាទត្រីឲ្យសហករណ៍នៅស្ទឹងត្រង់ក្នុងខេត្តកំពង់ចាម ក៏បានដឹងអំពីរឿងរ៉ាវសម្លាប់ ដូចគ្នានេះដែរ កើតមាននៅស្ទឹងត្រង់ ។ នៅដើមឆ្នាំ១៩៧៧មានជនជាតិចាមជាច្រើនមកពីស្រុកក្រូចឆ្មារ និងក្នុងស្រុកស្ទឹងត្រង់មកជុំគ្នានៅឯស្ទឹងត្រង់ក្នុងបំណងចេញទៅប្រទេសម៉ាឡេស៊ី ពីព្រោះពួកគេបានឮថា ម៉ាឡេស៊ីបានយកប្រេងមកដូរយកជនជាតិចាម ។ ប៉ុន្តែប្រជាជនចាមទាំងនោះត្រូវបានដឹកចេញពីទីនោះដោយរថយន្ត ។ អ៊ីប្រាហ៊ីម បញ្ជាក់ថា «គ្មានអ្នកណាម្នាក់បានរស់ទេក្នុងចំណោមជនជាតិទាំងនោះ ពីរថ្ងៃក្រោយពីដឹកចេញទៅឃើញខោអាវនិងក្រមារបស់អ្នកទាំងនោះត្រូវបានយកមកចែកឲ្យក្មេងៗក្នុងភូមិ» ។

ពាក្យចចាមអារ៉ាមនេះហើយ គឺជាគន្លឹះសំខាន់មួយក្នុងចំណោមល្បិចកលផ្សេងៗទៀតរបស់ខ្មែរក្រហមក្នុងការសម្រេចតាមទិសដៅជម្លៀស ការចាប់យកទោសកំហុសនិងការសម្លាប់ប្រជាជនចាមទូទាំងប្រទេសកម្ពុជា ។

តាមចម្លើយសារភាពរបស់អ្នកទោសគុកទួលស្លែងម្នាក់ ឈ្មោះ ចិក ប្រាហ៊ីម លេខ D០២៦៨៧ តម្កល់ទុកនៅបណ្ណាសារដ្ឋាននៃមជ្ឈមណ្ឌលឯកសារកម្ពុជា យើងខ្ញុំបានដឹងពីប្រភពដំបូងដែលនាំឲ្យពាក់ព័ន្ធទៅនឹងពាក្យចចាមអារ៉ាមនេះ ។

នៅមុនថ្ងៃ១៧ មេសា ១៩៧៥ មានឧត្តមសេនីយ៍ត្រីម្នាក់ជាជនជាតិចាមធ្វើការឲ្យរបបសាធារណរដ្ឋខ្មែរឈ្មោះ «ឡេស កសឹម» ។ ឧត្តមសេនីយ៍ កសឹម បានប្រកាសយ៉ាងទូលំទូលាយ... 

«បើរបបសាធារណរដ្ឋខ្មែរចាញ់សង្គ្រាមមែននោះ ខ្លួនក៏មានភារកិច្ចទាក់ទងជាមួយប្រទេសម៉ាឡេស៊ី ដើម្បីសុំជំនួយប្រទេសនេះជាកប៉ាល់ទឹកយកមកដឹកជញ្ជូនបងប្អូនខ្មែរឥស្លាមឲ្យចេញផុតអស់ពីស្រុកខ្មែរ» ។

ស្របតាមសំដីរបស់ ឡេស កសឹម និងទឹកចិត្តរបស់ជនជាតិចាមដែលប្រាថ្នាចង់រស់នៅក្នុងសង្គមមួយដែលមានការអធ្យាស្រ័យក្នុងការរស់នៅជួបជុំគ្នា ការប្រតិបត្តិសាសនានិងរក្សាប្រពៃណីទំនៀមទម្លាប់ខ្លួនទើបខ្មែរក្រហមបានឆក់យកឱកាសនេះ ដើម្បីបម្រើនយោបាយក្នុងការជម្លៀសការធ្វើទារុណកម្មនិងការសម្លាប់រង្គាលទៅវិញ ។ **អ៊ីសា ឧស្មាន**

# អ្នកបកប្រែភាសាចិន ឡុង មុយ

## ត្រូវបានខ្មែរក្រហមចោទថាជាជនក្បត់បដិវត្តន៍-រួចយកទៅសម្លាប់ចោល

តាមប្រភពឯកសារចម្លើយសារភាព (ឯកសារលេខ J០០៦៣៦) តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៧៧ ឡុង មុយ ជាប្រធានក្រុមបកប្រែភាសាចិន នៅមន្ទីរក-១៦ ។ ខ្មែរក្រហមចោទ ឡុង មុយ ថាជាជនក្បត់បដិវត្តន៍ ដោយបានបំរើឲ្យបក្សកុកម៉េងតាំងជាបក្សនយោបាយមួយដែលមាននិន្នាការប្រឆាំងនឹងបក្សកុម្មុយនិស្តចិនទើបចាប់ឃុំខ្លួននៅមន្ទីរស-២១ ។ បក្សកុកម៉េងតាំងនេះបានកកើតឡើងនៅក្នុងប្រទេសកម្ពុជា តាមរយៈចលនាតស៊ូរបស់ពួកអាណិកជនចិនរស់នៅស្រុកពារាំង ខេត្តព្រៃវែង ហើយបានធ្វើសកម្មភាពនៅអំឡុងឆ្នាំ១៩៥៧ ។ តាមរយៈចម្លើយរបស់ ឡុង មុយ បក្សកុកម៉េងតាំងបានបង្កើតឡើងក្នុងគោលបំណងដើម្បីលើកកម្ពស់ឥទ្ធិពលរបស់បក្សខ្លួន និងឆ្លៀតយកឱកាសក្តាប់តួនាទីដឹកនាំក្នុងចលនាអាណិកជនចិន ។

តាមចម្លើយសារភាពរបស់ឈ្មោះ ឡុង មុយ ខាងលើនេះបានឲ្យដឹងទៀតថានៅក្នុងស្រុកពារាំង ខេត្តព្រៃវែងគឺជាកន្លែងមួយដែលមានអាណិកជនចិនរស់នៅច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា ។

ផែនការប្រឆាំងនឹងបដិវត្តន៍ខ្មែរក្រហមមុនឆ្នាំ១៩៧០ របស់បក្សកុកម៉េងតាំងត្រូវបានដឹកនាដោយ តែ ហេងគ្រី ហៅ លី ជៀល ជាមេដឹកនាំចលនាបក្សកុកម៉េងតាំងនៅស្រុកពារាំង ខេត្តព្រៃវែង ។

នៅឆ្នាំ១៩៥៧ ក្រុមបក្សកុកម៉េងតាំងបានជួបជុំគ្នានៅសាលាចិនមួយកន្លែងនៅស្រុកពារាំង ខេត្តព្រៃវែង ដែលមានឈ្មោះ លី ជៀល ជាប្រធានអង្គប្រជុំ និងឈ្មោះ អុងប៉ាងលៀន ជាលេខាធិការអង្គប្រជុំ ។ អង្គប្រជុំបានសម្រេចថា «នៅក្នុងសាលាចិនត្រូវជ្រើសយកគ្រូណាដែលមានជំហរបក្សកុកម៉េងតាំងមកបង្រៀនសៀវភៅ ត្រូវយកសៀវភៅដែលបោះពុម្ពនៅតៃវ៉ាន់ និងនៅសាំងហ្គាពួរ យកមកបង្រៀនដែរ ក្រៅពីនេះមិនយកទេ ហើយនៅកន្លែងទីចាត់ការ និងតាមបន្ទប់រៀនត្រូវដាក់រូបថតរបស់ ជៀង កៃជៀក (ជាមេដឹកនាំបក្សកុកម៉េងតាំងប្រឆាំងលទ្ធិកុម្មុយនិស្តនៅប្រទេសចិន) និងទង់ជាតិបក្សកុកម៉េងតាំងនៅចំកណ្តាលលើជញ្ជាំង ហើយគូររូបសញ្ញាទង់ជាតិរបស់បក្សកុកម៉េងតាំង (ផ្កាយ១២ជ្រុង) មួយយ៉ាងធំ ដើម្បីសំដែងការស្មោះត្រង់របស់គេម្នាក់ៗចំពោះបក្សកុកម៉េងតាំង និងជៀងកៃសៀក» ។

យោងតាមសំដីរបស់ឈ្មោះ លី ជៀល ក្នុងចម្លើយសារភាពរបស់ឈ្មោះ ឡុង មុយ បាននិយាយឲ្យដឹងថា «យើងរៀនដើម្បីអ្វីត្រូវឲ្យច្បាស់លាស់ គឺយើងរៀនដើម្បីបម្រើឲ្យឧត្តមគតិរបស់យើង គឺសេរីភាពប្រជាធិបតេយ្យ ឯបក្សកុម្មុយនិស្តគឺផ្តាច់ការអត់សេរីភាព ខ្ញុំធ្លាប់រស់នៅប្រទេសចិន ខ្ញុំដឹងច្បាស់ណាស់ពួកចោរកុម្មុយនិស្តចិនធ្វើបាបប្រជាជន មិនឲ្យប្រជាជនមានពេលទំនេរដើម្បីសម្រាក និងកំសាន្តទេ ដូច្នេះយើងត្រូវតែប្រឆាំងនឹងបក្សកុម្មុយនិស្តដាច់ខាត» ។

ក្រោយឆ្នាំ១៩៧០របស់បក្សកុកម៉េងតាំងរយៈកាលប្រាំឆ្នាំ (១៩៧០-១៩៧៥) មេដឹកនាំបក្សកុកម៉េងតាំងនៅស្រុកពារាំង ខេត្តព្រៃវែង បានធ្វើសកម្មភាពដូចជាកសាងកម្លាំងតាមរយៈប្រជាជន និងតាមរយៈយុវសិស្ស នៅឃុំស្វាយពល់ ស្រុកពារាំង ខេត្តព្រៃវែង ។ ផែនការរបស់បក្សកុកម៉េងតាំងនេះមានដូចជាវាយប្រហារខាងនយោបាយ, ប្រឆាំងខាងសេដ្ឋកិច្ច និងប្រឆាំងខាងយោធា និងសុខាភិបាល ។

ដើម្បីសម្រេចផែនការខាងលើនេះក្រុមដឹកនាំបក្សកុកម៉េងតាំង បានពិភាក្សាគ្នាជារៀងរាល់ខែ និងធ្វើការកែប្រែតាមគោលការណ៍ជាក់ស្តែង ។ ចាប់តាំងពីឆ្នាំ១៩៧១មក យុវជនម្នាក់ៗរបស់បក្សកុកម៉េងតាំងត្រូវដឹកស្បៀង និងសត្វពាហនៈចេញទៅតំបន់ពួកក្បត់ឲ្យបានម្តងក្នុងមួយខែ ។ នៅខែមករា ឆ្នាំ ១៩៧២ ពេលនោះសមរភូមិប្រយុទ្ធរបស់ខ្មែរក្រហមត្រូវការ

បាយកញ្ចប់ពីប្រជាជនមេដឹកនាំបក្សកុកម៉េងតាំង បានណែនាំសមាជិករបស់ខ្លួនទាំងអស់ឲ្យខ្ចប់តែបាយ ដោយឥតដាក់ម្ហូប ហើយបាយកុំដាក់ច្រើនពេក ក្នុងបាយត្រូវដាក់ដែកគោលនិងមែកឈើ ឬដីខ្សាច់ ។ ក្រោយមកអង្គការខ្មែរក្រហមក៏បានស្នើអង្ករនិងស្បៀងក្រៀមក្រោះវិញ ។ ពេលនោះមេដឹកនាំបក្សកុកម៉េងតាំងក៏បានណែនាំសមាជិករបស់ខ្លួនម្តងទៀតឲ្យដាក់ខ្សាច់ ឬគ្រួសនៅក្នុងអង្ករហើយត្រូវត្រៀមអង្ករដែលសម្រាប់ទុកឧបត្ថម្ភនោះដោយឡែកនិងមិនចាំបាច់វែងឲ្យអស់ស្រូវទេ ។ វិធានការនេះចាប់ផ្តើមអនុវត្តចាប់តាំងពីខែធ្នូ ឆ្នាំ១៩៧២ រហូតមក ។

លុះមកដល់ខែកុម្ភៈ ឆ្នាំ១៩៧៣ មេដឹកនាំបក្សកុកម៉េងតាំង នៅស្រុកពារាំង ខេត្តព្រៃវែង បានប្រមូលគ្នាប្រជុំដោយលើកឡើងថា «អញ្ជើញបងប្អូនមកប្រជុំក្នុងថ្ងៃនេះ សំខាន់ចង់លើកផែនការមួយ គឺឥឡូវប្រជាជនច្រូតស្រូវជិតអស់ហើយ ដូច្នេះបងប្អូនណាដែលមានលុយអាចទិញទុកបាន សូមទិញទុកឲ្យបានច្រើន ហើយឲ្យថ្លៃលើសពីតម្លៃពួកកុម្មុយនិស្តដែលបានកំណត់ឲ្យ យើងច្បាស់ជាទិញបាន ហើយថ្ងៃក្រោយច្បាស់ជាឡើងថ្លៃ យើងមិនខាតទេ តែទិសដៅរបស់យើងគឺបង្អត់បាយកងទ័ព និងបង្អត់បាយប្រជាជន ។ ឆ្នាំនេះច្បាស់ជាមករកទិញដូចឆ្នាំមុនៗ ពេលពួកនោះមកសុំទិញ យើងកុំលក់ឲ្យ ដូច្នេះយើងទិញបានស្រូវមួយរទេះ ធ្វើឲ្យពួកកុម្មុយនិស្តលំបាកដោះស្រាយស្រូវមួយរទេះដែរ ធ្វើឲ្យមនុស្សមួយចំនួន ឬទ័ពវាមួយចំនួនអត់បាយ» ។ មិនតែប៉ុណ្ណោះពួកកុកម៉េងតាំងនៅស្រុកពារាំង ខេត្តព្រៃវែង មិនព្រមលក់ថ្នាំពេទ្យឲ្យទៅអង្គការឡើយ ដូចជានៅពេលណាមនុស្សរបស់ពួកកុម្មុយនិស្តមកសួររក ឆ្លើយថាគ្មាន ឬឈប់លក់យូរមកហើយ ។ ឡុង មុយ បានបន្តទៀតថាចាប់ពីឆ្នាំ១៩៧៤ ដល់ដើមឆ្នាំ១៩៧៥ អង្គការបានអំពាវនាវឲ្យសម្រុកលើកថ្នល់ដើម្បីងាយស្រួលក្នុងការដឹកជញ្ជូនស្បៀងឲ្យកងទ័ព ។ ប៉ុន្តែបក្សពួកកុកម៉េងតាំងក៏បានអំពាវនាវមិនឲ្យកូនចៅរបស់ខ្លួនចូលរួម ហើយព្រមទាំងបានបោះពាក្យដោយមិនចំហថា «មិនដឹងជាស្អីទេបន្តិចធ្វើនេះ បន្តិចធ្វើនោះ គ្មានពេលសម្រាកទេប្រើមនុស្សមើលតែសត្វ ធ្វើយ៉ាងនេះងាប់មនុស្សអស់ហើយ» ។

បក្សកុកម៉េងតាំងនៅស្រុកពារាំង ខេត្តព្រៃវែងបានបង្កើតចលនាសម្ងាត់ហៅថា សេ.អ៊ី.អា ដើម្បីឲ្យបក្សកុកម៉េងតាំងរបស់ខ្លួនមានភាពសកម្មក្នុងការផ្តួលរំលំបដិវត្តន៍កុម្មុយនិស្តខ្មែរក្រហម ដូច្នេះហើយទើបក្រុមបក្សកុកម៉េងតាំងនេះបានបង្កើតជាក្រុមសេ.អ៊ី.អាឡើង ក្នុងគោលបំណងបង្កប់ខ្លួនក្នុងបដិវត្តន៍កុម្មុយនិស្តខ្មែរក្រហម ។ និយាយរួមបក្សកុកម៉េងតាំងនិងសេ.អ៊ី.អា គឺជាចលនាតស៊ូប្រឆាំងនឹងរបបខ្មែរក្រហមតែមួយ ហើយបែបបទនៃការចូលជាសមាជិកសេ.អ៊ី.អា ត្រូវប្រព្រឹត្តទៅតាមរយៈការប្រជុំបញ្ចូលជាសមាជិកសេ.អ៊ី.អា ។ របៀបវារៈនៃការប្រជុំបញ្ចូលជាសមាជិកសេ.អ៊ី.អា រួមមានៈ ១-ប្រធានប្រកាសបើកអង្គប្រជុំ ២-អ្នកនាំចូលប្រកាសឈ្មោះសមាជិកថ្មី, ៣-អ្នកខ្មៀសនាមអានប្រវត្តិរូប, ៤-ប្រធានប្រកាសទទួលស្គាល់និងផ្តាំផ្ញើ, ៥សាម៉ីខ្លួនចាប់អារម្មណ៍និងសច្ចាចំពោះទង់ជាតិ និង ៦-ប្រកាសបិទកម្មវិធី ។

ក្រោយពីប្រកាសទទួលស្គាល់បញ្ចូលសមាជិកថ្មីហើយ ប្រធានអង្គប្រជុំបានផ្តាំផ្ញើថា «រូបភាពខាងក្រៅទាំងទ្រឹស្តី ទាំងសកម្មភាពជាក់ស្តែងត្រូវចេះធ្វើឲ្យបានល្អកុំឲ្យគេសង្ស័យធ្វើការងាររបស់យើងជាសម្ងាត់ គឺត្រូវចេះលាក់ការណ៍ឲ្យមានកំរិតខ្ពស់ ៗ» ហើយក្រុម សេ.អ៊ី.អា មានភារកិច្ចចម្បងៗ ដូចជាបង្កប់ស៊ីរូងផ្ទៃក្នុងឲ្យស៊ីជម្រៅក្នុងជួរបដិវត្តន៍, ធ្វើសកម្មភាពបំផ្លិចបំផ្លាញគ្រប់រូបភាព និងពង្រីកកម្លាំង សេ.អ៊ី.អា បន្ថែម ។ តាមការណែនាំរបស់ប្រធានអង្គប្រជុំ ឡុង មុយ បានដាក់ផែនការឲ្យសមាជិក សេ.អ៊ី.អា ថ្មីអនុវត្តដូចតទៅ÷ ពេលទឹកទន្លេឡើងពាសពេញត្រូវធ្វើសកម្មភាពដាន់ពន្លិច និងស្រាយទូកបណ្តែតចោលធ្វើឲ្យប្រជាជនព្រួយបារម្ភហើយ ធ្វើឲ្យកងទ័ពនិងអ្នកធ្វើការពិបាករកទូកឆ្លង, បង្កើនសកម្មភាពបំផ្លាញឧបករណ៍នេសាទត្រីនិងឧបករណ៍ផ្សេងៗទៀត តាមលទ្ធភាពដែលអាចធ្វើទៅបាន ។ សូមបញ្ជាក់ថា តាមចម្លើយរបស់ ឡុង មុយ ការប្រជុំបញ្ចូលជាសមាជិកសេ.អ៊ី.អានេះបានប្រព្រឹត្តទៅជាហូរហែរ ។ ប៉ុន្តែរបៀបវារៈនៃការប្រជុំ និងការដាក់ផែនការមានន័យប្រហាក់ប្រហែលគ្នាទៅនឹងភារកិច្ចចម្បងៗដែលក្រុមសេ.អ៊ី.អាត្រូវអនុវត្តទាំងបីខាងលើ ។

គោលបំណងរបស់ឈ្មោះ ឡុង មុយ ក្នុងការចូលធ្វើ

បដិវត្តន៍ខ្មែរក្រហម គឺដើម្បីបន្កប់ខ្លួនក្នុងជួរបដិវត្តន៍ខ្មែរក្រហមឲ្យបានជ្រៅ និងធ្វើឲ្យអសកម្មដល់បដិវត្តន៍ខ្មែរក្រហម ។ សកម្មភាពរបស់ ឡុង មុយ តាមចម្លើយសារភាពនេះគឺមិនដោះស្រាយជីវភាពឲ្យដល់ប្រជាជនមូលដ្ឋានបញ្ចេញស្បៀងឲ្យពួកក្បត់ និងយកលុយបដិវត្តន៍មកចាយវាយសម្រាប់ផ្ទាល់ខ្លួន ។

តាមចម្លើយរបស់ ឡុងមុយ បានឲ្យដឹងទៀតថាពេលដែលចុះទៅធ្វើការនៅស្រុកកងមាស ក្នុងខេត្តកំពង់ចាមដោយពេលនោះមានខ្មាំងវាយនៅផ្សារពាមជីកង និងនៅរកាកោង ជាហេតុធ្វើឲ្យប្រជាជនខ្វះខាតស្បៀង ជាពិសេសអង្ករហើយនៅពេលដែល ឡុង មុយ បានចុះទៅដល់ ឡុង មុយ ឥតបានគិតគូរដោះស្រាយជីវភាពឲ្យប្រជាជនបានធូរស្រាលពោល គឺមិនដោះស្រាយតាមរយៈអង្គការដូចគ្នាឡើយ ។ ផ្ទុយទៅវិញ ឡុង មុយ បែរជាបានអនុញ្ញាតឲ្យឈ្មួញកណ្តាលមកទាក់ទងលក់យកផលចំណេញលើប្រជាជននៅមូលដ្ឋានមួយជាន់ទៀត ហើយឈ្មួញកណ្តាលលក់ថ្លៃដោយសេរី ។ ឡុង មុយ ក៏បានរស់នៅស៊ីចុកជាមួយឈ្មួញកណ្តាលទាំងអស់នោះ ដែលជាហេតុនាំឲ្យប្រជាជនមូលដ្ឋានអស់ជំនឿលើអង្គការខ្មែរក្រហមមួយកម្រិតទៀត ។



ចំពោះលុយកាក់ដែលប្រជាជនឧបត្ថម្ភដល់អង្គការវិញ ឡុង មុយ បានយកទៅចាយវាយសម្រាប់ផ្ទាល់ខ្លួនដូចជាហូបគុយទាវ កាហ្វេ និងទិញសម្ភារៈផ្សេងៗសម្រាប់ប្រើប្រាស់ច្រើនថែមទៀត ។ សកម្មភាពជាក់ស្តែងដែលបក្សពួកកុកម៉េងតាំងប្រឆាំងនឹងខ្មែរក្រហមគឺឃោសនាប្រឆាំងនឹងបដិវត្តន៍ និងប្រឆាំងនឹងការឈប់ឲ្យប្រវាស់ស្រែនិងបណ្តាក់បុល ។ តាមសកម្មភាពជាក់ស្តែងជាដំបូងគឺឃោសនាប្រឆាំងនឹងអង្គការអំពីការមិនព្រមធ្វើការចរចារបស់ពួកខ្មែរក្រហម ដោយនិយាយថា «អង្គការធ្វើយ៉ាងដូច្នេះឆ្កួតជ្រុល នៅប្រទេសជិតខាងមានអាវុធទំនើបៗជាងយើងធ្វើសង្គ្រាមយូរជាងយើង ឥឡូវព្រមចរចាហើយៗបើចរចាទៅមិនបានសម្រេច វាយគ្នាតទៅទៀតក៏បានដែរ ដល់ពេលអង្គការមិនព្រមចរចាធ្វើឲ្យយន្តហោះទាំងអស់បានប្រមូលមកទម្លាក់គ្រាប់បែកតែលើប្រជាជនយើងលើប្រទេសយើងនាំឲ្យប្រជាជនយើងរងទុក្ខវេទនាជាងគេធ្វើឲ្យប្រទេសយើងបាក់បែកខ្ទេចខ្ទាំជាងគេ» ។ បន្ទាប់មកទៀតប្រឆាំងនឹងការឈប់ឲ្យមានការប្រវាស់ស្រែ និងការបណ្តាក់បុលដូចជានៅឆ្នាំ១៩៧២-១៩៧៣ អង្គការបានណែនាំឈប់ឲ្យមានការប្រវាស់ស្រែ និងបណ្តាក់បុលនៅឆ្នាំ១៩៧៣ ។ ពេលនោះ ឡុង មុយ បានឃោសនាប្រជាជនដែលធ្លាប់ប្រវាស់ស្រែទាំងនោះថា «មិនអីទេយើងប្រវាស់ស្ងាត់ៗទៅ ចាំដល់ថ្ងៃចែកផលយើងចែកគ្នាស្ងាត់ៗ បើអង្គការដឹងយើងថាចែកផលឲ្យអ្នកធ្វើបានច្រើនជាងម្ចាស់ស្រែដោះស្រាយតែប៉ុណ្ណឹងទៅវារួចស្រេចទៅហើយ មិនចាំបាច់ខ្វល់អីច្រើនទេ» ។ ចំពោះបញ្ហាបណ្តាក់បុល និងចងការប្រាក់វិញ ឡុង មុយ ក៏បានឃោសនាតាមរបៀបប្រហាក់ប្រហែលគ្នាដែរ ពោលគឺបំផុសឲ្យប្រជាជនបន្តការបណ្តាក់បុល និងចងការប្រាក់តទៅទៀត ។ ក្រៅពីនេះបក្សកុកម៉េងតាំងបានធ្វើសកម្មភាពក្បត់ផ្សេងៗទៀតចន្លោះឆ្នាំ១៩៧២-១៩៧៣ មានដូចជា បង្ខំឲ្យប្រជាជនសង់សាលារៀនហើយឲ្យសិស្សចូលរៀន និងឃោសនាប្រឆាំងគ្រប់វិធានការណាដែលបក្សកុម្មុយនិស្តខ្មែរក្រហមដាក់ចុះនៅគ្រប់ពេលវេលា និងធ្វើវិច្ឆេទកម្មសេដ្ឋកិច្ច



ប្រជុំចាត់តាំងអង្គការបក្ស

និងយោធាខិតខំពង្រីកកម្លាំង សេ.អ៊ី.អានៅតាមឃុំដែលចុះទៅដល់ និងបង្កឲ្យមានទំនាស់ឈ្លោះរវាងអង្គការ និងប្រជាជន។ ក្រោយពីលើកផែនការធ្វើសកម្មភាពទាំងនេះហើយ ក្រុមដឹកនាំបក្សកុកម៉េងតាំងក៏បានប្រកាសចាត់តាំងចលនាសេ.អ៊ី.អា នៅក្នុងក្រសួងឲ្យធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ដូចជាដឹកស្រូវ អង្ករ និងសត្វពាហនៈជាដើមយកទៅតំបន់ពួកក្បត់។

ក្រុមបក្សកុកម៉េងតាំងនៅក្នុងមន្ទីរក-១៦ បាននាំគ្នាធ្វើសកម្មភាពក្បត់នឹងបដិវត្តន៍ខ្មែរក្រហម ដូចជាបំបែកបំបាក់សាមគ្គីភាពរវាង កម្ពុជា-ចិន បន្ទុះបង្អាប់បក្សកុម្មុយនិស្តក្នុង


មហាលោតផ្ទោះមហាអស្ចារ្យ

ការថែរក្សាទ្រព្យសម្បត្តិរដ្ឋ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិរដ្ឋ និងបង្កទំនាស់ក្នុងគណៈមន្ទីររវាងក្រុមមួយទៅក្រុមមួយទៀត។ សកម្មភាពជាក់ស្តែងប្រឆាំងនឹងអង្គការបដិវត្តន៍ខ្មែរក្រហមរួមមានដូចជាបង្អត់បាយភ្ញៀវចិនជាច្រើនលើកជា ច្រើនសារ។ នៅវេលាម៉ោងប្រាំព្រឹកនាថ្ងៃមួយ នៅមុនពេលដែលចេញទៅធ្វើការភ្ញៀវចិនបានផ្តាំឲ្យដាំបាយ ប៉ុន្តែក្រុមបក្សកុកម៉េងតាំងធ្វើជាមិនដឹងមិនឮបណ្តោយឲ្យភ្ញៀវចិនអត់បាយក្រោយពេលត្រឡប់មកពីធ្វើការវិញ ហើយថែមទាំងបានណែនាំសមាជិកសេ.អ៊ី.អាទាំងអស់ នៅពេលប្រចាំការធ្វើជាមិនដឹងមិនឮ ឬភ្លេចនូវសំណូមពរចម្បងៗរបស់ភ្ញៀវចិនធ្វើឲ្យភ្ញៀវចិនទាំងនោះគ្មានជំនឿលើអង្គការបដិវត្តន៍របស់ខ្មែរក្រហម។ ម្យ៉ាងទៀតពេលបកប្រែឲ្យសិក្ខាកាមស្តាប់ភាគច្រើនអ្នកបកប្រែបកមិនឲ្យអស់ខ្លឹមសារ ធ្វើឲ្យភ្ញៀវចិនជាច្រើនមិនពេញចិត្តនឹងសិក្ខាកាម ព្រោះសិក្ខាកាមធ្វើមិនតាមសំណូមពរ។ ដោយឡែកជ័យភណ្ឌ និងសម្ភារៈប្រើប្រាស់ផ្សេងៗវិញគឺទុកចោលនៅហាល ភ្លៀង ជួនកាលទាត់សម្ភារៈប្រើប្រាស់ចោលនៅនឹងមុខភ្ញៀវចិនធ្វើឲ្យភ្ញៀវចិនមិនពេញចិត្តហើយចោទថា បក្សកុម្មុយនិស្តកម្ពុជាមិនចេះស្រឡាញ់ទ្រព្យសម្បត្តិរួម។ លើសពីនេះទៀតបានបង្កទំនាស់ក្នុងមន្ទីរអង្គការ ដូចជាយកមតិរបស់អ្នកនេះទៅប្រាប់អ្នកនោះធ្វើឲ្យក្នុងគណៈមន្ទីរមានទំនាស់ជាមួយគ្នាជាប់ជានិច្ច។

ចម្លើយសារភាពរបស់ ឡុង មុយ សរសេរថាមូលហេតុដែលអាណិកជនចិននៅស្រុកពារាំង ខេត្តព្រៃវែង របស់បក្សកុកម៉េងតាំងបានផ្លាស់ប្តូរឈ្មោះក្រុមសេ.អ៊ី.អារបស់ខ្លួនមកជាបក្សពលករវិញ ដោយមូលហេតុថាបក្សកុកម៉េងតាំងត្រូវបាន



ប្រជាជនចិននិងអាណិកជនចិនស្អប់ខ្ពើមខ្លាំងណាស់ក៏ដូចជាក្រោយពេលដែលប្រទេសកម្ពុជាទាំងមូលត្រូវបានរំដោះ។ ដើម្បីអូសទាញនិងដឹកនាំប្រជាជនឲ្យជឿបក្សកុកម៉េងតាំងនៅស្រុកពារាំង ខេត្តព្រៃវែង ក៏បានប្តូរឈ្មោះក្រុម សេ.អ៊ី.អារបស់ខ្លួនទៅជាបក្សពលករកម្ពុជាវិញដើម្បីបន្លំ ភ្នែកពួកបដិវត្តន៍កុម្មុយនិស្តខ្មែរក្រហមដោយសំអាងថាឈ្មោះបក្សពលករនេះត្រូវបានប្រទេសសង្គមនិយមក្នុងសកលលោកនិយមប្រើឈ្មោះបក្សពលករនេះដែរ។ ដូច្នេះហើយបានជាកើតមានចលនាតស៊ូសេ.អ៊ី.អានិងបក្សពលករកម្ពុជាជាហូរហែរ ព្រោះបក្សកុកម៉េងតាំងយល់ថារបបបដិវត្តន៍កុម្មុយនិស្តជារបបអយុត្តិធម៌គ្មានសិទ្ធិសេរីភាព គ្មានសុភមង្គល មួយថ្ងៃៗ ធ្វើការ នៅក្រោមកំដៅថ្ងៃ ហាលភ្លៀងហាលខ្យល់ គ្មានពេលសម្រាកទេហើយនៅតែហូបមិនឆ្អែតម្នាក់ៗស្គមនៅសល់តែឆ្អឹង។ ដោយសារតែមានចលនាក្បត់ប្រឆាំងនឹងរបបខ្មែរក្រហមយ៉ាងនេះហើយ ទើប ឡុង មុយ ដែលជា




សមាជិកម្នាក់ក្នុងចំណោម សមាជិកបក្សកុកម៉េងតាំងដទៃទៀត នៅស្រុកពារាំង ខេត្តព្រៃវែងត្រូវបានបដិវត្តន៍ខ្មែរក្រហមចាប់ខ្លួន ឡុង មុយ ហៅ ជួន បានឆ្លើយសារភាពក្រោមការសួរចម្លើយរបស់ឈ្មោះ អ៊ឹម អឿន ដែលជាអ្នកសួរចម្លើយនៅក្នុងគុកទួលស្លែងក្នុងជំនាន់របបខ្មែរក្រហម ។

ប្រពន្ធរបស់ ឡុង មុយ មានឈ្មោះថា អ៊ូម ស្រ៊ឹម ក៏ត្រូវបានអង្គការចាប់ខ្លួនដែរ ហើយ ឡុង មុយ បានឆ្លើយទាក់ទងនឹងសំដីរបស់ប្រពន្ធរបស់ខ្លួនដែលធ្លាប់បាននិយាយថា «ឃោសនាថាស្មើភាពតាមពិតអ្នកណាធំនៅតែមិនចេះខុស ឯងខុសរាល់ថ្ងៃត្រូវស្តីឲ្យរាល់ថ្ងៃអង្គការចាប់មនុស្សច្រើនយ៉ាងនេះ អស់មនុស្សធ្វើការហើយ» ។ ម្យ៉ាងវិញទៀតក្រោយពីឯកសារនេះត្រូវបានរៀបចំហើយ ឈ្មោះឌុច ដែលជាប្រធានគុកទួលស្លែងបានសរសេររាយការណ៍ ជូន សុន សេន ថា «បងជាទីគោរព, ១-កម្លាំងដែលវារាយការណ៍ក្នុងនេះ សុទ្ធតែពួកតំបន់២២ទាំងពួកក្នុងជួរបដិវត្តន៍ទាំងខ្សែកុកម៉េងតាំងចាស់ នៅពារាំង ។ ២-កម្លាំងខ្ពស់បំផុតដែលវានិយាយគឺអាទុំ ។ ៣-មិត្តអ៊ាងស៊ីផេងវានិយាយថាជាអ្នកបដិវត្តន៍ និយាយជាជំហរវាតែម្តង,ដោយគោរព,ឌុច, ១៥-១០៧៧» ។ សុន សេន ហៅខៀវ ក៏បានរាយការណ៍បន្តដោយសរសេរថា «១-អាចសំខាន់ដែរ, ២-អានេះខ្សែអាណិកជនចិនបកប្រែ, ៣-ខ្ញុំមិនទាន់អានទេសូមជូនបងអានមុន, ខៀវ, ១៧-១០-៧៧» ។ សុន សេន បានរាយការណ៍ទៅអង្គការលើទំនងជាចំណាររបស់ នួន ជា ដែលបានចារថា «ជូនហើយ,១១-១១-៧៧» ។ ចំណារមួយផ្សេងទៀតបានសរសេរថា «ពិសេសខាងសមមិត្តខៀវ, ទាក់ទងបូព៌ា» ។

**សុភារិទ្ធ**

## សម្រង់ពាក្យស្លោកខ្មែរក្រហម

- ◆ ភារកិច្ចរបស់យើងត្រូវទទួលខុសត្រូវចំពោះប្រជាជន គ្រប់សំដី គ្រប់អំពើ គ្រប់នយោបាយ ត្រូវតែស្របតាមយោបល់ ស្របតាមប្រយោជន៍របស់ប្រជាជនទាំងស្រុង បើមានកំហុសត្រូវតែកែតម្រូវ បានហៅថាទទួលខុសត្រូវចំពោះប្រជាជន។
- ◆ បើតាមភាសាយោធា ការនេះគេនិយាយបានថា យើងកម្ទេចបានសត្រូវមួយម្តងៗ។
- ◆ ខ្យល់ទិសបូព៌ា តែងឈ្នះទិសបស្ចិមជានិច្ច។

(ពាក្យស្លោកខ្មែរក្រហមៈ សៀវភៅលេខ០៥៣កណាហ)

- ◆ កងទ័ពស្រួចប្រមូលផ្តុំវាយកម្ទេចខ្មាំង កម្ទេចកម្លាំងធំរបស់ខ្មាំងទើបយើងឆាប់រហ័សបានទទួលជ័យជំនះ និងអាចការពារពង្រីកកម្លាំងយើងបាន។

(ពាក្យស្លោកខ្មែរក្រហមៈ សៀវភៅលេខ១៩៨កណាហ)

- ◆ ពង្រីកពង្រឹងគោលជំហរអធនជាច់ខាត ហើយកម្ចាត់ឱ្យអស់រលីងនូវគោលជំហរវណ្ណៈផ្សេងៗដែលមិនអធន។

(ពាក្យស្លោកខ្មែរក្រហមៈ សៀវភៅលេខ១៣៥កណាហ)

- ◆ គ្រប់សរសៃញាក់ និងគ្រប់សកម្មភាពរបស់សមរភូមិក្រោយត្រូវជាប់ខ្សែកយ៉ាងខ្លាំងក្លា និងយ៉ាងថ្លាត្រចង់របស់សមរភូមិមុខ។

(ពាក្យស្លោកខ្មែរក្រហមៈ សៀវភៅលេខ០០២កណាហ)

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហមមកកាន់
**ទស្សនាវដ្តី «ស្វែងរកការពិត»**
ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០៣៥៨
ឬ Email: dccam@bigbond.com.kh

# ភូមិចន្ទ្រាធ្លាក់ក្នុងវិនាសកម្មនៃសង្គ្រាម

ភូមិចន្ទ្រាជាភូមិមួយ ស្ថិតនៅជាប់ព្រំប្រទល់កម្ពុជាវៀតណាមដែលមានចម្ងាយប្រហែលជា៥ ទៅ៦គីឡូម៉ែត្រពីបន្ទាត់ព្រំប្រទល់ និងប្រមាណជាង៥០គីឡូម៉ែត្រ ពីទីរួមខេត្តស្វាយរៀង ។ ភូមិចន្ទ្រាជាភូមិមួយក្នុងចំណោមភូមិទាំង៤នៅក្នុងឃុំចន្ទ្រា ស្រុកជីភូ (បច្ចុប្បន្នស្រុកចន្ទ្រា) ខេត្តស្វាយរៀង ។ កាលពីឆ្នាំ១៩៦៤ ភូមិនេះរងគ្រោះថ្នាក់ពីការទម្លាក់គ្រាប់បែក និងគ្រាប់ផ្លោងយ៉ាងសន្ធឹកសន្ធាប់ដោយទ័ពវៀតណាមខាងត្បូងដែលចូលរួមដោយអាមេរិកក្នុងការតាមកម្ទេចពួកវៀតកុងដែលធ្វើឲ្យឆេះផ្ទះមួយចំនួន សត្វពាហនៈ និងមនុស្សប្រហែល២០នាក់ត្រូវបាត់បង់ជីវិត ។ រាជការជំនាន់នោះដែលមានសម្តេចនរោត្តម សីហនុ ជាប្រមុខរដ្ឋបានចេញមុខដោះស្រាយការលំបាករបស់អ្នកភូមិដែលជាជនរងគ្រោះ ដោយសាងសង់ផ្ទះឲ្យវិញចំពោះផ្ទះណាដែលបានឆេះទៅជាផេះក្នុងឧប្បត្តិហេតុនេះ ។

ដោយសារថាភូមិចន្ទ្រាជាភូមិមួយដែលរងគ្រោះធ្ងន់ធ្ងរ និងស្ថិតនៅឆ្ងាយដាច់ស្រយាលពីទីរួមខេត្តស្វាយរៀង សម្តេចសីហនុ បានប្តូរឈ្មោះស្រុក ពីស្រុកជីភូ ទៅជាស្រុកចន្ទ្រាវិញ ហើយប្តូរទីតាំងសាលាស្រុកយកទៅដាក់នៅក្នុងឃុំចន្ទ្រា ។ ដោយភាពក្រខ្វត់ និងភាពស្ងាត់ជ្រងំរបស់ឃុំចន្ទ្រា មន្ត្រីថ្នាក់ក្រោមក៏បានផ្លាស់ប្តូរទីតាំងរបស់សាលាស្រុកទៅនៅក្នុងឃុំសិតថ្ងក (មេសថ្ងក) ព្រោះនៅទីនោះមានផ្សារហើយអ៊ូរអរជាង ។ការដែលផ្លាស់ប្តូរទីតាំងរបស់សាលាស្រុកពីឃុំចន្ទ្រាទៅឃុំសិតថ្ងក គឺផ្ទុយស្រឡះទៅនឹងព្រះរាជតម្រិះរបស់សម្តេចសីហនុទាំងស្រុង ដែលមានបំណងចង់ធ្វើឲ្យភូមិចន្ទ្រាស្ថិតនៅក្នុងភាពមិនឯកោស្រងេះស្រងោចដាច់ស្រយាលតែឯង ឆ្ងាយពីរាជការគឺចង់ឲ្យអ្នកភូមិនេះមានអារម្មណ៍ថា ខ្លួននៅជិតរាជការដែលជាអាណាព្យា-បាល និងជាអ្នកជួយមើលថែទាំភូមិម្ករ និងអ្នកស្រុក ។

តាំងពីឆ្នាំ១៩៦៤ រហូតដល់ឆ្នាំ១៩៧៥ ភូមិចន្ទ្រាត្រូវរងគ្រោះថ្នាក់ដោយសារការទម្លាក់គ្រាប់បែក និងគ្រាប់ផ្លោងយ៉ាងសន្ធោរសន្ធៅពីសំណាក់រដ្ឋាភិបាល វៀតណាមខាងត្បូងដែលគាំទ្រដោយសហរដ្ឋអាមេរិក ។ ការទម្លាក់គ្រាប់បែកនេះបានធ្វើឲ្យខូចខាំខូចខាតសាលារៀន មន្ទីរពេទ្យ ផ្ទះសំបែង ងាប់គោក្របី ជ្រូក មាន់ទា និងយ៉ាងហោចណាស់មានមនុស្សជាង១០០នាក់ត្រូវស្លាប់ និងបន្សល់ទុកអ្នករបួស ពិការ ទាំងផ្លូវចិត្ត និងផ្លូវកាយ ។ ជាច្រើនអ្នកទៀតនៅរស់រានមាន ជីវិតសព្វថ្ងៃនៅក្នុងភូមិយ៉ាងអាណោចអាធម ។

បងប្រុសឈ្មោះ ដើក នេត អាយុ៣៨ឆ្នាំ ជាកសិករស្រុកកំណើត និងទីលំនៅនៅភូមិចន្ទ្រា ឃុំចន្ទ្រា ស្រុកចន្ទ្រា ខេត្តស្វាយរៀង បាននិយាយថា ក្នុងឆ្នាំ១៩៦៤ អាមេរិកបានទម្លាក់គ្រាប់បែកមកលើភូមិចន្ទ្រា ដោយមូលហេតុថា មានពួកទាហានវៀតកុងចូលមកក្នុងភូមិនេះ ។ កាលនោះមានផ្ទះប្រជាជនជាច្រើនខ្នងត្រូវបានឆេះ ដោយសារគ្រាប់បែកបេ៥២ ។ ក្នុងចំណោមផ្ទះដែលឆេះនោះ មានផ្ទះក្បឿងមួយខ្នងរបស់ឪពុកម្តាយគាត់ ក៏ត្រូវបានយន្តហោះបាញ់សាំងឲ្យឆេះ ។ នៅក្នុងផ្ទះដែលឆេះនោះមានបងស្រីគាត់ម្នាក់ឈ្មោះ មិន សួន (អាយុប្រហែល១៣ឆ្នាំ សំដីរបស់ សុក ឡូម ត្រូវជា ឪពុកមារបស់ នេត និងស្ងួ សាវ៉ុន អ្នកជិតខាង) និងបងប្រុសម្នាក់ទៀតឈ្មោះ ដើក ណាន អាយុប្រហែល១០ឆ្នាំ (សំដីរបស់ សុក ឡូម ត្រូវជាឪពុកមារបស់ នេត និងស្ងួ សាវ៉ុន អ្នកជិតខាង) ត្រូវឆេះរលាកនៅក្នុងផ្ទះដោយរត់ចេញមិនទាន់នៅពេលក្បាលល្ងាច ។ បន្ទាប់ពីភ្លើងឆេះហើយ ឪពុកម្តាយគាត់បានយកកូនទាំងពីរនាក់ទៅព្យាបាលនៅទីក្រុងភ្នំពេញ ។ បន្ទាប់ពីព្យាបាលបងរបស់គាត់ទាំងពីរនាក់ក៏រួចផុតពីគ្រោះថ្នាក់ដល់ជីវិត ។ តែរឿងដែលគួរឲ្យអនិច្ចានោះ គឺចំពោះបងស្រីរបស់គាត់ត្រូវឆេះ រលាកពោះពេលជាសះស្បើយវិញដៃទាំងពីរជាប់ក្លៀកមិនអាចដាក់ចុះក្រោមបានទេ ពេលផ្ទុតទឹកម្តងៗគឺលំបាកណាស់ ព្រោះដងទឹកបានតែតិចៗទំរាំតែផ្ទុតហើយយូរណាស់ ។ បងស្រីគាត់នៅតែពិការដដែល មិនអាចដាក់ដៃទាំងពីររបស់គាត់ចុះដូចមនុស្សធម្មតាបានទេ ។ អ្នកស្រុកភូមិវិញមានការអាណិតអាសូរបងស្រីគាត់គ្រប់ៗគ្នា ។ រីឯបងប្រុសគាត់វិញត្រូវរបួសជើងមិនពិការទេ តែក្រោយពីជាសះស្បើយ ប៉ុន្តែមានស្លាកស្នាមហើយជើង

ត្រូវស៊ិត ។ ផ្ទះក្បឿងរបស់ឪពុកធំ(អ៊ំ) របស់គាត់មួយខ្នងទៀតក៏ត្រូវឆេះអស់ដែរ ប៉ុន្តែមិនមានមនុស្សស្លាប់ទេ ពីព្រោះពួកគាត់គ្មាននរណានៅក្នុងផ្ទះនោះ ។ ក្រោយពីការទម្លាក់គ្រាប់បែកក្រុមគ្រួសារគាត់ត្រូវបានសម្តេចសីហនុ សង់ផ្ទះឲ្យវិញមួយខ្នង និងសង់ផ្ទះឲ្យប្រជាជនណាដែលផ្ទះត្រូវឆេះខ្ទេចខ្ទីដោយសារគ្រាប់បែកនៅពេលនោះ ។ ផ្ទះដែលសង់នោះធ្វើអំពី ឈើប្រក់ស័ង្កសីមានទំហំ៦-៨ម៉ែត្រ ។

ក្នុងឆ្នាំ១៩៧០ មានហេតុការណ៍ដ៏រន្ធត់កើតឡើងម្តងទៀតនៅពេលដែលយន្តហោះលន់ ណុល បានចាប់ផ្តើមទម្លាក់គ្រាប់បែកនិងបាញ់ផ្លោងយ៉ាងសន្ធឹកសន្ធាប់ពីខាងត្បូងមកដាក់ភូមិចន្ទ្រាគឺច្រើនជាងកាលពីឆ្នាំ១៩៦៤ទៅទៀត ។ ការប្រយុទ្ធគ្នាប្រព្រឹត្តទៅជាប់ បីថ្ងៃ បីយប់ ។ នៅយប់ថ្ងៃទីពីរ គឺនៅពេលដែលបាញ់ខ្លាំង ឪពុកម្តាយគាត់ និងកូនចៅបានរត់ទៅរកត្រង់សេ ។ ឪពុកគាត់ និងបងគាត់ទាំងពីរនាក់ដែលពិការ កាលពីឆ្នាំ១៩៦៤ បានរត់ទៅពួននៅក្នុងត្រង់សេមួយជាមួយគ្នា រីឯម្តាយគាត់ដោយសារការភ័យរន្ធត់ខ្លាំងពេក ក៏រត់ហួសចូលទៅក្នុងត្រង់សេផ្សេងមួយទៀតជាមួយជីតារបស់គាត់ឈ្មោះ យូ ។ នៅពេលកំពុងតែបាញ់គ្នានោះ គ្មានអ្នកណាដឹងថា អ្នកណារស់អ្នកណាស្លាប់ទេ ។ អ្នកភូមិមិនបានហូបបាយ ហូបទឹកទេ ក្នុងរយៈពេល២-៣ថ្ងៃនោះគឺពួននៅក្នុងត្រង់សេរហូត ។ ២ថ្ងៃក្រោយមកទើបបានម្តាយគាត់ដឹងថាឪពុក និងបងគាត់ពីរនាក់ដែលនៅក្នុងត្រង់សេផ្សេងត្រូវស្លាប់ក្នុងត្រង់សេទាំងអស់គ្នា ដោយសារពួកទាហានរដ្ឋាភិបាលបោកគ្រាប់បែក ។ សាកសពទាំង៣ត្រូវបានកប់ក្នុងត្រង់សេនោះតែម្តង ។ ពេលកប់សពរួចហើយ ម្តាយគាត់រត់ចេញពីភូមិចន្ទ្រាទៅខាងជើងវត្តចន្ទ្រា រួចរត់ទៅនៅភូមិទួលប្រលាននៅក្នុងឃុំច្រៃ ។

នៅឆ្នាំ១៩៧៥ ពេលចប់សង្គ្រាម ទើបម្តាយគាត់អាចចូលមកភូមិកំណើតវិញបាន ដើម្បីធ្វើបុណ្យសពឲ្យឪពុក និងបងគាត់ទាំងពីរដែលស្លាប់នៅក្នុងត្រង់សេ ។ ម្តាយគាត់មុនពេលស្លាប់បានផ្តាំ បងប្រុសគាត់ថា ធំឡើងធ្វើទាហានតស៊ូ ។ គាត់ខឹងនឹងពួករដ្ឋាភិបាលដែលសម្លាប់ឪពុកគាត់ ។

តាមបទសម្ភាសន៍ជាមួយលោកតា ប្រាក់ សារិន អាយុ ៦៤ឆ្នាំ កើតនៅភូមិចន្ទ្រា ឃុំចន្ទ្រា ស្រុកចន្ទ្រា ខេត្តស្វាយរៀង លោកតាបានមានប្រសាសន៍ថា នៅឆ្នាំ១៩៥០ គាត់បានទៅបួសរៀននៅវត្តសេរីវង្ស ស្ថិតនៅក្នុងភូមិចន្ទ្រា រហូតដល់ឆ្នាំ១៩៥៥ ទើបសឹកឈប់រៀន ។ ក្រោយមកគាត់រៀបការជាមួយលោកយាយប្រុក អេង ។ នៅខែប្រាំងរវាងខែ១ ឬខែ២ ឆ្នាំ១៩៦៤ មានយន្តហោះរបស់អាមេរិកពីរគ្រឿង មកទម្លាក់គ្រាប់បែកនៅភូមិចន្ទ្រា និងមានរថក្រោះ៤គ្រឿងបើកចូល ។ គ្រាប់បែកជាច្រើនគ្រាប់ត្រូវបានទម្លាក់ ដែលធ្វើឲ្យមនុស្សជាង១០នាក់ត្រូវ


ស្លាកស្នាមសង្គ្រាមដោយសារការទម្លាក់គ្រាប់

ស្លាប់ និងគោក្របីជាច្រើនក្បាលត្រូវងាប់ដែរ ។ អ្នកដែលស្លាប់នោះមានទូក រឿន (ពេលនោះអាយុប្រហែល៣២ឆ្នាំ), ម៉ៅ យិន ប្រុស (អាយុប្រហែល៣៨ឆ្នាំ), ចាន់ មឿន (អាយុប្រហែល១៨ឆ្នាំ), ពៅ អឹង ជាស្ត្រីមានផ្ទៃពោះ (អាយុប្រហែល៤០ឆ្នាំ), ភឿក សាបន ស្រីនៅលីវ (អាយុប្រហែល២៩ឆ្នាំ) ។

ពួកទាហានធីវគីជិះឧទ្ធម្ភាគចក្រ ហោះកម្ពស់ ប្រហែល៥០០ម៉ែត្រ បាញ់កាំភ្លើងស្វ័យប្រវត្តិចុះមកក្រោម ។

នៅក្នុងឆ្នាំ១៩៦៣-៦៤ លោកតាសារិន ធ្វើជាកងជីវពលការពារភូមិចន្ទ្រា ។ គាត់កាន់កាំភ្លើងម៉ាកអង់ហ្វៀល ។ ពេលគាត់ឃើញ ពួកទាហានគាត់រត់ជាមួយក្របី ហើយរថក្រោះ ពួកទាហានដេញបាញ់ពីក្រោយខ្នង ។ មុនដំបូងគាត់មិនទាន់លែង



បែក ប៥២ នៅភូមិចន្ទ្រា ខេត្តស្វាយរៀង

ក្របីទេ តែក្រោយមកមានឧទ្ធម្ភាគចក្រដេញបាញ់ពីលើ ពេលនោះគាត់ក៏លែងគោក្របីហើយរត់គេចផុត ប៉ុន្តែក្របី និងគោជាង ១០ក្បាលត្រូវគ្រាប់ងាប់អស់ ។ គាត់រត់ទៅលាក់ខ្លួននៅក្នុងប្រឡាយក្បែរភូមិដើម្បីគេចពីគ្រាប់កាំភ្លើង ។ គាត់អោបកាំភ្លើងក្រាបនៅក្នុងប្រឡាយ ពួកទាហានមិនឃើញគាត់ទេ ។ បើទាហានធីវគីឃើញគាត់ វាបាញ់សម្លាប់គាត់ហើយ ព្រោះគាត់ជាជីវពលដែលបានបាញ់តជាមួយពួកទាហានមួយប្រាវហើយ កាលពីមុនហ្នឹង(លោកតាបញ្ជាក់) ។ ជីវពលទូទាំងឃុំបានបាញ់តជាមួយពួកទាហានធីវគីតែមិនឈ្នះ ។ គាត់បាញ់តទល់ជាមួយពួកទាហាននៅភូមិតែងម៉ៅ ខាងលិចភូមិចន្ទ្រា ។ មូលហេតុដែលគាត់បាញ់ពួកទាហានព្រោះនៅតាមព្រំដែនពួកគាត់ខ្លាចទាហានចូលមកក្នុងភូមិដុតផ្ទះសំបែងប្រជាជន ។ មុនដំបូងរថក្រោះទាហានងាកក្បាលទៅកើត តែដោយសារពួកគាត់បាញ់ វាក៏ងាកក្បាលមកវិញហើយឈប់មួយសន្ទុះចម្ងាយ៣០០ម៉ែត្រពីភូមិចន្ទ្រា ទីនោះមានអន្លង់មួយហៅថាអន្លង់ព្រៃពស់ ។ ពេលចូលដល់ភូមិពួកទាហាននៅលើរថក្រោះ បញ្ជាឲ្យកូនចៅដេញចាប់ប្រជាជនមួយចំនួនយកទៅជាមួយ ឧទាហរណ៍ដូចជា បងជីដូនមួយគាត់ឈ្មោះ សោម យុត កាលនោះអាយុ៤៥ឆ្នាំ ត្រូវពួកទាហានចាប់ ។ តែក្រោយមកដោះលែងមកវិញ ។ ពេលនោះប្រជាជនមួយចំនួនបានភៀសខ្លួនទៅជីភូ ។ ៣-៤ថ្ងៃក្រោយមកបានមកចូលភូមិវិញ ។

ខែប្រាំង ឆ្នាំ១៩៧០ មានការទម្លាក់គ្រាប់បែកច្រើនណាស់នៅភូមិចន្ទ្រា និងភូមិតែងម៉ៅ ធ្វើឲ្យផ្ទះសំបែងសាលារៀន មន្ទីរពេទ្យខូចខ្ទីចខ្ទីអស់ ។ ប្រជាជនមួយចំនួន បំរុងទិញម៉ូតូ និងផ្ទះបំរុងសង់ត្រូវខកខានដោយសារសង្គ្រាមរហូតមក ។ មូលហេតុដែលមានការទម្លាក់គ្រាប់បែកនោះ គឺដោយសារជឿថាមានទាហានពួកវៀតកុងនៅតាមជាយដែនកម្ពុជា-វៀតណាម ។ ទាហានអាមេរិក និងធីវគីមកពីវៀតណាមខាងត្បូងតាមបាញ់ពួកទ័ពវៀតកុង ហើយទាហានវៀតកុងក៏រត់ចូលមកដីខ្មែរដូច្នោះ ពួកទាហានក៏តាមបាញ់រហូតដល់ស្រុកចន្ទ្រា ។ ពួកទាហានវៀតណាមខាងត្បូង ឲ្យតែឃើញពួកវៀតកុងម្នាក់ ឬពីរនាក់ ក៏តាមដេញបាញ់ដល់ដីខ្មែរដែរ ។ នៅក្នុងឆ្នាំ១៩៧០ មានទាហានវៀតកុងនៅក្នុងភូមិចន្ទ្រាច្រើនណាស់គឺនៅគ្រប់ទីកន្លែង ។ ពួកវៀតកុងយកអង្ករមកលាក់ទុកតាមផ្ទះប្រជាជនពេញៗផ្ទះ អង្ករទាំងនោះគឺសម្រាប់ពួកវាធ្វើសង្គ្រាមជាមួយពួកអាមេរិក ។ ពួកវាមិនដែលឲ្យអង្ករប្រជាជនយើងទេ ។ ដល់ពេលពួកវៀតកុងរត់ទៅអស់ដោយសារចាញ់សង្គ្រាមទើបពួកយើងអាចយកអង្ករនោះបានតិចតួច ។

**(នៅមានត)**

**ឡៀង សុភក្រ័ទ្ឋា**

# ជនជាតិភាគតិច "ភ្នង" និងឧក្រិដ្ឋកម្ម

កាលពីខែធ្នូ ឆ្នាំ១៩៩៩ ខ្ញុំបានចុះទៅសិក្សាស្រាវជ្រាវអំពីជនជាតិភាគតិចក្រោមរបបកម្ពុជាប្រជាធិបតេយ្យនៅភូមិភាគឦសាន ។ ក្រុមរបស់ខ្ញុំបានជួបសម្ភាសន៍ជាមួយមីង គីយ ដាត់ជនជាតិភ្នង ដែលជាប្រពន្ធរបស់ ប្រី ស្រឹត ជាអ្នកទោសគុកទួលស្លែង ។ មីង គីយ ដាត់ សព្វថ្ងៃរស់នៅក្នុងភូមិសុខសាន្ត ឃុំ សុខសាន្ត ស្រុកកោះញែក ខេត្តមណ្ឌលគិរី ដែលជាភូមិមួយនៅដាច់ស្រយាលបំផុតនាភាគឦសាននៃប្រទេសកម្ពុជា ហើយកម្រមានអ្នកសិក្សាស្រាវជ្រាវចុះទៅដល់ណាស់ ។ ដូចជាប្រជាជនកម្ពុជាភាគច្រើនដែរមីង គីយ ដាត់ ពុំបានដឹងពិតប្រាកដអំពីជោគវាសនារបស់ប្ដីគាត់ឡើយ ។ នៅពេលដែលខ្ញុំសួរអំពីប្ដីរបស់គាត់ មីង គីយ ដាត់ ឆ្លើយថា «អត់ដឹងទេ ពុថាងាប់មិនដឹង» ។



រូបភាពនេះប្រហែលថតនៅឆ្នាំ១៩៦៨ នាភូមិភាគឥសាន

ប្រី ស្រឹត ហៅ ខាំ វ៉ាត់ ជាជនជាតិភ្នងនៅភូមិភាគឦសាននៃប្រទេសកម្ពុជាត្រូវពួកទាហានខ្មែរក្រហមស្លៀកពាក់ខ្មៅ ចាប់ខ្លួននៅខែ៨ ឆ្នាំ១៩៧៧ ដោយចោទថាជាខ្មែរយៈយួន (ភាសាប្រើក្នុងឯកសារ) ។ ដោយមានការចោទប្រកាន់ថា «ជាខ្មែរយៈយួន ឬសេ.អ៊ី.អា ឬកា.ហ្សេ.បេ» ពួកទាហានខ្មែរក្រហមបានចាប់អ្នកទាំងឡាយណាដែលទោះជាមែនឬមិនមែនយកទៅដាក់មន្ទីរឃុំឃាំងដើម្បីសួរជំរិតយកចម្លើយ ។ ខ្ញុំសួរមីង គីយ ដាត់ ថា «តើពេលពួកខ្មែរក្រហមចាប់ប្ដីមីងនោះពួកខ្មែរក្រហមបាននិយាយយ៉ាងម៉េចខ្លះ?» គាត់និយាយថា«និយាយថាខ្មែរយៈយួនយកបាយទឹកឲ្យយួន ។ មានឃើញយួនឯណានាំប្រជារាស្ត្រធ្វើស្រែចម្ការ ។ មានយួនឯណាវាចោទថាខ្មែរយៈយួន» ។ ឯកសារចម្លើយសារភាពរបស់ប្រី ស្រឹត (លេខ P.១៨៩) ដែលធ្វើឡើងដោយអ្នកសួរចម្លើយពីរនាក់ម្នាក់ឈ្មោះ ខុម និង ម្នាក់ទៀតឈ្មោះ សេង កាលពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៨ បានបង្ហាញពីការរាយការណ៍របស់អ្នកសួរទាំងពីរខាងលើថា «សួរពីប្រវត្តិឆ្លងកាត់របស់វា ដើម្បីរកចំនុចបុក... ប្រមូលចំនុចខ្សោយយកទៅសង្កត់ឲ្យវាទទួលខ្លួនក្បត់ហើយសួររកខ្សែសង្វាក់» ។ យើងអាចប្រៀបធៀបបានចំពោះសំដីរបស់មីង គីយ ដាត់ ប្រពន្ធរបស់ជនរងគ្រោះ ប្រី ស្រឹត និងសំណេររាយការណ៍របស់អ្នកសួរចម្លើយទាំងពីរនាក់ ខុម និង សេង ថាតើ ប្រី ស្រឹត ក្បត់មែនឬយ៉ាងណា ។

កូនប្រុសរបស់ជនរងគ្រោះ ប្រី ស្រឹត ឈ្មោះ ស្រឹត ភឿន កាលក្នុងរបបខ្មែរក្រហម នៅមានវ័យក្មេងនៅឡើយមានអាយុប្រហែលបួន-ប្រាំឆ្នាំ ប៉ុន្តែបាននិយាយថាខ្លួននៅចាំបានចំពោះព្រឹត្តិការណ៍ដែលពួកទាហានខ្មែរក្រហមចាប់ឪពុករបស់ខ្លួនហើយ ពេលនោះខ្លួនថែមទាំងបានទៅគោងដៃគោងជើងឪពុក

ទៀតផង ។ គ្មានលទ្ធផលទាល់តែសោះពួកយោធាខ្មែរក្រហមនៅតែចាប់យកឪពុករបស់ស្រីត ភឿនទៅបាត់ដដែល ហើយ ស្រីត ភឿន ត្រូវបានពួកទាហានទាំងនោះច្រានចេញ ដោយប្រើពាក្យគំរាមគំហែងថា នឹងយកទៅសម្លាប់ ។ ស្រីត ភឿន រៀបរាប់ដោយទឹកមុខរកកលនឹងយំថា *«វាចាប់ខ្ញុំច្រានចេញ កុំតាម កុំតាម នៅតែតាមហ្នឹង ងាប់ទៀតហើយវាថាអញ្ចឹង»..... «ខ្ញុំតូចទេ បើធំត្រឹមនេះពួកវាចាប់ទាំងអស់គេថាកូនក្បត់»* ។ និយាយចប់ ស្រីត ភឿន ក្រឡេកមើលទៅផ្ទះរបស់ខ្លួនប្រក់ស្បូវ ជញ្ជាំងស្លឹកដែលថ្ងៃរសៀលកំពុងចាំងពន្លឺនៅផ្ទៃខាងក្រោយមានពណ៌ក្រហមច្រាល ។ ពេលនោះខ្ញុំហាក់មានអារម្មណ៍ថា ផ្ទះរបស់ភឿន មានប្រឡាក់ឈាមរបស់ពូស្រីត ដែលពួកខ្មែរក្រហមសម្លាប់យ៉ាងដូច្នេះដែរ ។ ចំណែកមីង ដាត់ វិញ ពេលដែលពួកយោធាខ្មែរក្រហមចាប់ប្តីរបស់មីងទៅ មីងគ្មានហ៊ាននិយាយអ្វី ឬក៏តវ៉ាអ្វីឡើយគឺបានត្រឹមតែយំស្រណោះតែប្តីប៉ុណ្ណោះ ។ មីង ដាត់ និយាយថា *«អត់ហ៊ាននិយាយទេ អត់ហ៊ានទេខ្លាចគេចាប់ទៀតនោះណា៎ អត់ហ៊ាននិយាយកាលណោះ»* ។ ឆ្នាំនេះ ភឿន មានអាយុ២៩ឆ្នាំ ។ ទាំងកូនទាំងម្តាយបានចងចាំរឿងរ៉ាវនេះច្បាស់ណាស់ ។ នៅពេលដែលពួកយោធាខ្មែរក្រហមចាប់ ប្រី ស្រីត យកទៅកូនៗយំតាមឪពុក ។ ចំណែកមីង ដាត់ បានព្យាយាមលួងលោមកូនៗរបស់គាត់កុំឲ្យយំ ព្រោះខ្លាចពួកខ្មែរក្រហមទាំងនោះយកទៅសម្លាប់ទៀត ដោយនិយាយថា «ឈប់យំ អាហ្នឹងថា ប៉ាដឹងតែងាប់ហើយ កូនកុំយំ តែយំទៀតយើងត្រូវតែងាប់តាមហ្នឹងហើយ» ។ រហូតមកដល់ថ្ងៃនេះទាំងភឿន ទាំងមីងដាត់ នៅតែជឿជាក់យ៉ាងមុតមាំថា «ប្រី ស្រីត មិនបានក្បត់ទេ មិនបានទាក់ទងយួនអ្វីនោះទេ ។ ភឿន និយាយថា «គ្មានទៅណា ទៅណីទេ ដល់ក្រោយដឹងម៉េចគេថាទាក់ទងយួននោះគេចាប់» ។

តាមការអានឯកសាររបស់ ប្រី ស្រីត ដែលធ្វើឡើងដោយអ្នកសួរចម្លើយ ឈ្មោះ ខុម និង សេង ហាក់ដូចជាពួកអ្នកសួរចម្លើយទាំងពីរនាក់នេះទម្លាក់កំហុសទាំងស្រុងទៅលើ ប្រី ស្រីត ដែលសុីគ្នានឹងការរៀបរាប់ក្នុងបទសម្ភាសន៍ជាមួយមីងដាត់ និងកូនរបស់គាត់ ។ អ្នកសួរទាំងពីរនាក់ ខុម និង សេង បានចុះហត្ថលេខាលើរបាយការណ៍ ដែលរបាយការណ៍នោះសរសេរថា *«ប្រមូលចំណុចខ្សោយយកទៅសង្កត់ឲ្យវាទទួលខ្លួនក្បត់ហើយ សួររកខ្សែសង្វាក់»* និងមានមួយឃ្លាទៀតបង្ហាញកាន់តែច្បាស់ថាពួកខ្មែរក្រហមទម្លាក់កំហុសទាំងស្រុងទៅលើ ប្រី ស្រីត ដោយសរសេរថា *«ក្រោយពីប្រមូលចំណុចខ្សោយទៅសង្កត់សួរជាបន្តបន្ទាប់មកវាក៏សារភាពថាសេ.អុី.អា»* ។

មានរបាយការណ៍ភ្ជាប់មកជាមួយចម្លើយសារភាពរបស់ ប្រី ស្រីត បានសរសេរថា «វានិយាយគ្មានច្បាស់លាស់ជាខ្សែសង្វាក់អ្វីទាំងអស់» ។ យើងឃើញមានលិខិតតូចមួយទៀតសរសេរថា «ចេញមិនច្បាស់បញ្ជូនទៅអង្គាម» ។ គ្រាន់តែឃើញឃ្លានេះក៏អាចបង្ហាញ និងដឹងថាពួកខ្មែរក្រហមសាហាវឃោរឃៅប៉ុណ្ណាទៅហើយ ព្រោះថាពាក្យ«អង្គាម» គឺត្រូវបានប្រើសម្រាប់សត្វឆ្កែដែលវាប្រឹងអង្គាមឆ្អឹងរហូតទាល់តែនៅសល់តែឆ្អឹងសសុះ ។ តាមពិសោធន៍ជាច្រើនឆ្នាំក្នុងកិច្ចការស្រាវជ្រាវអំពីឧក្រិដ្ឋកម្មរបស់របបខ្មែរក្រហម ពាក្យថា «បញ្ជូនទៅអង្គាម» ទំនងជាជនរងគ្រោះ ប្រី ស្រីត ត្រូវបានទទួលការសួរចម្លើយតាមរបៀបព្រៃផ្សៃជាច្រើនលើកច្រើនសារមុននឹងត្រូវបានពួកខ្មែរក្រហមសម្លាប់ចោល ។ ប្រី ស្រីត ធ្លាប់ធ្វើជាប្រធានសហករណ៍ភូមិសុខសាន្ត ស្រុកអូររាំង តំបន់១០៥ដែលកាលជំនាន់នោះមាន ប៉ៃ ជាប្រធានស្រុក និងឈ្មោះ ឡាំង ជាលេខាតំបន់ ។

យោងតាមឯកសារទូរសាររបស់ពួកខ្មែរក្រហមដែលមានតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ជាញឹកញាប់ណាស់ដែលឈ្មោះ ឡាំង បានរាយការណ៍ជាលាយលក្ខណ៍អក្សរទៅថ្នាក់លើដែលត្រូវបានស្គាល់ថា ថ្នាក់មជ្ឈិមតាមរយៈវិទ្យុទាក់ទងពីបញ្ហាផ្សេងៗដែលរបាយការណ៍ទាំងនេះតែងចម្លងជូនដល់ នួន ជា ។

ប្រី ស្រីត បានស្លាប់ដោយពុំបានបន្សល់ទុកពាក្យផ្តាំផ្ញើអ្វីសោះឡើយ ដល់ក្រុមគ្រួសារ ។ ស្រីត ភឿន ជាកូន ដែលបានឃើញព្រឹត្តិការណ៍ចាប់ឪពុករបស់ខ្លួនផ្ទាល់ភ្នែក បាននិយាយថា «ឪពុករបស់ខ្លួនមិនបានផ្តាំផ្ញើអ្វីទេ» ពេលដែលពួកខ្មែរក្រហមចាប់យកទៅដោយនិយាយរបៀបអ្នកស្រុកលើថា *«មានផ្តាំឯណា ដៃគេចងអញ្ចេះនោះ កាំភ្លើងភ្ជង់អញ្ចេះ ដើរចង្អុកអញ្ចេះ ខ្ញុំដឹងតែម្តង ឃើញនឹងភ្នែក»* ។

**ទ៉ាន់ថាន់ ពៅដារ៉ា**

# ម៉ៅ ជឿន ហៅ លី ត្រូវធ្វើទារុណកម្មបង្ខំឱ្យឆ្លើយ

ម៉ៅ ជឿន ហៅ លី មានអាយុ៣៣ឆ្នាំ ស្រុកកំណើតនៅកោះពាមប្រស្នា ស្រុកស៊ីធរត្រង់ តំបន់៤២ ភូមិភាគខត្តរ ដែលអ្នកស្រាវជ្រាវបរទេសបានហៅថាជាភូមិភាគកណ្តាលទៅវិញ ។ មុនចូលបដិវត្តន៍គាត់គឺជាអ្នកស៊ីឈ្នួលដឹកអង្ករឲ្យមេឃុំម្នាក់ឈ្មោះ លី ។ តាមរយៈការដឹកនាំពីមេឃុំ លី គាត់(ជឿន) បានធ្វើជាប្រធានភ័ស្តុភារកងពល លេខ១៧៤ ភូមិភាគកណ្តាល ។ ក្រោមការដឹកនាំរបស់ សី និង រៀប ជឿន បានទទួលភារកិច្ចឲ្យធ្វើសកម្មភាពយ៉ាងច្រើនរហូតដល់យប់ថ្ងៃទី១៧ ខែ៩ ឆ្នាំ១៩៧៧ ត្រូវអង្គការចាប់ខ្លួនដោយចោទថាក្បត់បដិវត្តន៍ ។ ជនរងគ្រោះរូបនេះត្រូវបានសន្តិសុខគុក ធ្វើទារុណកម្មសួរចម្លើយបីលើកឲ្យសារភាពពីប្រវត្តិសកម្មភាពខ្លួនរហូតដល់ពេលចាប់ ។

ខាងក្រោមនេះ ជាសេចក្តីសង្ខេបចម្លើយរបស់ ជឿន ដែលបានសារភាព ។

ម៉ៅ ជឿន ហៅ លី បានសារភាពថាកាលពីអាយុ ១៨ឆ្នាំគាត់បានរៀននៅសាលាវត្តពាមកោះស្នា ។ អាយុ១៩ឆ្នាំ បានរៀននៅបឋមសិក្សាពាមកោះស្នា ។ ឆ្នាំ១៩៦២ ឈប់រៀននៅជាមួយឪពុកម្តាយធ្វើស្រែ ។

នៅឆ្នាំ១៩៦៣ គាត់មកស៊ីឈ្នួលព្រៃចម្ការក្រូចក្នុងចម្ការកៅស៊ូបឹងកេត ។ គាត់តែងតែខស្សាហ៍ដើរលេងនៅចម្ការកៅស៊ូរហូតដល់ មេឃុំ លី ស្គាល់យ៉ាងជិតស្និទ្ធ។ ឆ្នាំ១៩៦៥ មេឃុំលី នៅពាមកោះស្នា (ចម្លើយលើកទី១ ជឿន និយាយថាចាប់ទាក់ទងជាមួយមេឃុំលី នៅឆ្នាំ១៩៦៨) ចាប់ផ្តើមអប់រំលើកស្ទួយ, ដើរបញ្ចុះបញ្ចូលធ្វើជាអាណិតមិនចង់ឲ្យធ្វើជាគូលី ចង់ឲ្យមានមុខមានមាត់មានប្រាក់ខែចាយមិនខ្វះ មិនពិបាកដូចធ្វើជាគូលី ។ មេឃុំ លី ក៏ចាត់តាំងឲ្យធ្វើជាភ្នាក់ងារគិញក្នុងឆ្នាំ១៩៦៩ តែម្តង សុង, រ៉េត, ឈើន, លី, ក៏បានតែងតាំងដែរ ។ ភារកិច្ចគិញពេលនោះគឺយកការណ៍ពីបដិវត្តន៍ទៅឲ្យ លី បានពីរជងអប់រំប្រជាជនឲ្យខ្លាចខ្មែរក្រហម និងកសាងកម្លាំងគិញ ។ តាមការចាត់តាំង មេឃុំលី និងគ្រូឈនបានមកទាក់ទង រឿម មេសហករណ៍ហឿងនិង ពុល ធ្វើសកម្មភាពតាមដានខ្មែរក្រហមនៅក្នុងឃុំពាមកោះស្នា ។ ឆ្នាំ១៩៦៧ តាមការខទ្ទេសនាមពី ពុល ឲ្យមកទំនាក់ទំនងជាមួយ ជន ជាជំនួយការភ័ស្តុភារកងពល១៧៤ ។

ឆ្នាំ១៩៦៩ មេឃុំ លី បានឲ្យមកទាក់ទងជាមួយខ្មែរ



សមមិត្តសុខ និរសារបស់ឌុច

សេ-អ៊ី-អា របស់ខ្លួនសម្រាប់ធ្វើការបំផ្លាញបដិវត្តន៍មាន សុង, ឈិន និង វ៉េត ។ ឆ្នាំ១៩៧០ មេឃុំលី ចាត់តាំង ដន, ពុល និង ជឿន ទៅទំនាក់ទំនងជាមួយនារី ស៊ីម ដើម្បីចូលបង្កប់ក្នុងជួរបដិវត្តនៅអង្គភាពឃុំពាមកោះស្នា ។ ជឿន ត្រូវបង្កប់ក្នុងអង្គភាពចល័តភូមិភាគឧត្តររបស់ ឈិន ។ ក្រោយមកសមមិត្ត កែពក បានដកជឿន និងហឿង ទៅនៅជាមួយគាត់នៅមន្ទីរក២ ហើយការទាក់ទងជាមួយខ្សែក៏ត្រូវដាច់មួយរយៈ ។ សកម្មភាពរបស់ជឿន នៅទីនោះគឺ បំផុសយុវជនឲ្យសេរីបំផ្លាញអង្ករខូចអស់៧០បាវ ។ ចុងឆ្នាំ១៩៧១ បានផ្លាស់ទៅមន្ទីរទោចឃំ ស្រុកជីក្រែង ខេត្តសៀមរាប ដើម្បីភ្ជាប់ជាមួយខ្សែ សាន់ ហាវ ជាជំនួយការសេដ្ឋកិច្ចតំបន់៤៣ ។ ហាវ អប់រំអំពីការធ្វើបដិវត្តន៍យ៉ាងច្រើន មុនពេលដឹងថា ជឿន ជាសេ.អ៊ី.អា ។ នៅខែ៦ ឆ្នាំ១៩៧១ ជឿន កសាងបានកម្លាំង៥នាក់ ហើយធ្វើជាអ្នកយាមឃ្លាំងអំបិល ឃ្លាំងស្រូវនៅទីនោះ តែមិនយកចិត្តទុកដាក់ បណ្តោលឲ្យខូចស្រូវអង្ករអស់ពាក់កណ្តាល ។



ឆ្នាំ១៩៧២ ជឿន ផ្លាស់មកនៅមន្ទីរជ.៧ ។ អង្គការចាត់តាំងទៅជាអនុប្រធានមន្ទីរយោធាភាគឧត្តរភ្ជាប់ខ្សែរយៈជាមួយ សី សម្រាប់ធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ជាមួយគ្នា ។ ក្រោយមកបន្តទាក់ទងជាមួយមនុស្សពីរនាក់ទៀតជាខ្សែរបស់ឈ្មោះ ឈុន និង ហឿង ។ ហឿង បានបញ្ចូលជាសេ.អ៊ី.អា ពេលបញ្ចូលរួចចូលរួមប្រជុំនៅផ្សារស្រែវាល ។ ខ្លឹមសារនៃអង្គប្រជុំនោះគឺវាយដកសមរភូមិធ្វើយ៉ាងណាកុំឲ្យឈ្នះខ្មាំងបាញ់គ្រាប់កាំភ្លើងរបស់អង្គការចោល ។ ពេលទទួលផែនការហើយ ជឿន និងលន បានយកកាំភ្លើងជ័យភណ្ឌដាក់ហាលភ្លៀងបណ្តោលឲ្យខូចនិងបែកបាក់អស់ ។

ខែ៩ ឆ្នាំ១៩៧៤ នៅសមរភូមិសៀមរាបជាមួយ សី ជឿន បានកសាងបានកម្លាំងពីរនាក់ ខ្លឹមសារអប់រំនៅនោះគឺសួរពីប្រវត្តិធ្វើបដិវត្តន៍ ហើយលើកឡើងពីមុខមាត់ បុណ្យសក្តិប្រាក់ខែនឹងប្រៀបធៀបការរស់នៅពីសង្គមចាស់សប្បាយហ៊ឺហា ឯការធ្វើបដិវត្តន៍ទៅអនាគតគឺវេទនា ។ នៅមន្ទីរភស្តុភារតំបន់ ៤៥-៤៦ មានការប្រជុំមួយចូលរួមដោយ សី, សំ, លីម, ស៊ុន និងភន, ប៉ែត, ដួង, ហោះ ឈ្មោះទាំងបួននេះត្រូវអង្គការចាប់ហើយ ។ ពេលនោះ សី បានលើកផែនការប្រជុំថា បើអង្គការវាយបែកខាងសៀមរាប ត្រូវប្រមូលទ័ពទាំងអស់រត់ចូលខ្មាំងនៅខេត្តឧត្តរមានជ័យ បើបដិវត្តន៍វាយមិនឈ្នះ ត្រូវវាយដកៗធ្វើម៉េចកុំឲ្យខ្មាំងឈ្នះ ។ ក្នុងឆ្នាំ ១៩៧៤ នៅមុខសញ្ញាកងតំបន់៤៥-៤៦ ដាក់ស្តែង ខែ១២ ឆ្នាំ១៩៧៤ ជាមួយមិត្តសី, លីម, ស៊ុន, ភន, ប៉ែត, ដួង, ហោះ បានបញ្ឈកងទ័ពទាំងអស់ដែលនៅការពារអង្គរវត្តដកមកខាងក្រោយ ។

ឆ្នាំ១៩៧៥ ជឿន ត្រូវអង្គការណែនាំឲ្យដឹកអង្ករទៅដាក់ឃ្លាំងដាក់អាវុធនៅមន្ទីរបន្ទាយសំរ៉ែចាស់ដើម្បីប្រមូលអាវុធ ពីក្រុងសៀមរាបទៅទុក រួចក៏ទៅពិភាក្សាជាមួយ សី លើផែនការបំផ្លាញអាវុធនិងគ្រាប់ទាំងនេះដាក់ហាលភ្លៀងទម្រាំតែឃ្លាំងនោះធ្វើហើយ ដែលអាចឲ្យអាវុធខូចបានមួយចំនួនធំ ។ អនុវត្តបានតាមផែនការពេលរើដាក់ឃ្លាំងទៅឃើញខូចកាំភ្លើង

អស់ ១ពាន់ដើមនិងថ្នាំពេទ្យ២ឡាន ។ នៅទីនោះ ជឿន កសាងបានកម្លាំងពីរនាក់ទៀត ។ នៅខែ២ ឆ្នាំ១៩៧៥ ពេលនៅសមរភូមិ ក្រុងសៀមរាបជឿន ឲ្យបញ្ឈប់ការដកទ័ពចោលសមរភូមិសៀមរាបធ្វើជាឲ្យទាហានសៀមរាបទៅចាប់ពួកនៅកំពង់ធំវិញ ។

ក្រោយថ្ងៃរំដោះក្រុងភ្នំពេញ ខែ៤ឆ្នាំ ១៩៧៥ ជឿននិងសី បានមកជួបខ្មែរនៅកំពង់ចាមវិញ ។ ជឿន ត្រូវអង្គការប្រកាសចាត់តាំងជាជំនួយការកងពល១១៧ ដែលមាន សី ជាលេខាកងពល ។ ចាត់តាំងរួចហើយក៏នាំគ្នាទៅប្រជុំនៅជិតវត្តជ្រោយថ្ម ដើម្បីខឹទ្ទេសនាមឲ្យស្គាល់គ្នានិងផែនការកសាងកម្លាំង,ត្រៀមធ្វើរដ្ឋប្រហារកម្ទេចកម្លាំងកម្មាភិបាលសំខាន់ៗរបស់បដិវត្តន៍ ។ សី ចាត់ឲ្យដើរប្រមូលកាំភ្លើងពីកំពង់ចាមនិងកំពង់ធំទុកក្នុងឃ្លាំងកំពង់ចាម ចំណែកអាវុធដែលនៅសេសសល់រាយការណ៍មកអង្គការ ។ បន្ទាប់ពីរាយការណ៍ហើយ សី បាន ហៅ ហោះ ,ខាន់, វើង, ស៊ុម, ផែន មកប្រជុំសម្រេចយក យុវជន៦នាក់ក្នុងវរសេនាតូចដែលកសាងបានមកឲ្យទទួលខុសត្រូវអាវុធនិងគ្រាប់ទាំងនេះយកមកប្រើប្រាស់បម្រើផែនការអ៊ីមួយមិនឲ្យបែកការណ៍ ។ ក្នុងខែ៨ មានប្រជុំលើកផែនការចាស់រៀបចំគម្រោងចាំស្ទាក់បាញ់កម្មាភិបាលបដិវត្តន៍ បួនយកឡានដឹកអង្ករថ្នាំពេទ្យដើម្បីទុកស្បៀងនេះបម្រើការផែនការធ្វើរដ្ឋប្រហារក្នុងពេលខាងមុខ ។ ខែ៩ ឆ្នាំ១៩៧៥ ខ្មែរចាស់ និងខ្មែរថ្មីបានមកប្រជុំខេត្តកំពង់ចាមដើម្បីរៀបចំចែកមុខសញ្ញាជាពីរផ្នែកក្នុងផែនការធ្វើរដ្ឋប្រហារក្នុង ឆ្នាំ១៩៧៥ ។ ផ្នែកទី១ ខាន់ និងហោះទទួលមុខសញ្ញាទៅវាយខេត្តកំពង់ធំ ផ្នែកទី២ ជឿន, ស៊ុម, វើង, ផែនទទួលមុខសញ្ញាវាយក្រុងកំពង់ចាម ប៉ុន្តែផែនការនេះមិនសម្រេចវិញ ។ នៅបន្ទាយសារិបក៏មានការប្រជុំដែរ សី បាននិយាយក្នុងពេលប្រជុំនេះថា ដើម្បីត្រៀមកម្លាំងបានទាល់តែកសាងកម្លាំងក្នុងវរសេនាធំឲ្យបាន ៣០នាក់ ព្រោះបច្ចុប្បន្នអង្គការកំពុងត្រូវការកម្លាំង ។ យើងត្រូវបញ្ជូនកម្លាំងប្រឆាំងបដិវត្តន៍របស់យើងទៅឲ្យអង្គការ ជាឱកាសមួយក្នុងការធ្វើសកម្មភាពជាមួយពួកចោរព្រៃ ។ ទំរាំចាំបានកម្លាំងហើយ យើងរៀបចំផែនការឲ្យទៅបំផ្លាញសម្ភារៈរបស់បក្សតាមគ្រប់មុខសញ្ញាទាំងអស់ ។

រហូតដល់ ខែ១ឆ្នាំ១៩៧៦ ជឿន នាំនារីនិងយុវជនមួយចំនួននៅអង្គភាពភស្តុភារកងពល១៧៧ ភ្ជាប់ជាមួយខ្មែររបស់ខ្លួន ។ ក្រោយមកបានចូលរួមប្រជុំជាមួយ សី អំពីបញ្ហាដែលអង្គការត្រូវចាត់តាំងឲ្យធ្វើសង្គ្រាមជាមួយពួកព្រៃនៅតំបន់៤១-៤២ ។ សី បាននិយាយថាយើងត្រូវទៅតែមិនចាប់ចោរព្រៃទេ យើងរឹតតែបង្កើនចោរព្រៃថែមទៀត ។ ដូច្នេះតំបន់៤១ ស៊ុម មានភារកិច្ចជាអ្នកដឹកនាំចាប់ពីចំណុចត្រើងរហូតដល់ស្គន់ ។ ដោយឡែក ជឿន ជាអ្នកដឹកស្បៀងទៅធ្វើសកម្មភាពនៅតំបន់៤២វិញ យកកម្លាំង៧នាក់ទៅបង្កប់ធ្វើសកម្មភាព ចាប់ពីចំណុចត្រើងដល់ស្ទឹងត្រង់ ។ ពេលទៅដល់ឈប់ធ្វើសកម្មភាព ជឿន, ស៊ុម, លឿន, ញ៉ក់, រៀម, លី, សេវ, រ៉ន់ និងភាព ទៅលួចអង្ករនៅសហករណ៍ថ្ពូន ព្រៃឈរ និងផ្អាវ ខេត្តកំពង់ចាមបាញ់គណៈឃុំផ្អាវបាក់ជើង ។ ខែ១២ សី បានប្រជុំលើកផែនការធ្វើរដ្ឋប្រហារទៅ ខែ៤ឆ្នាំ ១៩៧៦ វិញគឺក្នុងពេលដែលបក្សកំពុងធ្វើបុណ្យខួបជ័យជំនះ ។

ចាប់ពីខែ២ដល់ខែ៣ ឆ្នាំ១៩៧៦ ផែន ខឹទ្ទេសនាមកម្លាំងសេ.អ៊ី.អា ម្នាក់ឈ្មោះ ចក់ ដែលទទួលភារកិច្ចធ្វើឲ្យកាំភ្លើងដែលជួសជុលរួចឲ្យរអាក់រអួលប្រើការមិនកើតនិងជាអ្នកទទួលធ្វើគ្រាប់បែកជាពីរផ្នែក ផ្នែកម្ខាងមានគុណភាពល្អ ម្ខាងទៀតលាយដីខ្សាច់និងរំសេវ ។ ពេលនោះ ជឿន ត្រូវមកទាក់ទងណែនាំ អុននិងនុន ឲ្យធ្វើសកម្មភាពទៅបំផុសប្រជាជនឲ្យប្រឆាំងនិងបង្កប់កម្លាំងក្នុងសហករណ៍, មិនបើកសម្ភារៈឲ្យប្រជាជនប្រើប្រាស់ ដើម្បីឲ្យប្រជាជនមានទំនាស់ជាមួយអង្គការ ។ អុន និង នុន បានយកផែនការរបស់ ជឿន ទៅផ្សព្វផ្សាយដល់ប្រជាជននៅឃុំមាគនិងឃុំព្រះ ឲ្យទំនាស់នឹងបដិវត្តន៍ដោយលើកហេតុផលផ្សេងៗថា ការចូលសហករណ៍គឺការរស់នៅជាសមូហភាពស៊ីចុក ជារួមខ្វះតាំងពីស្បៀងមិនដូចសង្គមចាស់ទេ ដែលរស់នៅជារបបឯកជនការហូបចុកស្លៀកពាក់ក៏សម្បូរ ។ ខែ៤ឆ្នាំ១៩៧៦ សី ហៅឲ្យចូលរួមប្រជុំនៅជាយក្រុងកំពង់ចាមមានអ្នកចូលរួម២៤នាក់ មួយចំនួនត្រូវបានចាប់ខ្លួនហើយ សី បាននិយាយថាខ្មាំងក្នុងប្រទេសចាប់ផ្តើមធ្វើសកម្មភាពខ្លាំងហើយ ដូច្នេះដើម្បីឲ្យសមនឹងសភាពការណ៍ខាងក្នុងនិងក្រៅយើងត្រូវតែបន្តសកម្មភាពធ្វើរដ្ឋប្រហារវាយបក្សនៅ ថ្ងៃទី១៧-ខែ១០ឆ្នាំ១៩៧៧ ។ មុខសញ្ញាដែលត្រូវវាយគឺយកកំពង់ធំ និង

កំពង់ចាមឲ្យបានពិសេសក្រុងកំពង់ចាម ហើយកម្ទេចកន្លែងអង្គការភូមិភាគឧត្តរ ។ ពេលវាយបែកហើយត្រូវទុកកងតំបន់៤១ នៅការពារកំពង់ចាម កងតំបន់៤២ ការពារនៅកំពង់ធំ សល់ប៉ុន្មានពិនិត្យសភាពការណ៍ រួចឆ្លងព្រែកក្តាមទៅវាយក្រុងភ្នំពេញទៀត ។ មួយក្រុមទៀតត្រូវអប់រំប្រជាជនក្នុងតំបន់៤១-៤២ ឲ្យកម្ទេចរបបសមូហភាពរៀបចំរបបឯកជនឡើងវិញ ។ សី បញ្ជាក់ទៀតថា ពីមុនយើងអាងលើ ស្រេង និង គុល ជាបង្អែកហើយ អឿន នៅភ្នំពេញចាំទទួលយើង ចុះបើទាំងបីនាក់នេះត្រូវអង្គការចាប់ខ្លួនបាត់ទៅហើយ តើយើងគិតយ៉ាងម៉េចក្នុងពេលនោះ ។ មិត្ត រៀប មានយោបល់ថា បើមានសាឡាងឬទូកឆ្លងទៅយើងទៅវាយភ្នំពេញទៀត តែបើមិនមានត្រូវរៀបចំកម្លាំងនៅតាមផ្លូវជាតិលេខ៧ ដើម្បីរកវិធីវាយបន្តអាចការពារដីបានផង ប្រសិនបើទប់មិនជាប់ យើងដកទ័ពទៅបង្កប់ក្នុងព្រៃសំរោងតំបន់ ៤២ ដល់ព្រះវិហារ តែបើបដិវត្តន៍នៅតែវាយយើងទាក់ទងថៃឲ្យជួយសុំដីថៃនៅ ។ ប្រហែលជាបីខែក្រោយ សី ត្រូវអង្គការចាប់ខ្លួន ។ មិត្តរៀប ចាប់ទទួលផែនការនេះវិញ ។ ឯ ជឿន ត្រូវអង្គការចាត់ជាប្រធានភ័ស្តុភារកងពល១៧៤ជាប្រជាជនតំបន់៤២ ។ ជឿនបានទៅសហការជាមួយ ផែន, ដួង, រាប, អ៊ិន, ចន ពិភាក្សារកវិធីធ្វើសកម្មភាពបំផុសប្រជាជននិងកងទ័ពឲ្យចលនាលើកទំនប់ឃឹតយ៉ាវ រហូតមិនសម្រេចតាមផែនការកំណត់ ។ ចំណែកជឿន និងឈ្មោះ សួ បានសហការគ្នាផ្សព្វផ្សាយផែនការនេះបន្តទៀតដល់ប្រជាជនក្នុងឃុំព្រែកប្រសព្វ ត្រឡប់មកវិញទៅរុះផ្ទះថ្មីធ្វើជាអុសដុតបំផ្លាញតែផ្ទះចាស់ៗឲ្យអង្គការវិញ ស្របពេលធ្វើសកម្មភាពនេះ ជឿន និងសី, វើង, ស៊ឹម អប់រំបានមនុស្សពីរនាក់ដែលក្នុងនោះមានម្នាក់ជាប្រធានភ័ស្តុភារកងពល១៧៤ ។ វើង, វ៉ា, សុខ, កើន, ញ ចាត់កម្លាំងនាំយុវជន សេ.អ៊ី.អា មួយក្រុមទៅបំផ្លាញដំណាំប្រជាជនអស់ប្រហែល១ហិកតា ។ ប្រហែលក្នុងរវាងខែ៨ ឬខែ៩ ត្រូវបានអង្គការចាត់តាំងឲ្យទៅកាប់ឈើនៅឯស្រុកសណ្តាន់ ពេលនោះម្នាក់ឈ្មោះ សុខ ត្រូវបញ្ជាឲ្យនាំខ្មែររបស់ខ្លួនទៅអុកឡុកបាញ់បង្អើលប្លន់ទ្រព្យសម្បត្តិប្រជាជនបោះចោលក្នុងព្រៃដើម្បីឲ្យប្រជាជនអស់ជំនឿលើបក្ស ។

ចូលមកដល់ខែ១០ មានការប្រជុំម្តងទៀតគឺផែនការកម្ទេចកម្មាភិបាលភូមិភាគកណ្តាលនៅតាមផ្លូវ បន្ទាប់ពីផែនការធ្វើរដ្ឋប្រហារត្រូវបរាជ័យជាបន្តបន្ទាប់ ។

ខែ២ ឆ្នាំ១៩៧៧ ជឿន ត្រូវទទួលភារកិច្ចដឹកជញ្ជូនស្រូវនៅខេត្តកំពង់ធំ ។ ក្រោយពីមានការពិភាក្សារួចបានសម្រេចឲ្យមិត្តពេញ និងកម្លាំងជាច្រើនទៀតដឹកស្រូវរបស់អង្គការយកទៅលាក់ទុកដើម្បីត្រៀមធ្វើផែនការខែ៤-១៩៧៧ ។ មិត្តជឿន និងជុំ បានសហការគ្នាយកផែនការចាស់ៗទៅបំផុសប្រជាជនឃុំមាត ស្រុកស្ទឹងត្រង់ អស់រយៈពេល២ថ្ងៃទើបត្រឡប់មកកន្លែងវិញ ។ ខែ៧ ជឿន កសាងកម្លាំង១១នាក់ ភាគច្រើនជាយុទ្ធជនការពារឃ្លាំងកងពល១៧៤ ។ បន្ទាប់ពីកសាងបានកម្លាំងហើយ រៀបហៅមិត្តទាំងអស់មកប្រជុំនៅមន្ទីរវរសេនាធំ៦០១ ជិតភ្នំប្រុសភ្នំស្រី មានអ្នកចូលរួម២៣នាក់ ។ ការប្រជុំនេះគ្រាន់តែរំឭកពីផែនការចាស់របស់ សី ប៉ុណ្ណោះ ។ រៀប និយាយថាបន្ទាប់ពីក្បាលម៉ាស៊ីនធំៗត្រូវបានបោសសម្អាតហើយ យើងត្រូវបន្តផែនការវាយយកកំពង់ធំ កំពង់ចាម ឲ្យបានសម្រេច ។ មុខសញ្ញាដែលត្រូវវាយទី១ គឺខេត្តកំពង់ចាមដែលមានវរសេនាតូច៧០១ ការពារដល់ជាយក្រុង ខាងជើងភ្នំប្រុសភ្នំស្រីមាន ឈាន, សួត, ធាន ជាអ្នកបញ្ជា ។ វរសេនាតូច៧០៥បញ្ជា ដោយ អ៊ិន និង សេរ មានភារកិច្ចការពារផ្លូវមាត់ទន្លេខាងកើតក្រុង ។ វរសេនាតូច៧០៣មាន ភន, ឈិត និងវ៉ន មានភារកិច្ចវាយសម្រុកចូលក្រុងកំពង់ចាម, វរសេនាតូចលេខ៧០២ វាយសម្រុកចេញពីដើមចាន់វាយចូលពីខាងត្បូងមាន កុល, វឿន, អាល ។ វរសេនាតូច៧០៤ វាយសម្រុកចេញពីវត្តថ្មីចូលកំពង់ចាម និងវរសេនាតូច៩០១វាយកាំភ្លើងពីវត្តអង្គរចូលកំពង់ចាម ។ ទី២ គឺខេត្តកំពង់ធំ ដែលមានវរសេនាតូច៧០៩ មានភារកិច្ចវាយពីអូរវាយចូលក្រុងកំពង់ធំមាន វ៉ន, អេន, ឡាច, សុង កាន់វរសេនាតូច ៧០៨ ចាំវាយសម្រុកចេញពីវត្តកំពង់ធំ និងកងវរសេនាតូច ៩០២ វាយចេញពីដីរំអូរបាក់ចូលកំពង់ធំ ឆែម ជាអ្នកបញ្ជា ។ ក្នុងរយៈពេលខែ៦-៧នេះ ការធ្វើសកម្មភាពគឺលី គិតតែបំផ្លាញឧបករណ៍ដូចជាម៉ាស៊ីនបូមទឹក ៦គ្រឿង ដោះអំពូលភ្លើងនៅតាមផ្លូវវាយបំបែកចោល ដឹកអង្ករ ថ្នាំពេទ្យឲ្យបក្សពួកនៅក្នុងព្រៃ ។ ខែ៨ក្រោយពីអង្គការចាប់ សី ហើយ លី បន្តផែនការ

ទាក់ទងជាមួយ ចន, វៀប និងសោ ត្រៀមកសាងកម្លាំងបន្ថែម ។ នៅខែ៩ នៅពេលដែលកម្មាភិបាលយោធាក្រសួងនានារៀននៅសាលាភូមិភាគកណ្តាល កំពង់ចាម សោ និងជឿន បានមកពិភាក្សាពីផែនការចាប់ សី និងការធ្វើឃាតមិត្តអាន លេខាតំបន់៤១ ។ ព្រោះបើសម្លាប់ អាន បានសម្រេចអង្គការនឹងចាត់ឲ្យសោ ជំនួសវិញ ដល់ពេលនោះនឹងងាយស្រួលកសាងកម្លាំងប្រឆាំងនឹងបដិវត្តន៍ផង ងាយស្រួលទាក់ទងផង ។ ការធ្វើឃាតនេះត្រូវធ្វើដោយស្ងាត់ៗ និងតាមពេលវេលាច្បាស់លាស់ ។ ប៉ុន្តែផែនការនេះត្រូវបែកការណ៍វិញ ព្រោះមិត្តអានដឹងខ្លួនទាន់ ។ ពាក់កណ្តាលខែ៩ ជឿនចាប់ផ្តើមអនុវត្តផែនការផ្សេងទៀតដោយចាត់មនុស្ស៧នាក់ បឿន, ខុន, នឹង មឿន, កេត, ប៊ុត, និងវុធ ឲ្យយកគ្រាប់បែក២គ្រាប់របស់យន្តហោះស្លាបកាត់ដែលដឹកពីកំពង់ចាមទៅទម្លាក់ ។ បន្ទាប់មកបានចាត់អ្នកទាំង៧នាក់ខាងលើឲ្យយកគ្រាប់បេ៤០មកដោះឆ្នូនយករំសេវ១២០គ្រាប់ទៅព័ទ្ធជុំវិញឆ្នូនបង្កប់នៅជាមួយគ្នាដើម្បីជាជំនួយឲ្យឆេះបានកាន់តែលឿន ។ ចប់ពីផែនការមួយចូលដល់ផែនការមួយទៀត ជឿន បានទទួលបញ្ជាពីវៀបទៅចាត់កម្លាំងក្នុងមន្ទីរភ័ស្តុភារកងពលខាងយាមឃ្លាំងមួយក្រុមឲ្យដុតកម្ទេចឃ្លាំងគ្រាប់និងគ្រាប់មីន ។ មុនទៅអនុវត្ត មិត្តវៀបបាននិយាយថាបើធ្វើក៏ស្លាប់បើមិនធ្វើក៏ស្លាប់ ។ តែបើធ្វើតាមចំណេញ ផែនការយើងផងហើយបើគ្រាប់នោះផ្ទុះត្រូវរាយការណ៍ជូនអង្គការថា គ្រាប់ផ្ទុះនេះបណ្តាលមកពីយន្តហោះទម្លាក់ដូចនៅសៀមរាប ឬក៏ថាមកពីរើឃ្លាំងទៅគ្រាប់ប៉ះទង្គិចគ្នាផ្ទុះតែម្តង ។ បើអង្គការលែងទុកចិត្តមិត្តថាការពារលែងបាន ដល់អង្គការលែងជឿគឺត្រឹមតែមិត្តម្នាក់ ។ ឯអាវុធក្នុងឃ្លាំងអង្គការច្បាស់ជាប្រគល់ឲ្យកងទ័ពគ្រប់គ្រងម្តង ពេលនោះយើងមានលទ្ធភាពច្រើនក្នុងការវាយបក្ស ហើយការកម្ទេចឃ្លាំងគ្រាប់នេះ ត្រូវការមនុស្សប្រាំនាក់ធ្វើដោយស្របច្បាប់ទើបបាន ដល់ពេលនោះរាយការណ៍ជូនអង្គការថា ប្រាំនាក់នេះពេលគ្រាប់ផ្ទុះហើយបាត់ខ្លួនតែម្តង ។ តែការពិតយើងយកប្រាំនាក់នេះទៅលាក់នៅកន្លែងរ៉េន វរសេនាតូច៧០៩ វរសេនាធំ៦០២ បើលាក់មិនជិតសឹមបញ្ជូនអ្នកទាំងប្រាំទៅស្រុកកំណើតវិញ រាយការណ៍ទៅមូលដ្ឋានថាមិត្តទាំង៥នេះមានសមាសភាពមិនល្អ ។ នៅល្ងាចថ្ងៃទី១៤ ខែ៩ ឆ្នាំ១៩៧៧ ជឿន មកជួប បឿន, នឹងនៅមន្ទីរពីរឿងខាងលើ ។ បឿន និង នឹង បានបដិសេធថា ខ្លួនមិនអាចធ្វើបានព្រោះគ្មានជំនាញខាងណឹង ។ ប៉ុន្តែនៅមាន បុត, វុធ, ខុន, មឿន, កេត មានបច្ចេកទេសខាងគ្រាប់អាចធ្វើបាន ។ ជឿនបានទៅជួបសម្រេចកិច្ចការនេះ ។ ដល់ថ្ងៃទី១៥ ឈ្មោះទាំងប្រាំខាងលើនេះបានយកមីនក្លេម័រប្រហែលជា៤០០គ្រាប់ទៅវាយយករំសេវនៅចន្លោះឃ្លាំងគ្រាប់បែកនិងគ្រាប់មីនអស់ពីរថ្ងៃ ។ ព្រឹកថ្ងៃទី១៧ ទើបយករំសេវក្លេម័រនេះទៅរៀបដាក់នៅកណ្តាលឃ្លាំងរួចយកគ្រាប់បែក និងគ្រាប់មីនគ្របពីលើ ។ រៀបចំហើយជឿនបានចាកចេញពីកន្លែងនោះទៅ មើលមិត្តយើងរើផ្ទុះនៅជិតកងពល១៧៤ ។ ប្រហែលជាម៉ោង៤ល្ងាច ស្រាប់តែឃ្លាំងផ្ទុះត្រូវឆេះអស់ប្រាំនាក់នោះក៏រត់បាត់ ។ លុះម៉ោង៥ លីក៏ទៅរាយការណ៍ប្រាប់អង្គការភូមិភាគកណ្តាល (បងពក ឬកែពក) ពីមូលហេតុដែលនាំឲ្យឃ្លាំងឆេះ និងការបាត់ខ្លួនអ្នកទាំង៥ រួចត្រឡប់មកកន្លែងដើមវិញ ។ ដល់យប់បន្តិច អង្គការបានមកចាប់ខ្លួន ជឿន យកទៅឃុំទុករង់ចាំការសួរចម្លើយ ។

អត្ថបទនេះបានសង្ខេបចេញពីឯកសារ J000៧៤បបគខ មានចំនួន៧២ទំព័រ ។ ការសួរចម្លើយលើទីមួយនៅថ្ងៃទី២៤-៩-៧៧ និងចម្លើយលើកទីពីរ ថ្ងៃទី២៧-៩-៧៧ សួរដោយឡា និងឡាក់ ក្នុងចម្លើយលើកទី១នេះ មានបញ្ជីឈ្មោះបក្សពួក៧៣នាក់ ក្នុងនោះមាន ២២នាក់ត្រូវ បានចាប់ខ្លួនហើយក្នុងចម្លើយលើកទីពីរមានចំណារមួយសរសេរថា **«ជូនអង្គការ២ច្បាប់ ១-១០-៧៧»** ចម្លើយលើកទីបីត្រូវបានសួរដោយ វុធ, រ៉ានិងនី ថ្ងៃទី២៨-១០-៧៧ ដែលនៅលើកំណាត់ហេតុក៏មានចំណារមួយសរសេរថា **«ភូមិភាគកណ្តាល ជូនបង នួន ២ច្បាប់ហើយថ្ងៃទី១០-១១-៧៧»** ។ ក្នុងនោះមានសេចក្តីបញ្ជាក់សរុបចម្លើយរបស់អ្នកសួរបានសរសេរថា **«ដំបូងខ្ញុំសួរអំពីប្រវត្តិរបស់វាពីមុននិងមជ្ឈដ្ឋានរស់នៅពីមុន ក្រោយមកទើបខ្ញុំធ្វើទារុណកម្មវាហើយវាក៏និយាយពីរឿងក្បត់របស់វាជាខ្មែរសផ្ទាក់ខ្មែរគិញនិង សេ.អ៊ី.អារហូតដល់អង្គការចាប់វា»** ។ បញ្ជីឈ្មោះក្នុងចម្លើយទីបីនេះមានរាយឈ្មោះបក្សពួក៧១នាក់ដែលអង្គការតាមដានចាប់ ។

សុផល




នួន ជា មានឈ្មោះដើមហៅថា ឡុង រិទ្ធិ ។ ជាទូទៅនៅក្នុងរបបខ្មែរក្រហមគាត់ត្រូវបានកម្មាភិបាលដទៃទៀតហៅថា បងនួន ឬអ៊ំនួន ។ ខ្លះទៀតបានហៅគាត់ថា «តាប្រហុក» ដោយសារគាត់ជាមនុស្សចូលចិត្តប្រហុក ។ មកទល់នឹងពេលនេះហាក់ដូចជាពុំទាន់មាននរណាម្នាក់ដឹងអំពីថ្ងៃខែឆ្នាំកំណើតនួន ជា ច្បាស់លាស់នៅឡើយទេ ។ប៉ុន្តែជាទូទៅដឹងថាគាត់ជាអ្នកស្រុកបាត់ដំបងហើយធ្លាប់បានសិក្សានៅមហាវិទ្យាល័យធម្មសាធនៅក្រុងបាងកកប្រទេសថៃក្នុងឆ្នាំ១៩៤៥ ។ នៅបាងកក នួន ជា បានចូលជាសមាជិកបក្សកុម្មុយនិស្តថៃ ។នៅឆ្នាំ ១៩៥១ នួន ជា ធ្លាប់មានតំណែងជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការសេដ្ឋកិច្ចនៅរណសិរ្សរួបរួមឥស្សរៈ ហើយឆ្នាំ១៩៥៤បានទៅធ្វើកម្មសិក្សានៅហាណូយ ប្រទេសវៀតណាម ។ ឯកសារមួយចំនួនបានឲ្យសេចក្តីសន្និដ្ឋានថា នួន ជា បានទទួលតំណែងជានាយករដ្ឋមន្ត្រីនៃរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៦ ប៉ុន្តែត្រូវបាន ប៉ុល ពត ដណ្តើមយកវិញនៅខែតុលា ក្នុងឆ្នាំដដែល ។ នួន ជា គឺជាសមាជិកពេញសិទ្ធិនៃគណៈកម្មការមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជា និងគណៈកម្មាធិការអចិន្ត្រៃយ៍ ។ គណៈកម្មាធិការនេះ ហើយដែលបានចេញគោលនយោបាយដឹកនាំរបបខ្មែរក្រហម ហើយដែលបានធ្វើឲ្យមនុស្សរាប់លាននាក់ស្លាប់បាត់បង់ជីវិត ។ ឯកសារជាច្រើនបានបង្ហាញឲ្យឃើញថា គោលនយោបាយដែលបានដាក់ចុះមកថ្នាក់មូលដ្ឋានដើម្បីអនុវត្តត្រូវបានជម្រាប គាំទ្រ និងយល់ព្រមពីគណៈកម្មាធិការទាំងមូល ។ ខ្ញុំសូមជូនឧទាហរណ៍យ៉ាងខ្លីដូចតទៅៈ




◆◆◆ទូរលេខខ្ទង់២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៦ បានសរសេរថា «ជូនបង នួន ជាទីស្នេហានិងរលឹក យើងខ្ញុំបានទទួលទូរលេខរបស់បងហើយ ទាំងខ្លឹមសារ ណែនាំទាំងអស់...ដោយភាតរភាពបដិវត្តយ៉ាងកក់ក្តៅ បំផុត ។ សមមិត្ត ឡាំង» ។ ◆◆◆ កំណត់ហេតុនៃការ ប្រជុំសមមិត្ត គាល់ កងពល២៩០ និងកងពល១៧០ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ វេលាម៉ោង១៦ៈ១៥ បានកត់ត្រាទុកថា «**សមមិត្ត ឌុច មានមតិៈ** ក្រោយ ប្រជុំសមមិត្តសុខ និងគាល់ កងពល១៧០ បានឯកភាព គ្នាត្រូវស្នើយកឈ្មោះ [ចាប់] ២៩នាក់ទៀត ។...ឈ្មោះ ស្នើនេះ គឺស-២១ និងកងពល១៧០ប្រជុំគ្នាសម្រេច ក្រៅពី១១នាក់ ដែលប្រជុំសម្រេចពីថ្ងៃទី១៥ខែកញ្ញា ឈរលើហេតុផលបញ្ជាក់របស់ស-២១ និងកងពល ឃើញសកម្មភាពជាក់ស្តែងជាបន្តបន្ទាប់ព្រមទាំងឈរ លើគោលការណ៍អង្គការកំណត់....អង្គប្រជុំយល់ស្រប សម្រេចយកឈ្មោះទាំង២៩នាក់នេះទៀត ។....ត្រូវធ្វើ តាមពិសោធន៍របស់យើងដែលធ្លាប់យកពួកនេះជាបន្ត បន្ទាប់ធ្វើយ៉ាងម៉េចកុំឲ្យអង្គភាពប្របូកប្របល់ក្តាប់អង្គភាព ឲ្យជាប់ក្នុងដៃ និងរក្សាការសម្ងាត់ឲ្យបានល្អ ។»

◆◆◆ ឯកសារលេខ៣៥៣ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ១៩៧៧ មានចំណារថា «បងនួន គាត់ទទួលមួយច្បាប់ ហើយ ។» ◆◆◆

**ឆាំង យុ**





## សម្លេងពីមន្ទីរ ស-២១
### ខគ្គទី១: ការរកឃើញមន្ទីរ ស-២១
### ដោយសាស្ត្រាចារ្យ ដេវីដ ឆេនល័រ

(**តពីលេខមុន**) ឈ្មោះ ស-២១ ចាប់ផ្តើមឃើញលើឯកសារខ្មែរក្រហមកាលពី ខែកញ្ញា ឆ្នាំ១៩៧៥ ។ ក្នុងរយៈពេល៩ខែបន្ទាប់ពីពេលនោះសេវាសន្តិសុខមានវត្តមានរាយប៉ាយតាមអង្គភាពជាច្រើននៅភ្នំពេញ ដូចជានៅតាខ្មៅជាយក្រុងភ្នំពេញ និងតំបន់២៥ ខាងជើងក្រុងភ្នំពេញ រហូតដល់ ខែឧសភា ឬខែមិថុនា ឆ្នាំ១៩៧៦ ។ នៅចុងឆ្នាំ១៩៧៥ យោងទៅតាមអតីតអ្នកយាមម្នាក់ ឈ្មោះ កុក ស្រស់ ដែលបានផ្តល់បទសម្ភាសន៍ក្នុងឆ្នាំ ១៩៩៧ សន្តិបាល ត្រូវបានដាក់បញ្ចូលឲ្យនៅក្រោមបញ្ជារបស់ កាំង ហ្គិច អៀវ ហៅ ឌុច អតីតគ្រូបង្រៀនម្នាក់ ដែលបានទទួលបន្ទុកកិច្ចការសន្តិសុខនៅក្នុងអ្វីដែលពួកខ្មែរក្រហម ហៅថាភូមិភាគពិសេសស្ថិតនៅខាងជើងក្រុងភ្នំពេញនៅក្នុងអំឡុងសង្គ្រាម ។ ឌុចបានក្លាយជានាយកមន្ទីរស-២១ ទួលស្លែង ចាប់តាំងពីខែ មិថុនា ឆ្នាំ១៩៧៦ ។ ឌុច ជាអ្នកបញ្ជាកិច្ចការមន្ទីរស-២១ រហូតដល់ថ្ងៃដែលកងទ័ពវៀតណាមបានចូលមកដល់ ។

ដោយដឹងអំពីសារៈសំខាន់ផ្នែកប្រវត្តិសាស្ត្រ និងអំពីតម្លៃផ្នែកឃោសនានៃការរកឃើញរបស់ខ្លួន ។ វៀតណាមបានបិទទ្វារមណ្ឌលឧក្រិដ្ឋកម្មនេះ និងសម្អាតមណ្ឌលឧក្រិដ្ឋនេះ ហើយដោយមានការជួយជ្រោមជ្រែងពីបុគ្គលិកកម្ពុជាបានចាប់ផ្តើមពិនិត្យបណ្ណសារដ្ឋានដ៏សន្ធឹកសន្ធាប់របស់គុកទួលស្លែង ។ នៅថ្ងៃទី ២៥ ខែមករា ឆ្នាំ១៩៧៩ អ្នកកាសែតមួយក្រុមមកពីប្រទេសកុម្មុយនិស្ត ត្រូវបានវៀតណាមបញ្ជូនមកកម្ពុជា ដើម្បីយកពត៌មាន និងប្រារព្ធការបង្កើតរដ្ឋាភិបាលកម្ពុជាថ្មីមួយដែលហៅថាសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ អ្នកកាសែតទាំងនេះ គឺជាអ្នកមកទស្សនៈកិច្ចជាផ្លូវការលើកដំបូង ដើម្បីមើលគុកទួលស្លែង ។ លោក ជ័យ សាផុន បានអមដំណើរទស្សនៈកិច្ចរបស់ក្រុមអ្នកកាសែតទាំងនោះទៅកាន់គុកទួលស្លែង ។ អ្នកកាសែតម្នាក់ក្នុងចំណោមអ្នកកាសែតទាំងអស់ដែលជាជនជាតិគុយ បា ឈ្មោះ មីហ្គែល រីវ៉ូ ក្រោយមកបានសរសេរថា «នៅមានស្នាមឈាមនៅលើកម្រាលឥដ្ឋ ។ ក្លិនដ៏អសោចបានជះកាន់តែឈ្ងួលខ្លាំងឡើងជាងពីមុនទៅទៀត ។ រុយក្បាលខៀវរាប់ពាន់រោមបន្ទប់ជិត ។ លោក រីវ៉ូ បានបន្ថែមទៀតថាគាត់បានឃើញឯកសារជាច្រើន «ដែលសរសេរជាភាសាសំស្ក្រឹត» និងសៀវភៅក្រហមតូចរបស់ម៉ៅសេទុង «ជាច្រើន» ក្បាលនៅក្នុងបន្ទប់នៃអ្វីដែលគាត់ហៅថា«ឋាននរក» នោះ ។

ក្រោយមក នៅខែកុម្ភៈ ឬមីនា ឆ្នាំ១៩៧៩ (ការចងចាំរបស់គាត់ផ្ទាល់ហាក់ដូចជាពុំច្បាស់) ម៉ៃ ឡាំ វរសេនីយឯកទ័ពវៀតណាមដែលនិយាយភាសាខ្មែរយ៉ាងច្បាស់ ហើយធ្លាប់មានបទពិសោធន៍ឆ្លងកាត់ការសិក្សាផ្នែកច្បាប់ និងសារមន្ទីរបានមកដល់ក្រុងភ្នំពេញ ។ ម៉ៃ ឡាំ ត្រូវបានផ្តល់នូវភារកិច្ចរៀបចំឯកសារនានា ដែលបានរកឃើញនៅមន្ទីរស-២១ នៅក្នុងបណ្ណសារដ្ឋានមួយ ហើយនឹងប្រែក្លាយទីកន្លែងនេះឲ្យទៅជាអ្វីដែលអ្នកស្រាវជ្រាវ ដេវីដ ហក បានហៅថាជា«សារមន្ទីរនៃសុបិនដ៏អាក្រក់របស់កម្ពុជា» ។ ទិដ្ឋភាពដំបូងនៃការងាររបស់ម៉ៃ ឡាំ គឺមានភាពបន្ទាន់ជាងទិដ្ឋភាពទី២ ។ កាលនោះមានក្តីសង្ឃឹមថា ឯកសារទាំងឡាយដែលប្រទះឃើញនៅក្នុងគុកទួលស្លែងអាចត្រូវបានយកមកប្រើប្រាស់ជាភ័ស្តុតាងក្នុងការជំនុំជម្រះក្តី ប៉ុល ពត និង អៀង សារី ដែលជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយចោទប្រកាន់អំពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ការជំនុំជម្រះក្តីទាំងនេះធ្វើឡើងនៅក្នុងទីក្រុងភ្នំពេញ កាលពីខែសីហា ឆ្នាំ១៩៧៩ ។ ទោះបីជាពត៌មានដ៏មានតម្លៃអំពីមន្ទីរស-២១ ត្រូវបានបញ្ចេញប្រើ

ប្រាស់នៅក្នុងការជំនុំជម្រះក្តីទាំងនោះក៏ដោយ ឯកសារទាំងនោះពុំបានផ្តល់នូវភ័ស្តុតាងច្បាស់ក្រឡែត ហើយពិតដោយមិនអាចទាញហេតុផលផ្សេងបានដែលផ្តល់ក្តីសង្ឃឹមឲ្យមន្ត្រីវៀតណាម និងមន្ត្រីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាអាចរកឃើញនោះទេ ។ មកទល់ពេលនេះពុំមានភ័ស្តុតាងឯកសារដែលភ្ជាប់ ប៉ុល ពត ឬអៀង សារី ដោយផ្ទាល់ទៅនឹងបទបញ្ជាឲ្យបោសសម្អាតមនុស្សនៅមន្ទីរស-២១ ត្រូវបានរកឃើញនៅឡើយទេ ទោះបីខ្សែសង្វាក់អាជ្ញាធរភ្ជាប់ស-២១ ជាមួយនឹងមជ្ឈិមបក្សមានភ័ស្តុតាងបញ្ជាក់យ៉ាងច្បាស់គ្មានមន្ទិលសង្ស័យយ៉ាងណាក៏ដោយ ។

ដោយសារចំណង់ចំណូលចិត្តរបស់គាត់អំពីប្រវត្តិសាស្ត្រគួបផ្សំនឹងបទពិសោធន៍របស់គាត់ជាមួយនឹងសារមន្ទីរនានា ម៉ៃ ឡាំ បានរៀបចំសារមន្ទីរឧក្រិដ្ឋកម្មសង្គ្រាមរបស់អាមេរិកនៅក្រុងហូជីមិញនិងបង្ហាញពីភាពឧក្រិដ្ឋនៃអ្វីដែលបានកើតឡើងនៅមន្ទីរស-២១ ។ ម៉ៃ ឡាំ បានប្រឡូកក្នុងការងាររបស់គាត់ពោរពេញដោយមោទនភាព និងភាពសោមនស្សរីករាយ ។ មិនតែប៉ុណ្ណោះភាពពិសេសតែមួយគត់របស់ ម៉ៃ ឡាំ ដែលជាអ្វីមួយពោរពេញដោយការពេញចិត្តដ៏ខ្លាំងបំផុតចំពោះកម្ពុជានិងប្រជាជនកម្ពុជាដោយសារបទពិសោធន៍របស់គាត់ធ្លាប់ឆ្លងកាត់ការងារក្នុងប្រទេសកម្ពុជានៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី១ បានផ្តល់ទឹកចិត្តជំរុញឲ្យគាត់ចាប់អារម្មណ៍យ៉ាងខ្លាំងលើការរៀបចំសារមន្ទីរនេះ ។ គាត់បានប្រាប់អ្នកធ្វើបទសម្ភាសន៍ជាមួយគាត់ កាលពីឆ្នាំ១៩៩៤ ថា«ដើម្បីយល់អំពីឧក្រិដ្ឋកម្មរបបប៉ុល ពត, អៀង សារី ដំបូងអ្នកគួរតែយល់អំពីប្រទេសកម្ពុជានិងប្រជាជននៃប្រទេសនេះសិន ។»

នៅក្នុងការប្រែក្លាយមន្ទីរ ស-២១ ឲ្យទៅជាសារៈមន្ទីរប្រល័យពូជសាសន៍ ម៉ៃ ឡាំ ចង់រៀបចំអតីតកាលដែលទើបនឹងកើតឡើងថ្មីៗរបស់ប្រទេសកម្ពុជា ឲ្យស្របទៅនឹងតម្រូវការនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងអ្នកផ្តល់ដំបូន្មានជាជនជាតិវៀតណាមរបស់របបនេះ ក៏ដូចជាសេចក្តីត្រូវការដ៏យូរអង្វែងនានារបស់ប្រជាជនកម្ពុជា តាមការប្រមើលមើលរបស់គាត់ ។ ដោយសារតួលេខនៃជនរងគ្រោះដែលស្លាប់ក្រោម«របបប្រល័យពូជសាសន៍ ប៉ុល ពត, អៀង សារី» គឺជាប្រជាជនកម្ពុជាខ្លួនឯង ពត៌មានដែល ម៉ៃឡាំ កំពុងព្យាយាមផ្សព្វផ្សាយគឺខុសប្លែកគ្នាអំពីពត៌មានដែលគាត់ធ្លាប់បានសង្ឃឹមពាំនាំនៅក្នុងសារមន្ទីរឧក្រិដ្ឋកម្មសង្គ្រាមរបស់អាមេរិកនៅវៀតណាម ។ ក៏ប៉ុន្តែពត៌មានដែលគាត់ចង់ពាំនាំចេញពីសារមន្ទីរទួលស្លែងគឺមានអំណាចឥទ្ធិពលប្រហាក់ប្រហែលគ្នាដែរ ។ ប្រវត្តិសាស្ត្រដែលគាត់បានផ្តើបង្កើតឡើងនៅក្នុងការតាំងពិពណ៌នៅលើអគារអតីតមន្ទីរស-២១ បានបដិសេធមិនទទួលស្គាល់អត្តសញ្ញាណសង្គមនិយមទាំងអស់របស់មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ហើយបានទាក់ទាញចិត្តនិងអារម្មណ៍ឲ្យអ្នកមើលសារមន្ទីរនេះ ធ្វើការផ្សារភ្ជាប់រវាងរបបកម្ពុជាប្រជាធិបតេយ្យ និងទួលស្លែង ហើយម្ខាងទៀតធ្វើការផ្សារភ្ជាប់រវាងណាហ្ស៊ី អាល្លឺម៉ង់ និងម្ខាងទៀតប្រៀបដូចជាអ្វីដែលលោក សឺជ ធីយ៉ែន បានហៅថា «អូសឆ្វិត Auschwitz ដ៏កំណាចយង់ឃ្នង» ដែលជាជំរំប្រមូលផ្តុំ និងប្រហារជីវិតនៃជនជាតិជ្វីសដ៏ធំ ។ ការប្រៀបធៀបទាំងនេះគឺសក្តិសមពីព្រោះមន្ទីរ ស-២១ ដូចជាជំរំប្រមូលផ្តុំសម្លាប់មនុស្សរបស់ពួកណាហ្ស៊ី ក៏ប៉ុន្តែការពាក់ព័ន្ធច្បាស់លាស់ជាច្រើនបន្ថែមទៀតរវាងលទ្ធិណាហ្ស៊ីនិងរបបកម្ពុជាប្រជាធិបតេយ្យ គឺពុំមានភាពជាក់លាក់នោះទេ ទោះបីជាកន្លែងទាំងពីរនេះគួរឲ្យទាក់ទាញអារម្មណ៍ចំពោះភាពប្រហាក់ប្រហែលគ្នាយ៉ាងណាក៏ដោយ ។

អ្នករួចជីវិតពីមន្ទីរស-២១ ជាជនជាតិកម្ពុជាម្នាក់បានក្លាយជានាយកសារមន្ទីរនៅពេលដែលសារមន្ទីរនេះ បានបើកទ្វារនៅឆ្នាំ១៩៨០គឺ លោក អ៊ឹង ប៉ិច ។ អ៊ឹង ប៉ិច កាន់តំណែងនេះអស់រយៈពេលជាច្រើនឆ្នាំ ហើយបានធ្វើដំណើរជាមួយ ម៉ៃ ឡាំ ទៅកាន់ប្រទេសបារាំង សហភាពសូវៀត និងអឺរ៉ុបខាងកើតនៅដើមទសវត្សរ៍ឆ្នាំ៨០ ដើម្បីធ្វើទស្សនកិច្ចសារមន្ទីរនានា ហើយនឹងពិធីតាំងពិពណ៌នានាដែលរំលឹកដោយឧក្រិដ្ឋកម្មរបស់ពួកណាហ្ស៊ី ។ ទោះបីជា ម៉ៃ ឡាំ នៅកម្ពុជា រហូតដល់ឆ្នាំ១៩៨៨ ហើយភាគច្រើនធ្វើការនៅទួលស្លែងក៏ដោយ ក៏គាត់លាក់បាំងតួនាទីជាទីប្រឹក្សានិងអ្នកជំនាញ) របស់គាត់ដែលជាអ្នកមកពីខាងក្រៅដើម្បីបង្កើតឲ្យមានការចាប់អារម្មណ៍ថា ការផ្តួចផ្តើមគំនិតក្នុងការរៀបចំសារមន្ទីរនិងរៀបចំបង្ហ គឺចេញមកពីស្នាដៃជនរងគ្រោះកម្ពុជាជាជាងចេញពីមកពីវៀតណាម ។ នេះក៏ជាការ

ចាប់អារម្មណ៍មួយដែលគាត់ព្យាយាមកែតម្រូវនៅក្នុងបទសម្ភាសន៍របស់គាត់នៅក្នុងទសវត្សរ៍ឆ្នាំ៩០ ។

រយៈពេលពីរ ទៅ បីខែក្រោយមកប្រជាជនដែលធ្វើការនៅក្នុងគុកបានកសាងនៅប្រវត្តិសាស្ត្រត្រួសៗអំពីគុកទួលស្លែងដោយប្រមូលចងក្រងឯកសារបញ្ជីចេញចូល ឯកសារសម្ងាប់របាយការណ៍ធ្វើឡើងដោយអ្នកសួរចម្លើយនិងការចងចាំរបស់អ្នកដែលរួចរស់ជីវិតពីគុកនេះ ។ ចន្លោះខែមេសា ឆ្នាំ ១៩៧៥ និងសប្តាហ៍ទី១ នៅឆ្នាំ១៩៧៩ អ្នកដែលធ្វើការនៅគុកទួលស្លែងទាំងនោះបានរកឃើញថាយ៉ាងតិចបំផុតមនុស្សចំនួន១៤០០០រួមទាំង បុរស ស្ត្រី និងកុមារត្រូវឃុំឃាំងនៅមន្ទីរស-២១ ។ ដោយសារឯកសារបញ្ជីចេញចូលសម្រាប់រយៈពេលប៉ុន្មានខែនៅឆ្នាំ១៩៧៨ ពុំមានភាពពេញលេញចំនួនអ្នកទោសពិតប្រាកដច្បាស់ជាមានចំនួនច្រើនជាងនេះ ។ ក្នុងចំណោមអ្នកទោសដែលចុះក្នុងឯកសារអ្នកទោសទាំងអស់លើកលែងតែអ្នកទោសមួយចំនួនតូចដូចជា អ៊ឹង ប៉ិច និងអ្នកឯទៀតត្រូវបានយកទៅសម្លាប់ ។ ការចងចាំរបស់អ្នកដែលរួចពីគុកទួលស្លែងបូកផ្សំនឹងពត៌មានពីអតីតកម្មាភិបាលខ្មែរក្រហមនៅទីនោះមានតម្លៃមិនអាចកាត់ថ្លៃបានចំពោះការសិក្សានេះ ។

មិនតែប៉ុណ្ណោះឯកសារពីមន្ទីរស-២១ បានបង្ហាញថា



ជនរងគ្រោះណាហ្ស៊ី (ប្រភពរូបថតសារមន្ទីរអានហ្វ្រាំងប្រទេសហូឡង់)


ជនរងគ្រោះខ្មែរក្រហម

អ្នកទោសដែលមានឋានៈតូចទាបភាគច្រើនត្រូវបានដាក់ឃុំឃាំងអស់រយៈពេល ២ ទៅ ៣ថ្ងៃ រីឯអ្នកទោសដែលសំខាន់ជាងនេះ ព្រមទាំងឥស្សរជនឋានៈទាបជាងនេះបន្តិចដែលត្រូវបានសង្ស័យអំពីបទល្មើសធ្ងន់ធ្ងរត្រូវបានដាក់ពន្ធនាគាររាប់ខែ ។ អ្នកទោសរាប់ពាន់ដោយមិនគិតអំពីសារៈសំខាន់របស់អ្នកទោសទាំងនោះបានឆ្លងកាត់ការសួរចម្លើយបានរៀបចំ «ចម្លើយ» ឬចម្លើយសារភាពថាខ្លួនបានប្រព្រឹត្តិល្មើសប្រឆាំងនឹងបដិវត្តន៍ ហើយរាយបញ្ជីអ្នកដែលជាប់ពាក់ព័ន្ធ ក្រោមចំណងជើងថា«បណ្តាញក្បត់» ឬ «ខ្សែក្បត់» ដែលជួនកាលមានរាយឈ្មោះរហូតដល់រាប់រយ ។ អត្ថបទនៃចម្លើយសារភាពមានចំនួនពី ១ទំព័រ រហូតដល់រាប់រយទំព័រ ។ ប្រហែលជាចម្លើយសារភាព ៤៣០០ត្រូវបានប្រមូលបានមកទល់ពេលនេះរួមទាំងចម្លើយសារភាពរបស់ឥស្សរជនសំខាន់ៗនៃរបបកម្ពុជាប្រជាធិបតេយ្យ ស្ទើរតែទាំងអស់ដែលត្រូវបានដឹងថាត្រូវបានធ្វើបន្សុទ្ធកម្មដកទោសសម្លាប់ចោល ។

ចម្លើយសារភាព ការចងចាំរបស់អ្នកដែលនៅរស់ទាំងឡាយ និងឧបករណ៍ដែលជាប់ស្នាមប្រឡាក់ដោយឈាមមនុស្សដែលត្រូវបានរកឃើញនៅគុកទួលស្លែងបញ្ជាក់ច្បាស់ថាការធ្វើទារុណកម្មមនុស្សត្រូវបានអនុវត្តន៍យ៉ាងខ្លាំងនៅមន្ទីរស-២១ ។ អ្នកទោសតិចតួចណាស់ក្រោយពី

ទទួលរងការធ្វើទារុណកម្មបែបនេះឬគំរាមកំហែងធ្វើទារុណកម្មពុំអាចស៊ូទ្រាំរក្សាការអះអាងថាខ្លួនគ្មានកំហុសបានយូរឡើយ ។ ចាប់តាំងពីពេលដែលអ្នកទោសទាំងនោះចូលមកដល់គុកទួលស្លែងគឺត្រូវបានចាត់ទុកថាជាអ្នកមានទោសរួចទៅហើយ ហើយពាក្យ«អ្នកទោស»ក្នុងភាសាខ្មែរតាមទំនៀមទម្លាប់តរៀងមកប្រែតាមន័យត្រង់មកថា «អ្នកដែលមានទោស» ។ នៅស-២១ ប្រជាជនប្រុសស្រីរាប់ពាន់ត្រូវបានរំពឹងទុកថា នឹងសារភាពអំពីទោសកំហុសជាលាយលក្ខណ៍អក្សរ មុនពេលត្រូវបានយកទៅសម្លាប់ចោល ។ នីតិវិធីព្រៃផ្សៃដ៏ចម្លែកនេះបានទទួលឥទ្ធិពលមួយចំនួន ចេញពីអ្វីដែលស្គាល់ថាយុត្តិធម៌បដិវត្តន៍ដែលមានឫសគល់នៅក្នុងរបបដ៏រន្ធត់នៅប្រទេសបារាំងក្នុងសតវត្សរ៍ទី១៨ ហើយដែលអនុម័តប្រើប្រាស់ក្នុងការកាត់ក្តីដែលធ្វើយកតែល្អមើលនៅក្រុងម៉ូស្គូ នៅទសវត្សរ៍ឆ្នាំ៣០និងចេញពីការកែទម្រង់ដីធ្លី និងយុទ្ធនាការ «អប់រំកែប្រែ» នៅក្នុងប្រទេសចិនក្នុងទសវត្សរ៍ឆ្នាំ៤០ និងមួយទសវត្សរ៍ក្រោយមកនៅប្រទេសវៀតណាម ។ ប្រហែលជាដោយសារតែឥទ្ធិពលជាច្រើនជាន់ទាំងនេះទើបពុំអាចកំណត់ថាតើមន្ទីរស-២១យកគំរូតាមការអនុវត្តន៍របស់ប្រទេស ឬចម្លងតាមប្រទេសណាមួយពិតប្រាកដនោះទេ ។ លើសពីនេះទៅទៀតភាពធ្ងន់ធ្ងរនៅមន្ទីរស-២១ និងភាពដាក់ស្តែងដែលអ្នកសួរចម្លើយបានអនុវត្តកិច្ចការនោះវាបានឆ្លុះបញ្ចាំងពីទំនៀមទម្លាប់ក្នុងការដាក់ទណ្ឌកម្មរបស់កម្ពុជានាសម័យមុនបដិវត្តន៍ដែលតាមរយៈទំនៀមទម្លាប់នោះអ្នកទោស ពុំដែលត្រូវបានចាត់ទុកថាគ្មានទោស ហើយទោសពានវាំង ឬទោសប្រឆាំងនឹងអ្នកដឹកនាំត្រូវបានផ្តន្ទាទោសដោយឥតមេត្តា ។

ទោះបីជាគោលនយោបាយសេដ្ឋកិច្ចសង្គមរបស់របបកម្ពុជាប្រជាធិបតេយ្យពុំស៊ីគ្នាទៅនឹងក្របខណ្ឌហ្វាស៊ីសណាហ្ស៊ីក៏ដោយ ក៏ទ្រង់ទ្រាយប្រហាក់ប្រហែលគ្នារវាងមន្ទីរស-២១ និងជំរំប្រហារជីវិតរបស់ពួកណាហ្ស៊ីគឺគួរឲ្យមានការភ្ញាក់ផ្អើល ។ ស្នាដៃនិពន្ធនានាដែលពិភាក្សាអំពីមហាឧក្រិដ្ឋកម្មរបស់ពួក ណាហ្ស៊ីផ្តល់នូវការជ្រួតជ្រាបដ៏ស៊ីជម្រៅក្នុងចិត្តសាស្ត្ររបស់អ្នកធ្វើទារុណកម្មសមាជិក ឬបុគ្គលិករដ្ឋាភិបាល និងជនរងគ្រោះនៅក្នុងគុក ។ ស្នាដៃនាពេលថ្មីៗបំផុតទាក់ទងនឹងអ្នកធ្វើទារុណកម្មនៅក្នុង «សង្គ្រាមកខ្វក់» នៅប្រទេសអាហ្សង់ទីន ក្នុងទសវត្សរ៍ឆ្នាំ៧០ និងដើមទសវត្សរ៍ឆ្នាំ៨០ ក៏បានផ្តល់នូវការយល់ជ្រួតជ្រាបអំពីភាពស្រដៀងគ្នានេះដែរ ។ ឯកសារដែលខ្ញុំយល់ថាមានប្រយោជន៍សម្រាប់ជាគោលដៅនៃការប្រៀបធៀបបែបនេះមានជាច្រើន ហើយងាយស្រួលអាចចុះបញ្ជីយ៉ាងវែងជាមួយនូវឯកសារទាំងអស់នោះ ។

ភាពខុសប្លែកគ្នាដ៏គួរឲ្យភ្ញាក់ផ្អើលបំផុតរវាងករណីប្រទេសកម្ពុជានិងអាល្លឺម៉ង់ ស្ថិតនៅត្រង់ទំហំនៃការរៀបចំឯកសារដែលពួកខ្មែរក្រហមបានបង្កើតឡើងនៅមន្ទីរស-២១ ។ អ្នកទោសទាំងនៅក្រោមរបបណាហ្ស៊ី និងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានកាត់ផ្តាច់ដាច់ស្រឡះនូវសិទ្ធិទទួលទ្រង់ទ្រាយណាមួយនៃការការពារដោយច្បាប់ ក៏ប៉ុន្តែអ្វីដែលខុសគ្នាស្ថិតនៅត្រង់ថាអ្នកទោសទាំងឡាយនៅក្នុងជំរំសម្លាប់រង្គាលរបស់ពួកណាហ្ស៊ីគឺត្រូវបានគេងប្រវ័ញ្ចដម្រិតយកកម្លាំងពលកម្មរង់ចាំពេលប្រហារជីវិតមកដល់ប៉ុណ្ណោះ រីឯនៅមន្ទីរស-២១វិញអ្នកទោសត្រូវបានប្រព្រឹត្តមកលើស្ទើរតែហាក់បីដូចក្នុងក្របខណ្ឌប្រព័ន្ធច្បាប់មួយ ហើយចម្លើយសារភាពរបស់ពួកអ្នកទោសទាំងនោះគឺហាក់បីដូចជាត្រូវផ្តល់ជាភស្តុតាងសម្រាប់តុលាការច្បាប់មួយ ។ នៅត្រង់ទិដ្ឋភាពនេះអ្នកសទោសនៅមន្ទីរស-២១ មានសណ្ឋានដូចទៅនឹងអ្នកប្រឆាំងនឹងបដិវត្តន៍ទាំងហ្វូងៗដែលត្រូវបានចោទប្រកាន់ដោយពុំមានភស្តុតាង ហើយដែលត្រូវយកទៅ«កាត់ទោស» នៅក្នុងអតីតសហភាពសូវៀតនៅទសវត្សរ៍ឆ្នាំ៣០ ។ ក្រោមរបបណាហ្ស៊ីអាល្លឺម៉ង់ អ្នកទោសនយោបាយត្រូវបានរក្សាក្នុងជំរំដាច់ដោយឡែកពីអ្នកទោសដែលដាក់ជាគោលដៅសម្លាប់ ហើយអ្នកទោសនយោបាយត្រូវបានប្រព្រឹត្តមកលើក្នុងលក្ខណៈប្រសើរជាង ។ នៅឯមន្ទីរ ស-២១អ្នកទោសទាំងអស់ត្រូវបានចោទអំពីបទល្មើសនយោបាយ ហើយអ្នកទាំងអស់ត្រូវបានយកទៅសម្លាប់ចោលដូចគ្នា ។ ដូចគ្នានឹងជំរំប្រហារជីវិតរបស់ពួកណាហ្ស៊ី និងមណ្ឌលធ្វើទារុណកម្មនៅអាហ្សង់ទីន មន្ទីរស-២១ គឺជាគុកដ៏សម្ងាត់មួយ ហើយការចាំបាច់ឲ្យមានល័ក្ខការណ៍សម្ងាត់នៅមន្ទីរស-២១ ជះឥទ្ធិពលជាច្រើនមកលើអ្វីដែលបានកើតឡើងនៅក្នុងបរិវេណគុកនោះ ។ វត្តមានរបស់គុកនេះ **(តទៅទំព័រទី៣២)**

# គ្រោះថ្នាក់នៃអព្យាក្រឹតភាព

## ការបែកបាក់ទំនាក់ទំនងរវាងកម្ពុជានិងសហរដ្ឋអាមេរិកឆ្នាំ ១៩៦៥

**(តពីលេខមុន)** ហេតុដូច្នេះហើយ នៅក្នុងអំឡុងរបបគ្រប់គ្រងរបស់ប្រធានាធិបតីកេណ្ណឺឌី អាមេរិកបានប៉ុនប៉ងទប់គម្រោងផ្តួលរំលំ ទ្រង់សីហនុ របស់វៀតណាមនិងថៃ ឲ្យនៅក្នុងការគ្រប់គ្រងបានរបស់ខ្លួន ហើយភ្លាមៗនោះ បានជូនដំណឹងដល់រដ្ឋាភិបាលកម្ពុជាអំពីការឃុបឃិតនានាដែលសហរដ្ឋអាមេរិកបានដឹង ។ ជាតុល្យភាពទំនាក់ទំនងរវាងប្រទេសទាំងពីរ នៅក្នុងអាណត្តិភាគច្រើនរបស់ប្រធានាធិបតី ចន កេណ្ណឺឌី គឺមានភាពល្អគួរសម ដែលយ៉ាងហោចណាស់ដោយសារការងារ ដ៏មានសមត្ថភាពរបស់ឯកអគ្គរដ្ឋទូត វីលៀម ទ្រីមបល ជាមន្ត្រីអាមេរិកាំងមួយរូបក្នុងចំណោមមន្ត្រីដ៏តិចតួចបំផុតដែលទ្រង់ សីហនុ ទុកចិត្ត ។

ក៏ប៉ុន្តែឯកអគ្គរដ្ឋទូត ទ្រីមបល ចាកចេញពីក្រុងភ្នំពេញក្នុងឆ្នាំ១៩៦២ ហើយនៅក្នុងរដូវក្តៅឆ្នាំ១៩៦៣ កងកម្លាំងទ័ពវៀតណាមខាងត្បូង បានទន្ទ្រានចូលក្នុងទឹកដីកម្ពុជាជាច្រើនលើកដើម្បីតាមរកចាប់ពួកវៀតកុង ។ នៅខែ សីហា ឆ្នាំ១៩៦៣ វិទ្យុសម្ងាត់ខ្មែរសេរីបានចាប់ផ្តើមចាក់ផ្សាយសំឡេងចេញពីប្រទេសវៀតណាមខាងត្បូង ។ រំពេចនោះទ្រង់ សីហនុ បានផ្តាច់ទំនាក់ទំនងជាមួយវៀតណាមខាងត្បូង ហើយចាប់ផ្តើមចោទថាភ្នាក់ងារ សេ.អ៊ី.អា កំពុងគាំទ្រសត្រូវរបស់ទ្រង់ជាថ្មីម្តងទៀតហើយ ។ នៅដើមខែវិច្ឆិកា ការផ្តួលរំលំនិងការលួចធ្វើឃាតប្រធានាធិបតី ង៉ោ ឌិញយៀម នៃវៀតណាមខាងត្បូង និងប្អូនប្រុសរបស់គាត់ ង៉ោ ឌិញញ៉ូ ដែលមានអាមេរិកជាអ្នកគាំទ្របានធ្វើឲ្យទ្រង់ សីហនុ ញ័រខ្លួនចំប្រប់ ។ ទោះបីជាទ្រង់មិនចូលចិត្តប្រធានាធិបតី ឌិញយៀម «ជ្រោលជ្រៅនិងចងសត្រូវ"យ៉ាងណាក៏ដោយ ទ្រង់ភ័យខ្លាចថាអាមេរិកអាចមានផែនការស្រដៀងគ្នានេះដែរ ហើយបម្រុងទុកនឹងប្រព្រឹត្តមកលើរូបទ្រង់ ។ សាស្ត្រាចារ្យ ដេវីដ ឆេនដល័រ សរសេរថា «មរណភាពរបស់មេដឹកនាំវៀតណាមខាងត្បូងទាំងពីរនេះបញ្ជាក់ពីការសង្ស័យរបស់ទ្រង់ថា អាមេរិកមិនអាចទុកចិត្តធ្វើជាសម្ព័ន្ធមិត្តបានឡើយ» ។ នៅពាក់កណ្តាល ខែវិច្ឆិកា អតីតខ្មែរសេរី២រូបបានប្រកាសជាសាធារណៈមិនទទួលស្គាល់ការគាំទ្ររបស់អាមេរិកចំពោះចលនាប្រឆាំងសីហនុ ហើយភ្លាមៗបន្ទាប់នោះតែ២ថ្ងៃមុនមានការលួចធ្វើឃាតលើប្រធានាធិបតីកេណ្ណឺឌី មេដឹកនាំកម្ពុជា ទ្រង់ សីហនុ បានប្រាប់សហរដ្ឋអាមេរិកថា ទ្រង់នឹងបណ្តេញក្រុមប្រឹក្សាជំនួយយោធារបស់អាមេរិកចេញ ហេតុដូច្នេះទ្រង់ពុំទទួលជំនួយអាមេរិកទៀតទេ ។ ទ្រង់ទំនងជាបានសន្និដ្ឋានថាជំនួយអាមេរិកពុំអាចជួយការពារទ្រង់ទប់ទល់នឹងសត្រូវរបស់ទ្រង់បានតទៅទៀត ។ ផ្ទុយទៅវិញនោះចំណងទាក់ទងជិតស្និទ្ធជាមួយសហរដ្ឋអាមេរិក បង្កភាពមហន្តរាយដល់ប្រទេសរបស់ទ្រង់ ហើយចលនាកុម្មុយនិស្តនឹងទទួលជ័យជំនះនៅវៀតណាមដូចដែលទ្រង់មានព្រះតម្រិះហើយ ដែលកាន់តែជឿជាក់ថាពួកកុម្មុយនិស្តនឹងទទួលបាននូវជ័យជំនះ ។

ទំនាក់ទំនងអាមេរិក-កម្ពុជាបានធ្លាក់ដាំក្បាលចុះយ៉ាងលឿនៗ ។ ថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៦៣ នាយករដ្ឋមន្ត្រីថៃ សារិទ្ធ ថាណារ៉ាត់ បានទទួលមរណភាព ហើយទ្រង់ សីហនុ បានអំពាវនាវឲ្យមានការប្រារព្ធពិធីអបអរសាទរទូទាំងប្រទេសមួយដែលអនុរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការនយោបាយឈ្មោះ អាវេរែល ហារីម៉ែន បានហៅការអបអរនេះថា «សាហាវឃោរឃៅ» ។ ក៏ប៉ុន្តែអ្វីដែលបានធ្វើឲ្យសហរដ្ឋអាមេរិកខឹងសម្បារយ៉ាងខ្លាំងនោះ គឺការសង្កត់បញ្ជាក់តាមការផ្សាយវិទ្យុរបស់ទ្រង់សីហនុ ថាការស្លាប់របស់ ង៉ោ ឌិញយៀម, សារិទ្ធ ថាណារ៉ាត់ និង ចន កេណ្ណឺឌី បណ្តាលមកពីការធ្វើអន្តរាគមន៍របស់ព្រះជាម្ចាស់ដើម្បីសង្គ្រោះកម្ពុជា ។ ទ្រង់ត្រូវបានចោទថាបានថ្លែងៈ «កម្ពុជាយើងមានសត្រូវតែពាគត់ ហើយមេដឹកនាំរបស់ប្រទេសទាំងបីនេះគឺស្លាប់ទាំងអស់ហើយចុះនរកទាំង៣នាក់នៅក្នុងអំឡុងពេលប្រមាណមួយខែកន្លះប៉ុណ្ណោះហើយពួកគេទាំង៣នាក់កំពុងជួបប្រជុំជាមួយគ្នានៅក្នុងសន្និសីទអគ្គការ





សន្ធិសញ្ញាអាស៊ីភាគអគ្នេយ៍របស់លោកសេរី» ជាភាសាអង់គ្លេសសរសេរកាត់ថា SEATO ។

សហរដ្ឋអាមេរិកបានតវ៉ាយ៉ាងខ្លាំងចំពោះបញ្ហានេះ ។ ទ្រង់ សីហនុ បានបញ្ចេញប្រតិកម្មតបតយ៉ាងក្រេវក្រោធ ដោយបដិសេធថាទ្រង់ពុំបានផ្សព្វផ្សាយពត៌មានដូច្នេះ ដោយទ្រង់ប្រកាសបិទស្ថានទូតរបស់ទ្រង់នៅក្រុងវ៉ាស៊ីនតោន ហើយបញ្ចប់ការចរចាអំពីបែបបទបញ្ចប់ជំនួយអាមេរិក ។ ពេលនោះសហរដ្ឋអាមេរិក បានពិចារណាកាត់បន្ថយបុគ្គលិករបស់ខ្លួននៅកម្ពុជាដល់កម្រិតអប្បបរមា ហើយឯកអគ្គរដ្ឋទូត ហ៊ីលីព ស្រ្តុះ បានរៀបចំត្រឡប់ទៅក្រុងវ៉ាស៊ីនតោនវិញ ។ ទោះបីជាទំនាក់ទំនងអាមេរិក-កម្ពុជា ស្ថិតក្នុងភាពរកាំរកូសយ៉ាងណាក៏ដោយ ក៏ពេលនោះពុំមានភាគីម្ខាងណាប្រកាសផ្តាច់ទំនាក់ទំនងដ៏ប្រេះឆានេះឡើយ ។

សម្រាប់រយៈពេល ១៧ខែបន្ទាប់ មកលោក បីលតុន អូស្បន សរសេរថា «ទំនាក់ទំនងរវាងប្រទេសទាំងពីរកម្ពុជានិងសហរដ្ឋអាមេរិកក្លាយជាការនិយាយភាសារវាងមនុស្សថ្លង់និងមនុស្សថ្លង់» ។ បញ្ហាជាច្រើនក្នុងចំណោមបញ្ហាទាំងឡាយពុំមែនជារឿងថ្មីនោះទេ ។ ទ្រង់ សីហនុ បានបន្តចោទថាសហរដ្ឋអាមេរិកពាក់ព័ន្ធសហការជាមួយប្រទេសថៃ វៀតណាមខាងត្បូង និងសត្រូវស្នូរពូជរបស់ទ្រង់គឺ សឺង ង៉ុកថាញ់ ដើម្បីបង្កអស្ថេរភាពនៅកម្ពុជា ។ កាលពីខែមករា និងកុម្ភៈ ឆ្នាំ១៩៦៤ ជាឧទាហរណ៍ រដ្ឋាភិបាលកម្ពុជាបានធ្វើការចោទប្រកាន់យ៉ាងធ្ងន់ៗយ៉ាងតិច៣លើកថា អាមេរិកពាក់ព័ន្ធជាមួយនឹងក្រុមប្រឆាំងនឹងប្រទេសកម្ពុជា ។ បញ្ហាត្រង់ថាតើការចោទប្រកាន់ដោយពុំមានសំអាងទាំងនេះត្រឹមត្រូវដែរឬយ៉ាងណានោះ គឺពិបាកនឹងកំណត់ណាស់ ពីព្រោះថាឯកសារជាច្រើននៅតែរក្សាសម្ងាត់នៅឡើយ ។ ក៏ប៉ុន្តែមានភ័ស្តុតាងដែលបញ្ជេះឲ្យមានការចោទប្រកាន់នេះឡើងថានៅក្នុងរដ្ឋាភិបាលសហរដ្ឋអាមេរិកមានមន្ត្រីមួយចំនួនចង់ឲ្យមេដឹកនាំថ្មីជំនួសសីហនុ ទោះបីជាគ្រប់មជ្ឈដ្ឋានទទួលស្គាល់ជាទូទៅថា គ្មាននរណាម្នាក់មានសមត្ថភាពប្រហាក់ប្រហែលនឹងទ្រង់ សីហនុ ក្នុងការប្រកួតប្រជែងជាមួយទ្រង់លើបញ្ហាការគាំទ្រពីប្រជាជនទូទៅនោះក៏ដោយ ។ ជាឧទាហរណ៍កាលពីចុងខែកុម្ភៈ របាយការណ៍មួយមកពីក្រុងវៀងច័ន្ទ ប្រទេសឡាវ បានបង្ហើបឲ្យដឹងថា ឧត្តមសេនីយ៍ កម្ពុជា លន់ ណុល (ដែលប្រឆាំងនឹងកុម្មុយនិស្ត



អាវុធហត្ថជាតិនៃរបបសាធារណរដ្ឋខ្មែរ

យ៉ាងពេញទំហឹង) អាចនឹងរៀបចំគម្រោងធ្វើរដ្ឋប្រហារមួយ ។ នៅពេលដែលឯកអគ្គរដ្ឋទូត ស្ត្រុះ បានដឹងអំពីរបាយការណ៍នេះ...ស្ត្រុះ បានទទូចមិនឲ្យផ្សព្វផ្សាយរបាយការណ៍នោះពីព្រោះប្រសិនបើទ្រង់ សីហនុ បានដឹងអំពីគម្រោងការធ្វើរដ្ឋប្រហារនេះ នឹងធ្វើឲ្យ «មានការបោសសម្អាតចេញពីឆាកនយោបាយកម្ពុជា នូវបុគ្គល លន់ ណុល ដែលមានចរិតប្រឆាំងកុម្មុយនិស្តដែលមានឥទ្ធិពលបំផុត» ។ បន្ទាប់មកនៅខែខសភា អ្នកកាសែតដ៏ល្បីល្បាញម្នាក់ឈ្មោះ ម៉ាគីស ឆាល បានអះអាងថា មន្ទីរបញ្ចកោននៃក្រសួងការពារប្រទេសសហរដ្ឋអាមេរិក ចង់ឲ្យមានការផ្តួលរំលំទ្រង់សីហនុ ដែលជាការចោទប្រកាន់ដោយពុំមានសម្អាងដែលបញ្ជោះឲ្យទ្រង់ សីហនុ មានការសង្ស័យជាច្រើនចំពោះគោលបំណងរបស់សហរដ្ឋអាមេរិក ។

ធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នានេះដែរ (ហើយមានចំនួនច្រើនជាង) គឺការចោទថា សហរដ្ឋអាមេរិកបានដាក់ទណ្ឌកម្ម និងបានចូលរួមក្នុងការវាយឆ្មក់ដោយយោធាមកលើភូមិជាច្រើនរបស់កម្ពុជាដែលនៅជាប់នឹងព្រំដែនពីទឹកដីវៀតណាមខាងត្បូង ។ នេះពុំមែនជាការចោទថ្មីមួយឡើយ ។ ក៏ប៉ុន្តែនៅពេលដែលសង្គ្រាមនៅវៀតណាម ឆេះសន្ធោសន្ធៅ ឧប្បត្តិហេតុជាច្រើនពាក់ព័ន្ធនឹងកម្ពុជាបានកើនឡើងទាំងចំនួននិងភាពធ្ងន់ធ្ងរ ។ តាមសេចក្តីរាយការណ៍មកថា ទ្រង់ សីហនុ ខ្វាល់យ៉ាងខ្លាំង នៅពេលដែលយន្តហោះចម្បាំងវៀតណាមខាងត្បូងបានវាយប្រហារមកលើភូមិម៉ូង (ប្តុមួង) ប្រហែល២គីឡូម៉ែត្រនៅក្នុងទឹកដីកម្ពុជា ដោយសម្លាប់ប្រជាជនកម្ពុជា៥នាក់ និងធ្វើឲ្យរបួស៦នាក់ កាលពីថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៦៤ ។

ធ្ងន់ធ្ងរជាងនេះទៅទៀតនៅថ្ងៃទី១៩ ខែមីនា គ្រាន់តែ៩ថ្ងៃ បន្ទាប់ពីបាតុកម្មហិង្សា មកលើស្ថានទូតសហរដ្ឋអាមេរិក យន្តហោះចម្បាំងមកពីកងកម្លាំងយោធាវៀតណាមខាងត្បូងពេលកំពុងព្យាយាមស្វែងរកកម្ទេចមូលដ្ឋានសម្ងាត់របស់វៀតកុង បានវាយប្រហារមកលើភូមិចន្ទ្រារបស់កម្ពុជាដោយគ្រាប់បែកភ្លើង និងកាំភ្លើងស្វ័យប្រវត្តិជាច្រើន ។ ប្រជាជនកម្ពុជាក្នុងភូមិចន្ទ្រាស្លាប់អស់១៧នាក់ ហើយ១៩នាក់ទៀតរបួស ។ ទ័ពថ្មើរជើងវៀតណាមខាងត្បូងជាមួយនឹងទីប្រឹក្សាយោធាអាមេរិកក៏បានចូលប្រឡូកក្នុងប្រតិបត្តិការណ៍នោះដែរ ។ លោក មៃឃើល ហ្វ័ររេស្តុល ដែលជាសមាជិកជាន់ខ្ពស់ម្នាក់នៃសេនាធិការសន្តិសុខជាតិរបស់សេតវិមានបានផ្តល់ពត៌មានទៅប្រធានាធិបតី លីនដុន ចនសុន ថាបុគ្គលិកអាមេរិកកាំងបានជ្រៀតចូលទៅក្នុងទឹកដីកម្ពុជាដោយគាត់អះអាងថា បុគ្គលិកទាំងនោះពុំមានពត៌មានគ្រប់គ្រាន់ដើម្បីកំណត់ឲ្យច្បាស់អំពីទីតាំងភូមិសាស្ត្ររបស់ពួកខ្លួន នេះបើតាមសំដីអះអាងពីលើករបស់ ហ្វ័រេសស្តុល ។ វៀតណាមខាងត្បូងបានសុំទោសចំពោះឧប្បត្តិហេតុនេះ ។ មិនតែប៉ុណ្ណោះប្រធានាធិបតី ចនសុន មាននិន្នាការចង់សុំទោសដែរ ក៏ប៉ុន្តែមានជំនឿថា ធ្វើដូច្នេះនឹងធ្លាក់ចូលទៅក្នុងព្រះទ័យទ្រង់សីហនុ ដែលជឿថាសហរដ្ឋអាមេរិកត្រួតត្រាវៀតណាមខាងត្បូង ។ នៅទីបញ្ចប់សហរដ្ឋអាមេរិកបានសំដែងការសោកស្តាយជាផ្លូវការចំពោះឧប្បត្តិហេតុនៅស្រុកចន្ទ្រា ដោយបានទទួលស្គាល់ថា ទីប្រឹក្សាជនជាតិអាមេរិកមានវត្តមាននៅក្នុងទឹកដីកម្ពុជា ហើយបកស្រាយថា វាជាកំហុសក្នុងការមើលផែនទី ក៏ប៉ុន្តែសហរដ្ឋអាមេរិកពុំសុំទោស ឬទទួលខុសត្រូវចំពោះឧប្បត្តិហេតុនេះឡើយ ។ ភាពធ្ងន់ធ្ងរនៃឧប្បត្តិហេតុនេះបាននាំឲ្យមន្ត្រីមួយចំនួននៅក្នុងរដ្ឋាភិបាលសហរដ្ឋអាមេរិកទាមទារឲ្យមានវិធានការមួយចំនួនត្រូវបានចាត់ឡើងដើម្បីធានាឲ្យប្រាកដថាឧប្បត្តិហេតុបែបនេះនឹងពុំកើតឡើងជាថ្មីម្តងទៀតនៅក្នុងពេលអនាគត ។ ក៏ប៉ុន្តែផ្នែកយោធាជំទាស់នឹងបញ្ហានេះ ។ ម៉ាក្សវែល ថៃល័រ បានបដិសេធមិនបានសុំឲ្យមេបញ្ជាការកងទ័ពអាមេរិកនៅវៀតណាម ដូល ហាគីន ចាត់វិធានការអ្វីខ្លះដែលគួរតែចាត់ចែងឡើងដើម្បីទប់ស្កាត់ឧប្បត្តិហេតុបែបនេះកុំឲ្យកើតឡើងនៅពេលអនាគតនោះទេ ។ នៅក្នុងទស្សនៈរបស់រដ្ឋាភិបាលអាមេរិកការពិចារណាអំពីកម្ពុជាទុកលំដាប់ក្រោយគឺលំដាប់ទី២ ។ កត្តាសំខាន់ទី៣ គឺភាពអល់អែករបស់សហរដ្ឋអាមេរិកក្នុងការគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់ទ្រង់សីហនុ ដើម្បីរៀបចំសន្និសីទក្រុងហ្សឺណែវ ដើម្បីធានាអធិបតេយ្យភាពប្រទេសរបស់ទ្រង់ និងរក្សាព្រំដែនឲ្យរួចពីការឈ្លានពាន ។ ទ្រង់ សីហនុ ពីដំបូងឡើយបានសំណូមពរឲ្យមានសន្និសីទមួយបែបនេះនៅក្នុងរដូវក្តៅឆ្នាំ១៩៦២ ។ ដោយសារការជំទាស់ពីប្រទេសថៃ និងវៀតណាម

ខាងត្បូងសន្និសីទតែមួយគត់ដែលសហរដ្ឋអាមេរិកចង់គាំទ្រ គឺសន្និសីទដែលផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងនានា ដែលផុសចេញមុនពេលជំនួបសន្និសីទតាមរយៈការទូតដ៏ស្ងៀមស្ងាត់ ហើយហេតុដូច្នេះសន្និសីទនោះគាំងពុំមានច្រកចេញ ។ ក៏ប៉ុន្តែដោយសារថាម្តងនេះ បារាំងនិងចក្រភពអង់គ្លេសបានគាំទ្រព្រះរាជតម្រិះរបស់ទ្រង់ សីហនុ រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក ឌីន រ៉ាស់ មានទស្សនៈបើកទូលាយចំពោះគំនិតរបស់ទ្រង់ សីហនុ ដរាបណាគំនិតនោះអាចទទួលបានលទ្ធផលគួរជាទីពេញចិត្ត ។ ក៏ប៉ុន្តែមន្ត្រីនានានៅសេតវិមានជំទាស់ ។ លោកគ្លីវហ្វដ អាឡិចសាន់ឌឺរ ដែលជាជំនួយការពិសេសរបស់លោកប្រធានាធិបតីអាមេរិកបានប្តឹងតវ៉ាទៅទីប្រឹក្សាសន្តិសុខជាតិ ចច ប៊ុនឌី អំពី «ចលករនៅសហរដ្ឋអាមេរិក ក្នុងការដើរឆ្ពោះទៅសន្និសីទបែបនេះថា ... ក្នុងការប្រណាំងប្រជែងរបស់យើងឆ្ពោះទៅវេទិកាសន្និសីទ តាមដែលខ្ញុំដឹងពុំមាននរណាម្នាក់ឆ្លើយថា មានផលប្រយោជន៍សូម្បីតែមួយសំឡេង ដែលអាចជាលទ្ធផលចេញពីជំនួបប្រជុំមួយបែបនេះ» ។

ទីបញ្ចប់ប្រទេសដែលប្រឆាំងនឹងសន្និសីទនេះទទួលបានជ័យជំនះ ។ ទោះបីជាសហរដ្ឋអាមេរិកពុំដែលបានជំទាស់ជាផ្លូវការចំពោះសន្និសីទនេះជាគោលការណ៍ក៏ដោយ ក៏សហរដ្ឋអាមេរិកទុកបញ្ហានេះឲ្យនៅគាំងអស់រាប់ខែ ។


លោកសេនាប្រមុខ លន់ ណុល

ទ្រង់សីហនុ ចោទថាទង្វើរបស់សហរដ្ឋអាមេរិក ដូច្នេះចង្អុលបង្ហាញអំពី «គំនិតដ៏អាក្រក់ភាពទ្រុស្តមិត្តនិងភាពចចេសរឹងរូស» ។ នៅពាក់កណ្តាលខែកុម្ភៈ ឆ្នាំ១៩៦៤ ទ្រង់សីហនុបានចេញសេចក្តីថ្លែងការណ៍ដ៏គំរោះគំរើយថាប្រសិនបើសន្និសីទមួយនេះពុំត្រូវបានកោះឲ្យប្រព្រឹត្តឡើងនៅត្រឹមចុងខែឧសភា ឆ្នាំ១៩៦៤ ទេនោះ ទ្រង់នឹងកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក ហើយនិងសម្ព័ន្ធមិត្តដទៃទៀតរបស់សហរដ្ឋអាមេរិក ។ មន្ត្រីស្ថានទូតអាមេរិកបានផ្ញើការសន្និដ្ឋានថា «អនាគតនៃទំនាក់ទំនងរបស់សហរដ្ឋអាមេរិកជាមួយកម្ពុជាស្ថិតក្នុងភាពមិនប្រាកដប្រជាយ៉ាងខ្លាំង» ។ បន្ទាប់ពីនោះបន្តិចបាតុករកម្ពុជាបានវាយប្រហារលើស្ថានទូតអាមេរិកដោយមានកាន់បដាជាច្រើនផ្ញើការរិះគន់អាមេរិក និងអង់គ្លេសចំពោះការបដិសេធពុំគាំទ្រសំណើនេះ ។ ទោះបីជារដ្ឋាភិបាលកម្ពុជាជាផ្លូវការមានការសោកស្តាយចំពោះឧប្បត្តិហេតុនេះហើយបានផ្តល់សងការខូចខាតក៏ដោយ ទ្រង់សីហនុ ហាក់បីដូចជាមានមោទនភាពចំពោះទំហំនៃបាតុកម្មនោះ ។

មន្ត្រីមួយចំនួនរួមទាំងមន្ត្រីការិយាល័យការបរទេសបារាំងផងបានគិតថាសហរដ្ឋអាមេរិកបាននាំឲ្យមានស្ថានភាពបែបនេះកើតឡើងចំពោះខ្លួនគេដោយសារភាពរឹងត្អឹងទាំងស្រុងរបស់ពួកខ្លួន ។ ក៏ប៉ុន្តែមន្ត្រី

**(តទៅទំព័រទី៤១)**

# ច្បាប់សង្គ្រាម

ច្បាប់អន្តរជាតិកើតចេញពីប្រភពពីរគឺ សេចក្តីប្រកាស និងទំនៀមទម្លាប់ ។ និយាយជាទូទៅច្បាប់សង្គ្រាមត្រូវអនុវត្តន៍ នៅពេលដែលកម្លាំងប្រដាប់អាវុធត្រូវប្រើប្រាស់ដោយប្រទេស មួយនិងឥរិយាបទប្រយុទ្ធនៅពេលដែលជម្លោះប្រដាប់អាវុធ បានផ្ទុះឡើង ។ច្បាប់សង្គ្រាមអនុវត្តដូចៗគ្នាចំពោះជម្លោះក្នុងផ្ទៃ ប្រទេសនិងជម្លោះអន្តរជាតិ ទោះបីជាជម្លោះរវាងប្រទេស មួយនិងប្រទេសមួយទៀតត្រូវបានដាក់កម្រិតធ្ងន់ធ្ងរជាងក៏ដោយ ។ ក្នុងលក្ខណៈជាបទឧក្រិដ្ឋមួយ អំពើប្រល័យពូជសាសន៍បានរំលោភបំពានទៅលើអនុសញ្ញាក្រុងហ្សឺណែវស្តីអំពីច្បាប់សង្គ្រាម និងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្សរួចទៅហើយ ។ ក្នុងគោលបំណងទូទៅ ដូចគ្នាទាំងអនុសញ្ញាក្រុងហ្សឺណែវនិងសេចក្តីប្រកាសជាសកលស្តី អំពីសិទ្ធិមនុស្សពុំបានចែងឲ្យច្បាស់អំពីការប្រព្រឹត្តសាហាវឃោរឃៅលើជនស៊ីវិលដែលស្ថិតនៅក្រោមការគ្រប់គ្រងអ្នកទោសជាឈ្លើយសឹកសង្គ្រាម បុគ្គលិកពេទ្យដែលត្រូវបានចែងដោយច្បាប់ សង្គ្រាម ។ ប្រការជាលាយល័ក្ខអក្សរដែលអនុវត្តន៍ចំពោះប្រភេទ បទឧក្រិដ្ឋដែលនិយាយខាងលើចែងតែចំពោះជម្លោះរវាងប្រទេស និងប្រទេសប៉ុណ្ណោះ ។ ជនដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅ ក្នុងប្រទេសត្រូវយកមកកាត់ទោសតាមរយៈច្បាប់កើតដោយទំនៀមទម្លាប់និងមាត្រា៣ រួមនៃអនុសញ្ញាក្រុងហ្សឺណែវ ។ ស្មារតីនិងចេតនានៃច្បាប់តាមទំនៀមទម្លាប់ដែលអនុវត្តចំពោះក្រុមដាក់លាក់ទាំងឡាយគឺត្រូវបានចែងនៅក្នុងអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ស្តីពីឈ្លើយសឹកសង្គ្រាមក្នុងអនុសញ្ញាក្រុងហ្សឺណែវទី៤ស្តីអំពីជនស៊ីវិល ក្នុងពេលសង្គ្រាមនិងក្នុងអនុសញ្ញាក្រុងហ្សឺណែវទី១ និងទី២ដែល ដាក់កម្រិតលើការប្រព្រឹត្តមកលើអ្នកមានជំងឺ អ្នករបួស និងការប្រព្រឹត្តរបស់អ្នកដែលថែទាំអ្នកជំងឺទាំងនោះ ។



**ក. ដែនសមត្ថកិច្ច**






មាត្រារួមទី៣នៃអនុសញ្ញាក្រុងហ្សឺណែវផ្តល់នូវការយកចិត្តទុកដាក់នៃច្បាប់អន្តរជាតិក្នុងជម្លោះប្រដាប់អាវុធមួយដែលមិនមែនជាលក្ខណៈជម្លោះអន្តរជាតិដែលបានកើតឡើងក្នុងទឹកដីនៃរដ្ឋមួយក្នុងចំណោមភាគីរដ្ឋទាំងឡាយដែលបានចុះហត្ថលេខាលើអនុសញ្ញាក្រុងហ្សឺណែវទាំងនេះ ។ មាត្រា៣រួមត្រូវបានបកស្រាយ ដើម្បីយកមកអនុវត្តចំពោះការប្រព្រឹត្តមកលើជនស៊ីវិលនៅក្នុងជម្លោះប្រដាប់អាវុធទាំងឡាយ ។ ពិធីសារបន្ថែមដែលបង្កើតឡើងក្នុងឆ្នាំ១៩៧៧ ចំពោះអនុសញ្ញាក្រុងហ្សឺណែវបានពង្រីកនិងបញ្ជាក់ច្បាស់ពី «៤» ទាំងឡាយនៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ គ្រប់ផ្នែកទាំងអស់នៃពិធីសារឆ្នាំ១៩៧៧ ទៅនឹងអនុសញ្ញាក្រុងហ្សឺណែវត្រូវបានគេចាត់ទុកថាជាសេចក្តីប្រកាសដ៏មានអំណាចពីច្បាប់ទំនៀមទម្លាប់សង្គ្រាមដែលអនុវត្តចំពោះគ្រប់រដ្ឋទាំងអស់ ។

## ខ. គោលបំណង

គោលបំណងរបស់ច្បាប់សង្គ្រាមគឺសំដៅកម្រិតការប្រយុទ្ធគ្នាឲ្យនៅត្រឹមព្រំដែនកំណត់ ហើយក្នុងកាលៈទេសៈសង្គ្រាមបែបនេះ ការពារជនស៊ីវិលឲ្យរួចផុតពីការរំលោភបំពានដែលបង្កដោយរដ្ឋមួយ ហេតុដូច្នេះច្បាប់សង្គ្រាមទាំងឡាយបានផ្តល់នូវជម្រកដ៏មាំមួយ ការពារជីវិតនិងសិទ្ធិសេរីភាពរបស់បុគ្គលទាំងឡាយ ។ តាមទ្រឹស្តីការពារទាំងនេះត្រូវផ្តល់ឲ្យនៅគ្រប់ពេលដែលជម្លោះប្រដាប់អាវុធបានផ្ទុះឡើង ។ ការសម្លាប់រង្គាលនូវប្រជាជនក្នុងស្រុកក្នុងលក្ខណៈជាប្រព័ន្ធដែលប្រកាសដោយកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលគឺជាការរំលោភបំពានលើសន្តិភាពរួចជាស្រេចទៅហើយ ដូចជាការប្រកាសសង្គ្រាមជាផ្លូវការមួយដែលជាព្រឹត្តិការណ៍មួយមិនដែលកើតឡើងក្នុងភាពជាក់ស្តែង ចាប់តាំងតែពីឆ្នាំ១៩៤៨ ហើយការប្រកាសសង្គ្រាមជាផ្លូវការបានបាត់បង់នូវភាពស្របច្បាប់ជាច្រើន ។

## គ. ឈ្លើយសឹកសង្គ្រាម

ការប្រព្រឹត្តយោរយៅទៅលើឈ្លើយសឹកសង្គ្រាមគឺជាប្រធានបទនៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ដែលទាក់ទងទៅនឹងការប្រព្រឹត្តយោរយៅទៅលើឈ្លើយសឹកសង្គ្រាមគឺ «អនុសញ្ញាក្រុងហ្សឺណែវទី៣» ។ ជាឈ្លើយសឹកសង្គ្រាមគឺមិនមែនជាឧក្រិដ្ឋជនទេ ហើយក៏មិនមែនជាចំណាប់ខ្មាំងដែរ ប៉ុន្តែគឺជាយុទ្ធជនដែលត្រូវបានឃុំគ្រង ដើម្បីកុំឲ្យបន្តសកម្មភាពក្នុងអង្គភាពយោធារបស់សត្រូវជាថ្មី ។ ក្រុមអ្នកប្រឆាំងនឹងរដ្ឋាភិបាលមិនអាចក្លាយជាឈ្លើយសឹកសង្គ្រាមគ្រាន់តែដោយសារមន្ត្រីនៃរដ្ឋទាំងនោះបានប្រើប្រាស់អំពើហិង្សា ឬអាវុធជាធរមកលើរដ្ឋាភិបាលនោះទេ ។ ជាឈ្លើយសឹកសង្គ្រាម គឺជាអ្នកដែលត្រូវបានចាប់ក្នុងជម្លោះប្រដាប់អាវុធ ហើយជាអ្នកដែលត្រូវទទួលបាននូវការការពារតាមផ្លូវច្បាប់តែមួយគត់ ដោយអនុសញ្ញាក្រុងហ្សឺណែវទី៣ ។

អនុសញ្ញានេះបានអះអាងថា ឈ្លើយសឹកសង្គ្រាមត្រូវតែឃុំខ្លួនក្នុងជំរំឃុំឃាំងឈ្លើយសឹកសង្គ្រាមមួយច្បាស់លាស់ ។ ការផ្ទុំបត់តប ឬការសងសឹកទៅលើឈ្លើយសឹកសង្គ្រាមត្រូវហាមឃាត់ជាដាច់ខាត ហើយឈ្លើយសឹកសង្គ្រាមត្រូវតែដោះលែង ហើយបញ្ជូនឲ្យទៅអង្គភាពដើមវិញនៅពេលបញ្ចប់ជម្លោះប្រដាប់អាវុធហើយមិនត្រូវឃុំឃាំងទុកដើម្បីទាញយកសម្បទានទាំងឡាយពីសត្រូវនោះទេ ។ រដ្ឋដែលឃុំឃាំងឈ្លើយសឹកសង្គ្រាមគឺស្ថិតនៅក្រោមកាតព្វកិច្ចដ៏តឹងរឹងមិនឲ្យប្រព្រឹត្តយោរយៅធ្វើបាប ឬបណ្តោយឲ្យធ្វើបាបឈ្លើយសឹកសង្គ្រាមនោះឡើយ ។ ហេតុដូច្នេះហើយ វាគឺជាការរំលោភមួយយ៉ាងច្បាស់លើអនុសញ្ញា ការដែលរដ្ឋមួយធ្វើឃាត ធ្វើទារុណកម្ម រំលោភបំពានលើឈ្លើយសឹកសង្គ្រាម ឬអនុញ្ញាតឲ្យសមាជិករបស់កងកម្លាំងខ្លួន ឬប្រជាជនខ្លួនធ្វើអំពើដូច្នោះ ។

អ្នកទោសនយោបាយ និងអ្នកទោសប្រភេទផ្សេងៗទៀតដែលស្ថិតនៅក្រោមការបង្ខិតបង្ខំ ឬក្រោមរបបប្រល័យពូជសាសន៍ ទទួលនូវសិទ្ធិការពារពីច្បាប់មនុស្សធម៌ប្រហាក់ប្រហែលទៅនឹងសិទ្ធិដែលផ្តល់ទៅឲ្យឈ្លើយសឹកតាមរយៈការអនុវត្តន៍នូវច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។ សិទ្ធិទទួលភាពការពារដែលបង្កើតឡើងសម្រាប់អ្នកទោសជាឈ្លើយសឹកសង្គ្រាមគឺដើម្បីជួយជនរងគ្រោះក្រោមរបបផ្តាច់ការមួយ ដូចជារបបខ្មែរក្រហមជាដើម ពីព្រោះអនុសញ្ញានេះបានដាក់បទបញ្ញានេះដែលត្រូវបានបកស្រាយដើម្បីបង្កើតនូវបទដ្ឋានដើម្បីធានា



ប៉ុល ពត

សិទ្ធិទាំងឡាយរបស់អ្នកទោសទាំងអស់ ទាំងអ្នកទោសជាតិនិងអ្នកទោសអន្តរជាតិ ។

## ឃ. ជនស៊ីវិល

អនុសញ្ញាទីក្រុងហ្សឺណែវទាក់ទងទៅនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម «អនុសញ្ញាក្រុងហ្សឺណែវលើកទី៤» ត្រូវបានអនុម័តដើម្បីការពារដល់ប្រជាជាតិនៃរដ្ឋជាភាគីខាងសង្គ្រាមមួយដែលនៅក្នុងទឹកដីដែលកាន់កាប់ ឬគ្រប់គ្រងដោយរដ្ឋបច្ចាមិត្តមួយទៀត ។ ដោយអនុសញ្ញានេះត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបចំពោះការផ្តល់ភាពការពារពុំបានគ្រប់គ្រាន់ដល់ប្រជាជាតិទាំងឡាយនៅក្នុងទឹកដីក្រោមការគ្រប់គ្រងរបស់ខ្លួនក្នុងអំឡុងសង្គ្រាមលោកលើកទី២ អនុសញ្ញាក្រុងហ្សឺណែវលើកទី៤នេះ ការពារជនស៊ីវិលទាំងអស់ឲ្យរួចផុតពីការប្រព្រឹត្តឃោរឃៅព្រៃផ្សៃ ឬធ្វើបាបគ្រប់បែបយ៉ាង ។ អនុសញ្ញានេះអនុវត្តចំពោះជនស៊ីវិលដែលមិនមែនជាយុទ្ធជន ។ ការអនុវត្តន៍អនុសញ្ញាក្រុងហ្សឺណែវលើកទី៤នេះ ចំពោះប្រទេសកម្ពុជាអាចនឹងបង្កើតនូវកម្រិតមួយដែលអាចអនុវត្តបានចំពោះជនស៊ីវិលទាំងអស់ក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធមួយ ។

ជនស៊ីវិលទាំងឡាយនៅក្នុងដែនដីដែលគ្រប់គ្រងដោយបច្ចាមិត្ត មានសិទ្ធិទទួលការការពារមិនឲ្យមានការប្រព្រឹត្តអំពើព្រៃផ្សៃគ្រប់បែបយ៉ាងមកលើខ្លួន ហើយប្រសិនបើឃុំឃាំងប្រជាជនស៊ីវិលទាំងនោះ ត្រូវទទួលបាននូវល័ក្ខខ័ណ្ឌដែលឆ្លើយតបទៅនឹងកម្រិតជាអប្បបរមានៃអនុសញ្ញាទីក្រុងហ្សឺណែវទី៤ ។ អនុសញ្ញានេះហាមឃាត់ការនិរទេសជនស៊ីវិលពីដែនដីរបស់ខ្លួនឲ្យទៅរស់នៅក្នុងទឹកដីរបស់រដ្ឋបច្ចាមិត្ត ឬទៅកាន់រដ្ឋដទៃទៀតទោះបីក្នុងមូលហេតុណាក៏ដោយ ។ ការឃុំឃាំងនិងការជម្លៀសក្រុមជនជាតិភាគតិចទាំងហ្វូងដូចដែលបានកើតឡើងនៅក្នុងអតីតប្រទេសយូហ្គោស្លាវី គឺជាការរំលោភយ៉ាងច្បាស់ក្រឡែតលើ





អនុសញ្ញាក្រុងហ្សឺណែវលើកទី៤ ហើយល័ក្ខខ័ណ្ឌដែលឃុំឃាំង ជនស៊ីវិលទាំងនោះ ក៏ជាការរំលោភបំពានចំពោះអនុសញ្ញានេះ ដែរ ។ ការជម្លៀសជនស៊ីវិល និងការសម្លាប់បំផុតពូជ និងការ ឃុំឃាំងក្រុមជនជាតិ និងសាសនា គឺតំណាងឲ្យការរំលោភបំពាន ទៅលើកម្រិតច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលបង្កើតឡើង ដោយច្បាប់សង្គ្រាម ។

## ខ. អ្នករបួស និងអ្នកជំងឺក្នុងពេលសង្គ្រាម

ភាពការពារតាមផ្លូវច្បាប់ដែលផ្តល់ឲ្យអ្នករបួស និង អ្នកជំងឺ និងបុគ្គលិកពេទ្យដែលមើលថែទាំ អាចត្រូវបានសង្ខេប យ៉ាងខ្លីថាជាភារកិច្ច២ៈ ទី១ [ភារកិច្ចអវិជ្ជមាន] គឺមិនត្រូវបង្ក គ្រោះថ្នាក់ដល់អ្នករបួស ឬអ្នកមើលថែទាំអ្នករបួសឡើយ ។ ទី២ [ភារកិច្ចវិជ្ជមាន] គឺត្រូវជួយដល់បច្ចាមិត្តដែលរងរបួសក្នុងពេល សង្គ្រាម ។ អ្នករបួសទាំងអស់នោះត្រូវបានតម្រូវដោយអនុសញ្ញា នេះនូវសិទ្ធិក្នុងការទទួលការព្យាបាល ការផ្តល់ថ្នាំដូចគ្នានឹង អ្នករបួស ឬអ្នកជំងឺជាពលរដ្ឋនៃប្រទេសម្ខាងទៀតដែរ ។ ការផ្តល់អត្ថិភាពក្នុងចំណោមអ្នកជំងឺត្រូវបានកំណត់ឡើងដោយ ការពិចារណា យោងទៅតាមសភាពចាំបាច់នៃការផ្តល់ថ្នាំព្យាបាល មិនមែនយោងទៅតាមសញ្ជាតិ អត្តសញ្ញាណកម្ម ឬឋានៈឡើយ ។

មធ្យោបាយដឹកជញ្ជូនថ្នាំពេទ្យ មន្ទីរពេទ្យ និងកន្លែងរុំ របួសសម្រាប់កងកម្លាំងយោធារបស់ភាគីទាំង២ និងគ្រឿង បរិក្ខារពេទ្យរបស់ជនស៊ីវិលត្រូវបានការពារដោយពិធីសារបន្ថែម ទី១ មិនត្រូវធ្វើការវាយប្រហារឡើយ លុះត្រាណាតែមធ្យោបាយ ទាំងនេះ ត្រូវបានប្រើប្រាស់ក្នុងគោលបំណងបម្រើសកម្មភាព យោធាជាខែលការពារការវាយប្រហារយោធា ដូចដែលចែង នៅក្នុងអនុសញ្ញាក្រុងហ្សឺណែវ ។ អ្នកដឹកជញ្ជូនបរិក្ខារពេទ្យដែល មានសញ្ញាកាកបាទក្រហម ឬសញ្ញាចំណិតលោកខែត្រូវទទួល នូវការការពារយ៉ាងតឹងរឹងដោយអនុសញ្ញានេះ ហើយនិងមិន ត្រូវធ្វើការវាយប្រហារទៅលើបុគ្គលិកពេទ្យទេ លុះត្រាតែ បុគ្គលិកទាំងនោះប្រព្រឹត្តសកម្មភាពដែលបង្កគ្រោះថ្នាក់ដល់ភាគី សត្រូវដែលមិនមែនជាតួនាទីផ្នែកមនុស្សធម៌របស់ខ្លួន ។ ការ ប្រព្រឹត្តសងសឹកលើអ្នករបួស ឬអ្នកជំងឺក្នុងសង្គ្រាម ជនរង គ្រោះដោយលិចកប៉ាល់ឬជាសមាជិកនៃអង្គភាពពេទ្យត្រូវបាន ហាមប្រាមជាដាច់ខាត ។ ដោយអនុលោមទៅតាមអនុសញ្ញា ក្រុងហ្សឺណែវទី៤ការជ្រៀតជ្រែកជីវភាពរស់នៅរបស់ជនស៊ីវិល ឬភារកិច្ចទីភ្នាក់ងារទាំងឡាយដែលប៉ុនប៉ងជួយសង្គ្រោះជនរង គ្រោះឲ្យផុតពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក៏ត្រូវបានហាម ប្រាមដែរ ។

**អាលីហ្សាប៊ែត ខាន់ស្កាក់**

---

**(តមកពីទំព័រទី២៨)** ត្រូវបានដឹងក្នុងចំណោមអ្នកដែលធ្លាប់បានធ្វើការ ឬត្រូវបានដាក់ពន្ធនាគារហើយនិងកម្មាភិបាលជាន់ខ្ពស់មួយក្តាប់ តូចហៅថា មជ្ឈិមបក្សដែលបានត្រួតពិនិត្យឯកសារនានា និង យោធា និងអង្គភាពដទៃទៀតដែលត្រូវធ្វើបទ្យុទ្ធកម្ម ។ អ្នកសួរ ចម្លើយ ស្មៀនកត់ត្រា អ្នកថតរូប អ្នកយាម និងចុងភៅ នៅគុក នេះត្រូវបានហាមមិនឲ្យរស់នៅឡុកឡំពាក់ព័ន្ធជាមួយអ្នកធ្វើការ នៅកន្លែងផ្សេង ហើយឆាប់ៗនោះបរិវេណនេះល្បីថាជាកន្លែង ដ៏គួរឲ្យភ័យខ្លាច ។ អ្នកធ្វើការនៅរោងចក្រម្នាក់ដែលកាលណោះ នៅក្នុងបរិវេណក្បែរនោះដែលបានផ្តល់បទសម្ភាសន៍មួយក្នុងឆ្នាំ ១៩៨៩ ចាត់ទុកមន្ទីរស-២១ ជា «កន្លែងដែលចូលទៅហើយ គ្មានថ្ងៃចេញមកវិញ» ។ អ្នកធ្វើការនៅរោងចក្រនៅក្បែរគុក នេះពុំច្បាស់មានអ្វីកើតឡើងនៅខាងក្នុងនោះឡើយ ក៏ប៉ុន្តែ ពេលនោះពួកគេត្រៀមខ្លួនគិតថាជាកន្លែងដ៏សាហាវបំផុតរួចទៅ ហើយ ។ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាពុំដែលនិយាយអំពីមន្ទីរ ស-២១ ដោយប្រើឈ្មោះនេះឡើយ ។ ឆ្នាំ ១៩៩៧ នៅពេល ដែលអ្នកកាសែតឈ្មោះ នេត ថេយ័រ បានសួរ ប៉ុល ពត, ប៉ុលពត បានបដិសេធថា ខ្លួនពុំបានដឹងអំពី «ទួលស្លែង» ដោយចង់បង្ហាញ ថាសារមន្ទីរនិងបណ្ណាសារដ្ឋាននៅទួលស្លែង គឺជាការប្រឌិត ដោយវៀតណាម ។ ប៉ុល ពត និយាយថា «ខ្ញុំនៅខាងលើបំផុតខ្ញុំ ធ្វើការសម្រេចចិត្តធំៗ» ទួលស្លែង គឺជាកន្លែងតាំងពិពណ៌វៀត ណាម ។ អ្នកកាសែតម្នាក់ធ្លាប់បានសរសេរដូច្នោះ ។ មានការ និយាយគ្រប់គ្នាអំពីទួលស្លែង ទួលស្លែង ទួលស្លែង...នៅពេលដែល ខ្ញុំបានឮពីទួលស្លែងគឺតាមវិទ្យុផ្សាយសម្លេងរបស់សហរដ្ឋអាមេ រិក ។ ខ្ញុំបានស្តាប់ឮចំនួនពីរដង ។ **(នៅមានត)**

# ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា

ចំពោះយុទ្ធជនទាំងឡាយដែលពិតជាបានចូលប្រឡូក នៅក្នុងសង្គ្រាមប្រដាប់អាវុធ ហើយប្រឈមមុខនឹងភាពភ័យរន្ធត់នៃការតស៊ូប្រយុទ្ធស្លាប់រស់ជារៀងរាល់ថ្ងៃ វាជាការចម្លែកណាស់ដែលថារាល់សង្គ្រាមត្រូវបានគ្រប់គ្រងដោយច្បាប់ជាក់លាក់មួយជាជាងក្រឹត្យក្រមសង្គ្រាមដែលយុទ្ធជនទាំងនោះទទួលស្គាល់ថា «បើមិនសម្លាប់សត្រូវ សត្រូវនឹងសម្លាប់យើងវិញ» ។ ទោះបីជាយ៉ាងណាក៏ដោយ អំពើសាហាវឃោរឃៅបំផុតក្នុងភ្នក់ភ្លើង «សង្គ្រាមគ្រប់ប្រកល្ហក» នៃសតវត្សរ៍ទី២០ នេះដែលបានកើតឡើងក្រោមអណ្តាតភ្លើងនិងចុងអាវុធដែលក្នុងនោះប្រជាជនស៊ីវិលនៃបណ្តាប្រទេសជាច្រើន បានក្លាយជាផ្ទាំងស៊ីបនៃការបំផ្លិចបំផ្លាញនិងការកម្ទេចចោលឡុកឡំជាមួយនឹងកងកម្លាំងប្រដាប់អាវុធរបស់សត្រូវផងនោះ បានជម្រុញឲ្យមានការផ្តោតយកចិត្តទុកដាក់កាន់តែកើតឡើងថែមទៀតដល់កិច្ចព្រមព្រៀងអន្តរជាតិដែលធានាថា មធ្យោបាយធ្វើសង្គ្រាមពុំអាចប្រព្រឹត្តហួសពីច្បាប់អន្តរជាតិបានទេ ។ ច្បាប់អន្តរជាតិបានអភិវឌ្ឍន៍ជាបណ្តើរៗ ដោយមានគោលដៅចម្បងៗគឺដើម្បីធានាឲ្យបាននូវការការពារឲ្យបានគ្រប់គ្រាន់ដល់ជនស៊ីវិល និងឈ្លើយសឹកសង្គ្រាមក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ ។ នៅត្រង់ចំណុចនេះគួរបញ្ជាក់ឲ្យច្បាស់ទាំងស្រុងថា គោលគំនិតនៃ «ឧក្រិដ្ឋកម្មសង្គ្រាម» ពុំបានរាប់បញ្ចូលអំពើស្របច្បាប់របស់កូនទាហានដែលអនុវត្តភារកិច្ចរបស់ខ្លួនតាមមេ











បញ្ហាការនៅក្នុងពេលសង្គ្រាមបានទេ ។ ជាការច្បាស់ណាស់ភារកិច្ចរបស់កូនទាហាននៅក្នុងពេលសង្គ្រាមហើយជានិច្ចកាលគឺជាភារកិច្ចទៅដែលត្រូវចូលប្រយុទ្ធហើយសម្លាប់សត្រូវក្នុងសង្គ្រាម ។ នេះជាចរិតនៃសង្គ្រាម ហើយតុលាការខ្មែរក្រហមដែលបានស្នើបង្កើតឡើងពុំមានអ្វីទាក់ទងទាល់តែសោះទៅនឹងការដាក់ទណ្ឌកម្មកូនទាហានយោធាខ្មែរក្រហមចំពោះការដែលកូនទាហានទាំងនោះអនុវត្តភារកិច្ចស្របច្បាប់របស់ពួកគេក្នុងឋានៈជាកូនទាហានក្នុងពេលប្រយុទ្ធក្នុងសង្គ្រាមនោះឡើយ ។

បរិយាយជាសង្ខេបចំពោះគោលបំណងនៃការដាក់ឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌមកលើមេដឹកនាំខ្មែរក្រហម«ឧក្រិដ្ឋកម្មសង្គ្រាម»នឹងមានសារៈសំខាន់ត្រង់២ចំណុច ។ ចំណុចទី១ឧក្រិដ្ឋកម្មសង្គ្រាមនឹងអាចធ្វើការចោទប្រកាន់ដោយឯករាជ្យចំពោះការរំលោភបំពាន និងការកាប់សម្លាប់ជនស៊ីវិលរបស់សត្រូវ និងឈ្លើយសឹកសង្គ្រាមរបស់បណ្តាប្រទេសទាំងឡាយដែលរបបខ្មែរក្រហមបានប្រឡូកក្នុងសង្គ្រាមជាមួយ (មានន័យថាប្រទេសវៀតណាមនិង ខ្លះទៀតអាចទាញហេតុផលបញ្ចូលទាំងប្រទេសថៃផង) ។ ទី២ នៅពេលដែលខ្ញុំបានអាននិងសិក្សាអត្ថបទរបស់ទស្សនាវដ្តីស្វែងរកការពិតលេខទី១ កាលពីខែមករា កន្លងមកនេះ ការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធអន្តរជាតិទាំងនោះនឹងមានសារៈសំខាន់ត្រង់ថា តើអង្គជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមដែលនឹងរៀបចំឡើងក្នុងពេលខាងមុខនេះនឹងកំណត់ថា «សម្ព័ន្ធភាពជម្លោះប្រដាប់អាវុធ» ដែលជាតម្រូវការសម្រាប់ការកាត់ទោសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺនៅតែយកមកគិត ឬនៅជាធរមាននៅក្នុងរបបខ្មែរក្រហមដែរឬយ៉ាងណា ។ នៅក្នុងករណីនោះទំនាក់ទំនងរវាងការកាប់សម្លាប់របស់ខ្មែរក្រហម មកលើជនស៊ីវិលបរទេស និងឈ្លើយសឹកសង្គ្រាម (ករណីឧក្រិដ្ឋកម្មសង្គ្រាម) និងការកាប់សម្លាប់ដ៏ច្រើនសន្ធឹកសន្ធាប់មកលើពលរដ្ឋកម្ពុជានៃរបបនេះដោយចោទថាជា «ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង» របស់អង្គការ (ករណីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) នឹងមានសារៈសំខាន់យ៉ាងខ្លាំង ។ សម័យរបបខ្មែរក្រហមគោលគំនិតនៃ «ឧក្រិដ្ឋកម្មសង្គ្រាម» ពុំទាន់ត្រូវបានយកមកអនុវត្តន៍ ចំពោះសង្គ្រាមស៊ីវិលដែលពុំមានលក្ខណៈជាអន្តរជាតិដូចក្នុងករណីដែលបានកើតឡើងក្នុងប្រទេសកម្ពុជារវាងឆ្នាំ១៩៧០ និងឆ្នាំ១៩៧៥ ហើយ «ឧក្រិដ្ឋកម្មសង្គ្រាម» នេះក៏ពុំអនុវត្តចំពោះអំពើរបស់រដ្ឋាភិបាលខ្មែរក្រហមមកលើពលរដ្ឋកម្ពុជារបស់ខ្លួនដូចដែលបានកើតឡើងបន្ទាប់ពីសង្គ្រាមស៊ីវិលនៅកម្ពុជាក្រោមរបបខ្មែរក្រហមចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ដែរ ។ ដោយសារថា គោលការណ៍គ្រឹះនៃច្បាប់ព្រហ្មទណ្ឌចែងថា មនុស្សម្នាក់ពុំអាចត្រូវបាននាំយកមកកាត់ទោស ឬដាក់ទណ្ឌកម្មចំពោះអំពើទាំងឡាយដែលក្នុងពេលប្រព្រឹត្តអំពើនោះពុំមានច្បាប់ណាមួយកំណត់ថាជាបទឧក្រិដ្ឋនោះការនាំយកមកកាត់ទោសអំពី «បទឧក្រិដ្ឋកម្មសង្គ្រាម» ពាក់ព័ន្ធទៅនឹងអំពើទាំងឡាយដែលត្រូវបានប្រព្រឹត្តក្រោមបរិបទនៃជម្លោះអន្តរជាតិរបស់កម្ពុជានៅក្នុងសម័យខ្មែរក្រហមពុំអាចធ្វើទៅបានឡើយ ។

នៅក្នុងបរិបទនៃ«អំពើប្រល័យពូជសាសន៍នៅកម្ពុជា» ការលើកយកមកពិចារណាខក្រិដ្ឋកម្មសង្គ្រាមដែលត្រូវបាន ប្រព្រឹត្តក្រោមរបបខ្មែរក្រហមប្រឆាំងនឹងប្រជាជនវៀតណាម អាចប៉ះពាល់ទៅលើអារម្មណ៍ដែលងាយនឹងមានការប៉ះទង្គិចផ្នែក នយោបាយមកលើប្រជាជនកម្ពុជាជាច្រើន ។ យើងអាចចោទសួរ ថា «ហេតុអ្វីបានជាត្រូវយកការកាប់សម្លាប់ប្រជាជនស៊ីវិល និងឈ្លើយសឹកសង្គ្រាមវៀតណាម មកធ្វើជាប្រធានបទនៃអង្គ ជំនុំជម្រះក្តីមួយដែលមានគោលដៅសម្រេចឲ្យបាននូវការផ្តល់ យុត្តិធម៌សម្រាប់ប្រជាជនកម្ពុជាទៅវិញ? ក្នុងនាមជាពលរដ្ឋ នៃប្រទេសមួយ(អាមេរិក) ដែលរួមចំណែកទទួលខុសត្រូវ ចំពោះអំពើសាហាវយង់ឃ្នងពីអតីតកាលប្រឆាំងនឹងប្រជាជន កម្ពុជា ព្រមទាំងប្រជាជនវៀតណាមដែរ ខ្ញុំមិនអាចយកប្រធាន បទនេះមកពិភាក្សាសើៗបានទេ ។ ចម្លើយដ៏សាមញ្ញគឺថានៅក្នុង បរិបទនៃអង្គជំនុំជម្រះមួយ ដែលឥឡូវនេះកំពុងតែត្រូវបាន រំពឹងទុកថា នឹងនាំយកមេដឹកនាំខ្មែរក្រហមដែលនៅរស់មកដាក់ ឲ្យទទួលខុសត្រូវចំពោះការរំលោភបំពានសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ដែលត្រូវបានប្រព្រឹត្តនៅក្នុងរបបនេះ ច្បាប់តម្រូវថាជនរងគ្រោះ ទាំងអស់ក្នុងនាមជាមនុស្សជាតិទូទៅមានសិទ្ធិស្វែងរកយុត្តិធម៌ ។ ការទទួលរងការឈឺចាប់របស់មនុស្សពុំមានការបែងចែកដោយ ផ្អែកលើពូជសាសន៍នេះសាសនានេះ ឬជនជាតិនេះនោះទេ ។ គោលដៅនៃតុលាការនេះគឺដើម្បីស្វែងរកយុត្តិធម៌សម្រាប់អ្នក ទាំងឡាយណាដែលបានទទួលរងការឈឺចាប់ក្រោមអំពើឃោរ ឃៅព្រៃផ្សៃដ៏ច្រើនឥតគណនាក្រោមការគ្រោងទុករបស់របប ដឹកនាំខ្មែរក្រហម ។

អ្នកអាននឹងចាប់អារម្មណ៍ថាខ្ញុំបាននិយាយម្តងហើយ ម្តងទៀតអំពីការទទួលខុសត្រូវនៃរបបដឹកនាំខ្មែរក្រហម ចំពោះ ខក្រិដ្ឋកម្មសង្គ្រាមដូចដែលត្រូវបានលើកយកមកនិយាយស្រដៀង គ្នានេះកាលពីលេខមុនអំពីការទទួលខុសត្រូវរបស់មេដឹកនាំរបប ខ្មែរក្រហមចំពោះខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយខ្ញុំនឹង យកមកនិយាយនៅក្នុងលេខខាងមុខអំពីការទទួលខុសត្រូវចំពោះ អំពើប្រល័យពូជសាសន៍ ។ អ្នកអានអាចងឿងឆ្ងល់ថា ធ្វើយ៉ាង ដូចម្តេច ទើបអាចដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការ ធ្វើទារុណកម្ម និងការកាប់ សម្លាប់ចំពោះអ្នកទាំងឡាយ ដែលពុំបានប្រព្រឹត្តអំពើ ទាំងនោះដោយផ្ទាល់សោះ នោះ ។ ចម្លើយគឺស្ថិតនៅ ត្រង់គោលការណ៍ច្បាប់២ ដែលឈានដល់ការធានា ឲ្យប្រាកដថា បុគ្គលដែល ពិតប្រាកដទទួលខុសត្រូវ ចំពោះអំពើរំលោភបំពាន សិទ្ធិមនុស្សដ៏ព្រៃផ្សៃត្រូវ បានដាក់ទណ្ឌកម្មចំពោះ ខក្រិដ្ឋកម្មរបស់ពួកគេ ។ គោលការណ៍ច្បាប់ទាំង២ នេះគឺ «ការឃុបឃិត» និង«ការទទួលខុសត្រូវលើ បទបញ្ជា» ។ ដោយអនុ លោមទៅតាមច្បាប់ស្តីអំពី «ការឃុបឃិត»មនុស្ស ម្នាក់ត្រូវទទួលខុសត្រូវ ចំពោះអំពើខក្រិដ្ឋដែលខ្លួន ពុំពិតប្រាកដជាបានប្រព្រឹត្ត ដោយផ្ទាល់ដែលបុគ្គលនោះ គ្រាន់តែបានជួយជ្រោមជ្រែង ក្នុងការរៀបចំផែនការញុះ ញង់ ឬបញ្ជាឲ្យអំពើបែប នេះត្រូវបានប្រព្រឹត្ត ។ ហេតុដូច្នេះហើយរដ្ឋមន្ត្រី របស់រដ្ឋាភិបាលមួយរូប ដែលជំរុញលើកទឹកចិត្ត ឬបញ្ជាឲ្យមន្ត្រីថ្នាក់ក្រោម របស់ខ្លួនប្រព្រឹត្តបទខក្រិដ្ឋ











មួយអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌបានចំពោះអំពើទាំងនោះដូចគ្នាទៅនឹងការដែលរដ្ឋមន្ត្រីរូបនោះបានប្រព្រឹត្តដោយផ្ទាល់យ៉ាងដូច្នេះដែរ ។ ឧទាហរណ៍មួយទៀត គឺក្នុងស្ថានការណ៍មួយដែលបុគ្គលជាច្រើនរៀបផែនការសម្រាប់នរណាម្នាក់ ហើយបុគ្គលតែម្នាក់គត់ជាអ្នកដៃដល់ក្នុងការអនុវត្តន៍ការសម្លាប់នោះ ។ បុគ្គលទាំងឡាយដែលបានជួយក្នុងការរៀបចំផែនការនោះ ប៉ុន្តែពុំបានចូលរួមក្នុងការសម្លាប់នោះក៏អាចដាក់ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការសម្លាប់នោះអំពីបទ «ការឃុបឃិត» ដូចជាបុគ្គលទាំងនោះបានកេះកៃកាំភ្លើងបាញ់សម្លាប់ដោយផ្ទាល់ដៃដូច្នោះដែរ ។ ជាបន្ថែមទៀតនោះ ការដែលគ្រាន់តែបានដឹងអំពីអំពើឧក្រិដ្ឋកម្មមួយ និងផ្តល់ជំនួយក្នុងការធ្វើឲ្យជនដៃដល់គេចវេសពីការនាំយកមកកាត់ទោសអាចបង្កើតជាមូលដ្ឋានសម្រាប់ការដាក់ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌបានដោយផ្អែកលើគោលការណ៍ច្បាប់នៃ «ការឃុបឃិត» នេះដែរ ។ អនុលោមទៅតាមគោលការណ៍នៃ «ការទទួលខុសត្រូវលើការបញ្ជា» ដែលពាក់ព័ន្ធដូចដែលបានលើកយកមកពិភាក្សាយ៉ាងក្បោះក្បាយនៅក្នុងទស្សនាវដ្តី «ស្វែងរកការពិត» ពីលេខទី១ មេបញ្ជាការយោធាឬស៊ីវិលអាចដាក់ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តដោយមន្ត្រីនៅក្រោមបង្គាប់ ហើយមេបញ្ជាការបាននោះដឹង ឬមានហេតុផលត្រូវដឹងនិងមានអំណាចទប់ស្កាត់ឬដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្ម ហើយខកខានពុំបានធ្វើដូច្នោះ ។ ដូចដែលបានធ្វើការកត់សម្គាល់នៅក្នុងអត្ថបទដែលបានបកស្រាយក្នុងលេខមុនដែរ ច្បាប់ស្តីអំពីការទទួលខុសត្រូវលើការបញ្ជានឹងដើរតួនាទីដ៏សំខាន់ នៅក្នុងការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយខ្ញុំមានបំណងចង់ទាញហេតុផលផ្សេងនៅក្នុងអត្ថបទលើកក្រោយខ្ញុំសូមបញ្ជាក់ក្នុងពេលនេះថា អត្ថបទក្នុងលេខទី១គឺជាគំនិតរបស់អ្នកនិពន្ធនោះប៉ុណ្ណោះ ដែលថាមានភ័ស្តុតាងឯកសារដែលមានទម្ងន់គួរឲ្យជឿបានដែលទំនងជាចង្អុលបង្ហាញថា ការសម្លាប់ជាច្រើនដែលស្តែងឲ្យឃើញថា ត្រូវបានប្រព្រឹត្តតាមទំនើងចិត្តមកលើប្រជាពលរដ្ឋកម្ពុជា ក្រោមរបបខ្មែរក្រហម គឺជាលទ្ធផលនៃការបញ្ជាពិតប្រាកដចេញពីថ្នាក់លើបំផុតរបស់របបនេះមក ។ ការពិតថាមេដឹកនាំខ្មែរក្រហមមានគោលនយោបាយផ្ទេរអំណាចក្នុងការកំណត់អត្តសញ្ញាណកម្មជនទាំងឡាយដែលជា «ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង» ទៅកម្មាភិបាលថ្នាក់ក្រោមយើងអាចធ្វើការស្រាវជ្រាវរកឃើញថាតាមរយៈការផ្ទេរអំណាច ហើយជាមួយគ្នានោះផ្តល់សិទ្ធិកម្មាភិបាលថ្នាក់ក្រោមឲ្យសម្លាប់ «សត្រូវបង្កប់ស៊ីរូងផ្ទៃក្នុង» មេដឹកនាំខ្មែរក្រហមបានបញ្ជាយ៉ាងមានប្រសិទ្ធិភាពនូវការសម្លាប់រង្គាលមកលើប្រជាជនកម្ពុជារួចទៅហើយ ។ លើសពីនេះបុគ្គលទាំងឡាយណាដែលត្រូវបានបង្ហាញថាជាភាគីចូលរួមក្នុងការអនុម័តគោលនយោបាយទាំងនោះ ទោះជាបុគ្គលនោះនៅ ឬក៏មិននៅក្នុងខ្សែសង្វាក់នៃការបញ្ជាដ៏មានប្រសិទ្ធិភាពដែលជាចំណុចសំខាន់នៃគោលការណ៍ច្បាប់នៃ «ការទទួលខុសត្រូវលើបទបញ្ជា» ក៏ដោយក៏ត្រូវដាក់ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការសម្លាប់រង្គាលដែលបណ្តាលមកពីការអនុវត្តន៍គោលនយោបាយទាំងនេះដោយផ្ទាល់ ឬផលវិបាកដែលអាចប្រមើលមើលឃើញថានឹងបណ្តាលមកពីគោលនយោបាយទាំងនេះ ។ ត្រឡប់ទៅប្រធានបទអំពីឧក្រិដ្ឋកម្មសង្គ្រាមវិញភ័ស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់និងគួរឲ្យអាចជឿបានដែលមានស្រាប់ចង្អុលបង្ហាញថា នៅក្នុងអំឡុងសង្គ្រាមតាមព្រំដែនរវាងខ្មែរក្រហមជាមួយវៀតណាម និងថៃឡង់ដ៍ ទ័ពខ្មែរក្រហមបានចូលប្រឡូកក្នុងការកាប់សម្លាប់ដ៏ច្រើនសន្ធឹកសន្ធាប់មកលើប្រជាជនស៊ីវិលរបស់ប្រទេសជិតខាងទាំងពីរ ។ ជាឧទាហរណ៍ ទូរសារមួយមកពីមិត្ត «ឈាន» ដែលចុះកាលបរិច្ឆេទថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៧ ហើយត្រូវបានចម្លងទៅឲ្យ អៀងសារី បាននិយាយអំពីឧប្បត្តិហេតុនេះ ដែលបានកើតឡើងនៅក្នុងខែមិថុនា ឆ្នាំ១៩៧៥ នៅឯកោះប៉ូលូវៃ ដែលក្នុងព្រឹត្តិការណ៍នោះប្រជាជនវៀតណាមចំនួន៥១៥នាក់ ត្រូវបានចាប់ពង្រាត់ដោយកងកម្លាំងខ្មែរក្រហម ហើយបាត់រហូតពុំដែលត្រូវបានធ្លាប់ឮជាថ្មីម្តងទៀតឡើយ ។

ឯកសារដដែលនេះក៏បានបញ្ជាក់ពី «ការខូចខាតដ៏ច្រើនចំពោះប្រជាជនវៀតណាម ...ទាំងជីវិតនិងទ្រព្យសម្បត្តិ» ដែលបណ្តាលមកពីកងកម្លាំងប្រដាប់អាវុធខ្មែរក្រហមនៅក្នុងការលុកលុយឆ្លងព្រំដែនចាប់ពីខេត្តហាទៀងមកដល់តាយនិញ ហើយនិយាយអំពីប្រជាជនស៊ីវិលវៀតណាមចំនួន១១៣នាក់

ដែលត្រូវបានចាប់ពង្រាត់ចេញពីខេត្តកន្ទុំនៅវៀតណាម ។ របាយការណ៍អង្គប្រជុំ ខែសីហា ឆ្នាំ១៩៧៨ របស់ខ្មែរក្រហមបាននិយាយថា«ប្រជាជនវៀតណាម មួយរយនាក់ទាំងក្មេង-ចាស់ ធំ-តូច »ត្រូវបាន«កម្ទេច» ។

យោងទៅតាមសេចក្តីរាយការណ៍របស់លោក ឆាលី បោវិរ ថាមានប្រជាជនវៀតណាម គាន់ឡាប់ ៥០០នាក់ នៅខេត្តតាយនិញ ត្រូវបានសម្លាប់យ៉ាងរង្គាលនៅក្នុងការវាយឆ្មក់នានារបស់ខ្មែរក្រហមនៅចុងខែកញ្ញា ឆ្នាំ១៩៧៧ ។ ការវាយឆ្មក់ទាំងនេះរួមបញ្ចូលទាំងព្រឹត្តិការណ៍នានាដូចជា កូនក្មេងត្រូវបានចងដោយខ្សែលួសហើយទម្លាក់ចុះទៅក្នុងអណ្តូងមួយទារកមួយត្រូវហែកជាពីរដោយប្រើកែងជើង ហើយស្ត្រីមានផ្ទៃពោះដែលត្រូវបានវះពោះ ហើយកុមារដែលមិនទាន់គ្រប់ខែកើតត្រូវបានខ្វេះពន្លូតចេញហើយ យកមកគប់លើផ្ទៃមុខម្តាយ ។

ឯកសារដែលមានតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាចង្អុលបង្ហាញថាមធ្យោបាយដែលត្រូវបាននិយាយមកនេះត្រូវបានប្រើប្រាស់ជាច្រើនលើកច្រើនសារទៀត ។ អំពើទាំងនេះថែមទាំងឧទាហរណ៍ពីរបីទៀតនៃឧក្រិដ្ឋកម្មសង្គ្រាម ដែលត្រូវបានរក្សាជាឯកសារ ត្រូវបានប្រព្រឹត្តដោយទ័ពខ្មែរក្រហមមកលើជនស៊ីវិលប្រទេសវៀតណាម ។ មិនតែប៉ុណ្ណោះភ័ស្តុតាងដែលមានស្រាប់បានចង្អុលបង្ហាញថា អំពើឃោរឃៅស្រដៀងគ្នានេះ ទោះបីជាធ្ងន់ធ្ងរតិចជាងក៏ដោយត្រូវបានប្រព្រឹត្តមកលើជនស៊ីវិលថៃ នៅក្នុងការវាយឆ្មក់តាមព្រំដែនដោយទ័ពខ្មែរក្រហម ។ ជាឧទាហរណ៍កំណត់ហេតុដំណើរទស្សនកិច្ចគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនិស្តកម្ពុជា កាលពីខែសីហា ឆ្នាំ១៩៧៥ ទៅកាន់«ភូមិភាគបស្ចឹម» និយាយអំពី «ការកម្ទេច» កសិករថៃដែលត្រូវបានចោទដោយពុំមានសំអាងថាបានចូលមកធ្វើស្រូវនៅតាមដំនៀរដីខ្មែរតាមព្រំដែន ។

ក្នុងនាមជាបុគ្គលម្នាក់ដែលពុំធ្លាប់ដែលទទួលរងនូវអំពើដ៏ភ័យរន្ធត់និងការលំបាកយ៉ាប់យឺននៃសង្គ្រាម ខ្ញុំបានពិភាក្សាអំពីប្រធានបទឧក្រិដ្ឋកម្មសង្គ្រាមទាំងអារម្មណ៍ដ៏គួរឲ្យរអៀសខ្លួន ។ កូនទាហានទាំងឡាយ ជាពិសេសទាហានវ័យក្មេង គឺតាមពិតជាជនរងគ្រោះនៃភាពសាហាវឃោរឃៅនៃសង្គ្រាម ដែលបណ្តាកូនទាហានទាំងនោះត្រូវបានដាក់ក្នុងស្ថានការណ៍មួយដែលត្រូវតែប្រយុទ្ធ ។

មានភ័ស្តុតាងជាច្រើនទំនងជាសំដៅបង្ហាញថាសារជាតិដ៏សាហាវយង់ឃ្នង ជាពិសេសនៃជម្លោះប្រដាប់អាវុធអន្តរជាតិឆ្លុះបញ្ចាំងអំពីភាពសាហាវយង់ឃ្នងនៃសង្គ្រាមនយោបាយរបស់របបដឹកនាំខ្មែរក្រហមមកលើប្រជាជនកម្ពុជា ។ ការជំនុំជម្រះរបបដឹកនាំខ្មែរក្រហមពីបទឧក្រិដ្ឋកម្មសង្គ្រាមប្រឆាំងនឹងកសិករវៀតណាមនិងថៃ និងជាទិដ្ឋភាពដ៏មានសារៈសំខាន់មួយនៃការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជាដែរ ។

**ររម៉ិន ចូហាន់សិន**

◆ **ខ្នះខ្នែងកម្ទេចកម្លាំងខ្មាំង ថែរក្សានិងបំប៉នកម្លាំងយើង កាន់តែខាយកាន់តែខ្លាំង កាន់តែខាយកាន់តែឈ្នះ។**

(ពាក្យស្លោកខ្មែរក្រហមៈ សៀវភៅលេខ២០០កណាហ) ។

◆ **កម្ចាត់ជាច់ខាត ភ្នាក់ងារសេ.អ៊ី.អា ឱ្យអស់រលីងពីអង្គការ និងពីទឹកដីកម្ពុជាជារៀងរហូត។**

(ពាក្យស្លោកខ្មែរក្រហមៈ សៀវភៅលេខ១០៧៦កណាហ) ។











# វិធានស្ដីអំពីភស្តុតាងក្នុងអង្គជំនុំជម្រះក្ដីខ្មែរក្រហមៈ "ពាក្យចចាមអារ៉ាម និងចម្លើយសារភាព"

នៅក្នុងដំណើរការជំនុំជម្រះក្ដីតាមផ្លូវច្បាប់ តុលាការ ឬអង្គជំនុំជម្រះក្ដីដែលទទួលខុសត្រូវអនុវត្តទៅតាមវិធានដែលគ្រប់គ្រងលើប្រភេទភស្តុតាងដែលតុលាការឬអង្គជំនុំជម្រះក្ដីនេះអាចនឹងពិចារណានៅក្នុងការវិនិច្ឆ័យរឿងក្ដី ដែលកំពុងប្រព្រឹត្តទៅ ។ ជាទូទៅតុលាការអចិន្ត្រៃយ៍គោរពទៅតាមវិធានស្ដីអំពីភស្តុតាងដែលត្រូវបានបង្កើតឡើងដោយលក្ខន្តិកៈ ឬសាលក្រមតុលាការដែលធ្លាប់បានវិនិច្ឆ័យពីពេលមុនមក ។ ស្រដៀងគ្នានេះដែរ អង្គចៅក្រមនៃតុលាការឬអង្គជំនុំជម្រះក្ដីពិសេសតាមធម្មតាត្រូវអនុម័តនូវវិធានស្ដីអំពីភស្តុតាងថ្មីមួយមុនពេលបើកសវនាការ ។ ដោយសារថារដ្ឋាភិបាលកម្ពុជាសម្រេចលើវេទិកាជំនុំជម្រះក្ដីខ្មែរក្រហមដែលនឹងកើតឡើងនៅពេលខាងមុខនេះដោយធ្វើការពិភាក្សាជាមួយសហគមអន្តរជាតិវិធានស្ដីអំពីភស្តុតាងដែលនឹងត្រូវយកមកអនុវត្តដោយតុលាការ ឬអង្គជំនុំជម្រះក្ដីដែលត្រូវបានប្រគល់អំណាចបង្កើតបានជាចំណុចពិភាក្សាផ្នែកច្បាប់មួយដ៏សំខាន់ ។

វិធានស្ដីអំពីភស្តុតាងដែលនឹងត្រូវបានអនុម័តដោយតុលាការ ឬអង្គជំនុំជម្រះក្ដីមួយអាចជះឥទ្ធិពលដ៏សំខាន់ខ្លាំងចំពោះលទ្ធផលនៃការជំនុំជម្រះព្រហ្មទណ្ឌមួយ ពីព្រោះវិធានទាំងនេះហើយដែលគ្រប់គ្រងប្រភេទភស្តុតាង ដែលអាចត្រូវបានប្រើប្រាស់ដោយព្រះរាជអាជ្ញានិងមេធាវីចុងចោទ ។ វិធានស្ដីអំពីភស្តុតាងមានសារៈសំខាន់ជាពិសេសចំពោះភស្តុតាងដែលមានភាពមន្ទិលសង្ស័យចំពោះភាពយកជាការបានដែលអាច ឬមិនអាចទទួលទម្ងន់ច្រើននៅក្នុងការពិចារណារបស់តុលាការ ។ នៅក្នុងការជំនុំជម្រះក្ដីអតីតមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាដែលរំពឹងទុកថានឹងរៀបចំឡើងនៅពេលខាងមុខប្រភេទភស្តុតាងពីរដែលមានបញ្ហានោះគឺចំបាច់នឹងដើរតួនាទីដ៏សំខាន់ ។ ប្រភេទភស្តុតាងទាំងពីរនេះគឺពាក្យចចាមអារ៉ាម និងចម្លើយសារភាព ។ អត្ថបទនេះពិភាក្សាជាសង្ខេបអំពីបញ្ហាទាំងឡាយដែលលេចចេញពីការប្រើប្រាស់ពាក្យចចាមអារ៉ាម និងចម្លើយសារភាពធ្វើជាភស្តុតាង និងអំពីសារៈសំខាន់នៃវិធានស្ដីអំពីភស្តុតាងក្នុងការកំណត់ថាតើពាក្យចចាមអារ៉ាម និងចម្លើយសារភាពទាំងនោះត្រូវបានពិចារណាយ៉ាងដូចម្ដេច ដោយតុលាការឬអង្គជំនុំជម្រះក្ដីនោះ ។

## ១-ពាក្យចចាមអារ៉ាម

និយមន័យច្បាប់តាមកម្រិតស្តង់ដារនៃពាក្យចចាមអារ៉ាមគឺ «ចម្លើយក្រៅអង្គតុលាការ ដើម្បីបញ្ជាក់បន្ថែមអំពីការពិតនៃបញ្ហានេះដែលបានដាក់ជូនជាភស្តុតាងនៅក្នុងតុលាការ» ។ ជាឧទាហរណ៍យើងស្រមៃថា សាក្សីម្នាក់បានបង្ហាញខ្លួននៅក្នុងតុលាការមួយហើយនិយាយថា «មិត្តភក្ដិរបស់ខ្ញុំឈ្មោះ មុំ បានប្រាប់ខ្ញុំថានាងបានឃើញ ប៉ុល ពត សម្លាប់ក្មេងស្លូតត្រង់ម្នាក់» កសិណរបស់ មុំ ត្រូវបានចាត់ទុកថាជាពាក្យចចាមអារ៉ាមពីព្រោះចម្លើយដែលទាក់ទងថា (ប៉ុល ពត បានសម្លាប់ក្មេងប្រុសស្លូតត្រង់ម្នាក់) ត្រូវបានផ្ដល់ឲ្យដោយបុគ្គលម្នាក់ដែលពុំនៅក្នុងបន្ទប់តុលាការ ក្នុងករណីនេះគឺ មុំ ដើម្បីបញ្ជាក់អំពីការពិតនៃបញ្ហាដែលដាក់ជូនតុលាការថា (ប៉ុល ពត បានសម្លាប់ក្មេងប្រុសស្លូតត្រង់ម្នាក់) ។

ពាក្យចចាមអារ៉ាម ត្រូវបានចាត់ទុកថាមានបញ្ហាពីព្រោះបុគ្គលដែលបានផ្ដល់ចម្លើយទាក់ទងនោះគឺពុំមានវត្តមាននៅក្នុងតុលាការ ។ អវត្តមានរបស់បុគ្គលនេះក្នុងបន្ទប់តុលាការធ្វើឲ្យចៅក្រម ឬមេធាវីការពារចុងចោទពុំអាចចោទសួរគាត់ហើយនិងកំណត់ពីសុក្រឹតភាពរបស់ចម្លើយរបស់គាត់បាន ។ ជាលទ្ធផលពាក្យចចាមអារ៉ាមជាទូទៅត្រូវបានចាត់ទុកថា មានតម្លៃអាចជឿជាក់បានតិចជាងភស្តុតាងប្រភេទដទៃទៀត ហើយដោយអាស្រ័យទៅលើវិធានស្ដីអំពីភស្តុតាងជាក់លាក់ទាំងនោះដែលត្រូវបានអនុម័តដោយតុលាការ ឬអង្គជំនុំជម្រះក្ដីពាក្យចចាមអារ៉ាមក៏អាចត្រូវបានទាត់ចោលដោយពុំយកមកពិចារណាជាមួយគ្នាបាន ។

ភស្តុតាងមួយផ្នែកដ៏សំខាន់ដែលអាចដាក់ទោសមន្ត្រីនៃ

បក្សកុម្មុយនិស្តកម្ពុជាអំពីបទឧក្រិដ្ឋកម្មដូចជាការប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើទារុណកម្មគឺពាក្យចចាមអារ៉ាមដែរ ។ ញត្តិទាំងឡាយដែលសរសេរដោយប្រជាជនកម្ពុជានៅក្នុងអំឡុងការគ្រប់គ្រងដោយវៀតណាម(១៩៨៣) ដែលមានចំនួនជាង១លាន ៥សែននាក់ គឺជាពាក្យចចាមអារ៉ាមលុះត្រាណាតែអ្នកសរសេរញត្តិទាំងនោះចូលខ្លួនមកក្នុងតុលាការ ឬអាចផ្តល់ចម្លើយដែលត្រូវបានធ្វើសច្ចាប្រណិធានត្រឹមត្រូវមួយដល់តុលាការនិងជាលាយល័ក្ខអក្សរ ។ ដូចគ្នាដែរតម្រូវឲ្យមានសច្ចាប្រណិធានចំពោះមុខតុលាការ ដូច្នេះចំពោះរបាយការណ៍អ្នកជំនាញ សំបុត្រឆ្លើយឆ្លង ចម្លើយសារភាព និងទម្រង់ភស្តុតាងឯកសារដទៃទៀតជាច្រើនដែលជាផ្នែកមួយនៃភស្តុតាងដ៏សំខាន់ដែលព្រះរាជអាជ្ញាអាចប្រើប្រាស់បាន ។




ពាក្យចចាមអារ៉ាមមួយចំនួនដែលបានពិភាក្សាបញ្ហាខាងលើនេះ អាចត្រូវបាន «ប៉ះប៉ូវជួសជុល» ដោយផ្តល់ចម្លើយសច្ចាប្រណិធាននិងកសិណសាក្សីផ្ទាល់ដែលធ្វើឲ្យតុលាការឬអង្គជំនុំជម្រះក្តីក៏ដូចជាមេធាវីខាងការពារចុងចោទអាចធ្វើការចោទសួរបញ្ជាក់អំពីភាពអាចជឿជាក់បានរបស់ពាក្យចចាមអារ៉ាមនោះ ។ ហេតុដូច្នេះការពិចារណាពាក្យចចាមអារ៉ាមក្រោមវិធានស្តីអំពីភស្តុតាងដែលត្រូវបានអនុម័តដោយតុលាការឬអង្គជំនុំជម្រះក្តីនឹងមានសារៈសំខាន់ខ្លាំងបំផុត ។

មានវិធីពីរយ៉ាងក្នុងការពិចារណាពាក្យចចាមអារ៉ាមក្រោមគោលការណ៍ច្បាប់និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ។ វិធីទី១គឺចេញមកពីប្រពៃណីនៃច្បាប់អង់គ្លោសាក់សុងប្រភពចេញពីអង់គ្លេស (English Common Law Tradition) ដែលពុំទទួលយកភស្តុតាង ពាក្យចចាមអារ៉ាមដែលពុំត្រូវទៅនឹងករណីលើកលែងណាមួយក្នុងចំណោមករណីលើកលែងដ៏ស្មុគស្មាញប្រហែលជា១៧ចំណុច ។ វិធីសំខាន់ទី២ដើម្បីពិចារណាពាក្យចចាមអារ៉ាម គឺទាញចេញដ៏លើសលប់មកពីទំនៀមទម្លាប់ច្បាប់ស៊ីវិលរបស់បារាំង (French Civil-Law Tradition) ហើយអនុញ្ញាតឲ្យតុលាការពិចារណាភស្តុតាងពាក្យចចាមអារ៉ាមទាំងអស់ ដោយធ្វើការថ្លឹងថ្លែងនីមួយៗខុសប្លែកពីគ្នាដោយយោងទៅតាមភាពអាចជឿជាក់បានជាក់ស្តែងនៃពាក្យចចាមអារ៉ាមនោះ ។

វិធីទី២ ផ្តល់ឲ្យចៅក្រមកាត់ក្តីនូវសិទ្ធិសម្រេចច្រើនជាង

ហើយត្រូវបានអនុវត្តនៅក្នុងតុលាការអន្តរជាតិភាគច្រើន មកទល់ពេលបច្ចុប្បន្ននេះ ។ ជាទូទៅ វិធីទី២នេះត្រូវបានអនុវត្ត នៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុកនៃបណ្តាប្រទេសមួយចំនួនដែរ ដូចជាប្រទេសកម្ពុជាជាដើមដែលជាប្រវត្តិសាស្ត្រប្រព័ន្ធច្បាប់ នៃប្រទេសនេះពឹងផ្អែកលើគំរូច្បាប់របស់បារាំង ។

ហេតុដូច្នេះ ប្រព័ន្ធច្បាប់នៅកម្ពុជាបង្ហាញពីលក្ខណៈ ដែលអាចនឹងយកពាក្យចចាមអារ៉ាមមកពិចារណានៅក្នុងការជំនុំ ជម្រះក្តីខ្មែរក្រហមច្រើនជាង ដែលប្រហែលជានឹងបម្រើផល ប្រយោជន៍ដ៏ប្រសើរបំផុតដល់ព្រះរាជអាជ្ញានៃតុលាការកាត់ទោស មេដឹកនាំខ្មែរក្រហមនាពេលខាងមុខ ។ ទោះបីភស្តុតាងពាក្យ ចចាមអារ៉ាមមួយចំនួនដែលបង្ហាញដោយព្រះរាជអាជ្ញាអាចត្រូវ ទៅនឹងករណីមួយក្នុងចំណោមករណីលើកលែងទាំងអស់ក្នុងប្រព័ន្ធ ច្បាប់អង់គ្លោសាក់សុងរបស់អង់គ្លេសក៏ដោយ ក៏ភស្តុតាងពាក្យ ចចាមអារ៉ាមជាច្រើនអាចនឹងត្រូវបានទាត់ចោលដោយវិធានស្តី អំពីភស្តុតាង ។ ផ្ទុយទៅវិញភស្តុតាងពាក្យចចាមអារ៉ាមទាំងអស់ នេះនឹងអាចទទួលយកមកពិចារណាបានដោយតុលាការដែល បង្កើតក្រោមទំនៀមទម្លាប់ច្បាប់ស៊ីវិលដែលមានប្រភពចេញមក ពីបារាំងហើយទោះបីជាភស្តុតាងនីមួយៗត្រូវបានផ្តល់តម្លៃឬទម្ងន់ តិចតួចក៏ដោយ ក៏សារៈសំខាន់នៃកសិណតាមពាក្យចចាមអារ៉ាម ទាំងនោះអាចមានឥទ្ធិពលធំនៅពេលដែលផ្គុំបញ្ចូលគ្នាដោយពិនិត្យ លើចំនួនកសិណនៃពាក្យចចាមអារ៉ាមជាច្រើនដែលមានស្រាប់ ។

## ២-ចម្លើយសារភាព

ទម្រង់ភស្តុតាងដែលមានបញ្ហាទី២ នៅក្នុង ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមគឺចម្លើយសារភាព ។ ឯកសារជាច្រើនសន្ធឹកសន្ធាប់ដែលបានកត់ត្រា ចម្លើយសារភាពជាពិសេសនៅគុកទួលស្លែង ដែល ជាគុកដ៏សាហាវរបស់របបខ្មែរក្រហម (ដែលហៅថា មន្ទីរស-២១) នៅក្រុងភ្នំពេញមានផ្ទុកពត៌មានដែល មានតម្លៃភស្តុតាងដ៏មានសារៈសំខាន់ជាសក្តានុពល ។ ជាពិសេសឯកសារចម្លើយសារភាពជាច្រើនពិពណ៌នា អំពីសកម្មភាព និងមុខងាររបស់មន្ត្រីបក្សកុម្មុយនិស្ត កម្ពុជា និងកម្មាភិបាលផ្សេងៗ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ចម្លើយសារភាពទាំងនេះមានបញ្ហាច្រើនក្នុងការយក មកធ្វើជាភស្តុតាងដោយមូលហេតុជាច្រើន គឺទី១ ចម្លើយ សារភាពទាំងនោះត្រូវបានគិតថាមានតម្លៃអាចជឿជាក់បានតិច ជាងទម្រង់ភស្តុតាងដទៃទៀត ពីព្រោះតុលាការទទួលស្គាល់ថា ចម្លើយសារភាពជាច្រើនជារឿយៗអាចត្រូវបានធ្វើឡើងដោយ បង្ខំគ្រាន់តែក្នុងកម្រិតបង្ខំផ្សេងៗគ្នា ។ ក្រោមរបបកម្ពុជាប្រជា ធិបតេយ្យនៅក្នុងគុកដ៏គួរឲ្យខ្លាចទាំងអស់របស់របបនេះស្ទើរតែ ច្បាស់ថាចម្លើយសារភាពត្រូវបានជម្រិតយកដោយអំពើទារុណ កម្ម ។ បញ្ហានេះធ្វើឲ្យមានមន្ទិលសង្ស័យជាច្រើនអំពីសុពលភាព ពិតប្រាកដនៃការអះអាងជាច្រើន ។ ជាឧទាហរណ៍ អ្នកទោស ខ្មែរម្នាក់ដែលបានចុះហត្ថលេខាលើក្រដាសមួយសន្លឹកបញ្ជាក់ ថាគាត់ជា «ភ្នាក់ងារសេ.អ៊ី.អា» អាចត្រូវបានបង្ខំឲ្យធ្វើដូច្នេះ ។ ម្យ៉ាងទៀតអ្នកទោសនោះអាចត្រូវបង្ខំឲ្យចុះហត្ថលេខាមួយដែល ត្រូវបានសរសេរដោយមន្ត្រីនៃបក្សកុម្មុយនិស្តកម្ពុជាមួយរូប ។ តុលាការបានដឹងអំពីលទ្ធភាពនានាបែបនេះហើយ ហេតុដូច្នេះ ជារឿយៗផ្តល់ទម្ងន់តិចជាងចំពោះចម្លើយសារភាពជាងភស្តុតាង ប្រភេទដទៃទៀត ។

ការពិចារណាលើគោលនយោបាយសម្រាប់តុលាការ នេះបង្កើតបានជាហេតុផលទី៣ ដែលតុលាការជួនកាលអល់ អែកក្នុងការប្រើប្រាស់ចម្លើយសារភាពជាភស្តុតាងក្នុងការជំនុំ ជម្រះក្តីព្រហ្មទណ្ឌនានា ។ ដោយប្រើប្រាស់ចម្លើយសារភាព



អៀង សារី ជួន ប្រាសិទ្ធិ

ក្រោមការបង្ខិតបង្ខំនៅក្នុងតុលាការធ្វើឲ្យចម្លើយសារភាពមានភាពស្របច្បាប់ហើយផ្តល់ផលប្រយោជន៍ដ៏មានប្រសិទ្ធិភាពដល់អ្នកដកស្រង់យកមកប្រើ ។ ក្នុងគោលបំណងបង្រួញការអនុវត្តន៍ជម្រិតយកចម្លើយសារភាព ហើយដោយធ្វើបែបនោះគឺដើម្បីការពារ និងលើកស្ទួយសិទ្ធិរបស់បុគ្គលជាទូទៅតុលាការទាត់ចោលនូវរបាយការណ៍នានាចេញពីចម្លើយសារភាពដែលនឹងត្រូវបានជម្រិតយកដោយការបង្ខិតបង្ខំឬក៏ផ្តល់ទម្ងន់ភ័ស្តុតាងតិចតួចបំផុត ។

ទោះបីជាក្រមច្បាប់ភ័ស្តុតាងដែលត្រូវបានអនុម័តដោយតុលាការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមមួយនឹងមិនចាំបាច់ដោះស្រាយភាពអាចទទួលយកបាននៃចម្លើយសារភាពក៏ដោយ ក៏ចំណុចសំខាន់ៗមួយចំនួននៃច្បាប់ភ័ស្តុតាងត្រូវតែដោះស្រាយមុនពេលចេញដីកាណាមួយ ។ ដំបូងគឺថាតើអនុញ្ញាតឲ្យប្រើរបាយការណ៍ចម្លើយសារភាពជាភ័ស្តុតាងដែរ ឬអត់ ដោយយើងបានដឹងជាប្រវត្តិសាស្ត្រថា របាយការណ៍ចម្លើយសារភាពជាច្រើន បានមកពីវិធានការបង្ខិតបង្ខំនិងទារុណកម្មដ៏ព្រៃផ្សៃ ។ ប្រសិនបើភ័ស្តុតាងចេញពីចម្លើយសារភាពទាំងនោះត្រូវបានដាក់បញ្ចូល បញ្ហាបន្ថែមទៀតនឹងលេចឡើង ។ បញ្ហាទាំងនោះគឺសួរថាតើតុលាការ ឬអង្គជំនុំជម្រះក្តីនោះនឹងសម្រេចថាតើឯកសារណាអាចជឿជាក់បាន ឬឯកសារណាមិនអាចជឿជាក់បានតាមវិធីយ៉ាងដូចម្តេច? ទោះបីជាចម្លើយសារភាពក្រោមការបង្ខិតបង្ខំបង្កើតឲ្យមានបញ្ហាព្រួយបារម្ភផ្នែកភ័ស្តុតាងជាច្រើន ចម្លើយសារភាពជនទៃទៀតដែលពុំត្រូវបានធ្វើឡើងក្រោមការបង្ខិតបង្ខំ ហើយប្រហែលសូម្បីតែផ្នែកមួយចំនួននៃចម្លើយសារភាពដែលបានពាក់ព័ន្ធទៅនឹងការបង្ខិតបង្ខំអាចផ្តល់នូវភ័ស្តុតាងដ៏មានតម្លៃទៅព្រះរាជអាជ្ញា ។ ប្រសិនបើដូច្នេះតុលាការនឹងត្រូវសម្រេចថាតើត្រូវទទួលយក ឬផ្តល់ទម្ងន់លើផ្នែកណាធ្ងន់ជាងផ្នែកណាមួយទៀតនៃចម្លើយសារភាពនោះ ។

## ៣-សេចក្តីសន្និដ្ឋាន

អត្ថបទនេះពុំស្នើសុំឲ្យមានដំណោះស្រាយមួយចំពោះបញ្ហានានាដែលបានលើកឡើងខាងលើនោះទេ ។ ក៏ប៉ុន្តែអត្ថបទនេះប៉ុនប៉ងធ្វើការកត់សម្គាល់និងបញ្ជាក់ឲ្យច្បាស់នូវចំណុចច្បាប់មួយចំនួនដែលនឹងមានសារៈសំខាន់ នៅពេលដែលការជំនុំជម្រះក្តីមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជានឹងឈានមកដល់ដូចដែលត្រូវបានរំពឹងទុកនាពេលខាងមុខ ។ ការសម្រេចចិត្តផ្នែកច្បាប់បែបនេះនឹងជះឥទ្ធិពលដ៏សំខាន់មួយមកលើការជំនុំជម្រះក្តីខ្មែរក្រហម និងការរំពឹងចង់បានលើយុត្តិធម៌ ការដាក់ឲ្យទទួលខុសត្រូវនិងការបង្រួបបង្រួមជាតិនៅកម្ពុជា ។ **ចន ឆរឆីអារី**

---

**(តមកពីទំព័រ២៨)**

អាមេរិកបានជឿថា ពួកខ្លួនពុំអាចធ្វើអ្វីបានសមតាមហេតុផលដែលនឹងធ្វើឲ្យទំនាក់ទំនងនេះកាន់តែប្រសើរឡើង ។ មន្ត្រីសហរដ្ឋអាមេរិកជឿថា សកម្មភាពរបស់ទ្រង់សីហនុ បណ្តាលមកពីជំនឿរបស់ទ្រង់ថា កម្លាំងរបស់ប្រទេសចិនកំពុងរីកធំខ្លាំងឡើងហើយថារណសិរ្សរំដោះជាតិនឹងទទួលជោគជ័យនៅវៀតណាម ។ ជាផលវិបាកមន្ត្រីអាមេរិកកាំងទាំងនោះសន្និដ្ឋានថា ទ្រង់ សីហនុបានសម្រេចចិត្តថាទ្រង់ត្រូវតែកាត់ទំនាក់ទំនងជាមួយពួកខ្លួនឲ្យអស់តាមដែលទ្រង់អាចធ្វើទៅបាន ។ ហេតុដូច្នេះការធ្វើសម្បទានដ៏សមហេតុផលរបស់អាមេរិកនឹងពុំមានអ្វីសំខាន់ធំដុំនោះទេ ។ ជាបន្ថែមទៀតសហរដ្ឋអាមេរិកបានចាត់ទុកទំនាក់ទំនងរបស់ខ្លួនជាមួយប្រទេសថៃនិងវៀតណាមខាងត្បូង «ថាមានសារៈសំខាន់បំផុតដែលពុំអាចបណ្តោយឲ្យធ្លាក់ក្នុងសភាពគ្រោះថ្នាក់បានដោយសារការធ្វើសម្បទាននានាទៅឲ្យទ្រង់ សីហនុ ដែលទោះបីជាមន្ត្រីអាមេរិកទាំងនោះអាចបង្ហាញថា ការធ្វើសម្បទានអាចទទួលយកបានក៏ដោយ ក៏ពុំប្រហែលជានឹងអាចទិញបាននូវផលប្រយោជន៍ដ៏យូរអង្វែងបានទេដរាបណាទ្រង់សីហនុ នៅតែជឿថាជ័យជំនះរបស់កងកម្លាំងកុម្មុយនិស្តនៅអាស៊ីអាគ្នេយ៍នឹងមកដល់ក្នុងពេលខាងមុខនេះ» ។ សរុបមកមានតិចតួចណាស់ដែលសហរដ្ឋអាមេរិកអាចធ្វើដើម្បីជះឥទ្ធិពលមកលើព្រឹត្តិការណ៍ទាំងនេះ ។ មន្ត្រីអាមេរិកជឿថា ពួកខ្លួនអាចត្រឹមតែដាក់ខ្លួនឲ្យទាបហើយអត់ធ្មត់ប៉ុណ្ណោះ ។ **(នៅមានត)** **វ៉ែយនគុន វ៉ក្លែមម័រ**

**ទុកមិនចំណេញ ដកចេញមិនខាត។**
*ពាក្យស្លោកខ្មែរក្រហម*

# គំរូមួយនៃភ័ស្តុតាងឯកសារដែលភ្ជាប់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនិស្តដែលនៅរស់ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

(**តពីលេខមុន**) ចាប់តាំងពីអំឡុងខែមីនា ឆ្នាំ១៩៧៦ កាំង ហ្គិចអៀវ ហៅ ឌុច គឺជាប្រធានមន្ទីរស-២១ និងលេខាសាខាបក្សរបស់មន្ទីរស-២១ ។ ឌុច ឬក៏កម្មាភិបាលជាន់ខ្ពស់ដទៃទៀតដែលតំណាងមន្ទីរស-២១ បានចូលរួមអង្គប្រជុំមួយចំនួនដែលកោះប្រជុំក្រោមអធិបតីភាពលេខានិងអនុលេខារបស់កងពលមជ្ឈិមរបស់ សុន សេន និងវរសេនាធំឯករាជ្យនានា ។ ឌុច និងកម្មាភិបាលមន្ទីរស-២១ចំនួន១១នាក់ទៀតក៏បានចូលរួមក្នុងវគ្គសិក្សាអគ្គសេនាធិការទូទាំងប្រទេសលើកដំបូងសម្រាប់កម្មាភិបាលយោធាមជ្ឈិមកាលពីខែតុលា ឆ្នាំ១៩៧៦ ហើយកម្មាភិបាលចំនួន៣០០នាក់ទៀតមកពីអង្គភាពនានាទូទាំងប្រទេសក៏មានវត្តមាននៅក្នុងវគ្គសិក្សានោះដែរ ។

## *សេចក្តីថ្លែងការណ៍ដោយ អៀង សារី ប៉ុល ពត តាម៉ុក និង នួន ជា*

ឯកសារភ័ស្តុតាងនិងកសិណសាក្សីដែលមានស្រាប់ពាក់ព័ន្ធបទឧក្រិដ្ឋកម្មនានាពុំបង្ហាញច្បាស់អំពីខ្សែសង្វាក់បទបញ្ជានយោបាយក្នុងមន្ទីរស-២១ដែលនៅក្រោមចំណុះអគ្គសេនាធិការទាក់ទងទៅនឹងការគ្រប់គ្រងរដ្ឋបាល និងការបំពាក់បំប៉នស្មារតី ។ មូលហេតុមួយដែលនាំឲ្យមានភាពស្មុគស្មាញ គឺពុំទាន់មានឯកសារដែលផ្តល់ជាពន្លឺបញ្ជាក់ ឬបដិសេធវត្តមាននៃអង្គការទាំងពីរគឺ (គណៈកម្មាធិការសន្តិសុខ និងគណៈកម្មាធិការសម្ងាត់ដែលត្រូវបាននិយាយដោយឯកសារស្រាវជ្រាវ ខែកញ្ញា ឆ្នាំ១៩៩៦ មួយដែលត្រូវបានចេញផ្សាយក្រោមឈ្មោះ «ការស្រាវជ្រាវនិងមជ្ឈមណ្ឌលឯកសារ» របស់ចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យដែលបង្កើតឡើងដោយ អៀង សារី បន្ទាប់ពី អៀង សារី បាន «ផ្តាច់ខ្លួន» ចេញពី ប៉ុល ពត កាលពីខែសីហា ឆ្នាំ១៩៩៦ ។

ការពិពណ៌នាក្នុងឯកសារស្រាវជ្រាវអំពីអង្គការទាំងពីរនេះបានបង្ហាញថា អង្គការទាំងពីរនេះមើលខុសត្រូវពីលើមន្ទីរស-២១ ផ្នែកនយោបាយ ហេតុដូច្នេះមានអំណាចអនុវត្តហួសប្រមាណលើអំណាចរបស់លក្ខន្តិកៈបក្ស, រដ្ឋធម្មនុញ្ញ, គណៈកម្មាធិការមជ្ឈិម, គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការយោធា ហើយនិងអគ្គសេនាធិការ ។ ឯកសារនោះបានកំណត់អត្តសញ្ញាណកម្ម «គណៈកម្មាធិការសន្តិសុខ» ដែលដឹកនាំដោយ ប៉ុល ពត នៅក្នុងគណៈកម្មាធិការយោធា ហើយនៅក្នុងគណៈកម្មាធិការដដែលនេះ មានអង្គការមួយទៀតគឺ «គណៈកម្មាធិការសម្ងាត់» ដែលដឹកនាំដោយ នួន ជា ដោយមាន សុន សេន ជា «សមាជិក» របស់គណៈកម្មាធិការ ហើយ យុន យ៉ាត ត្រូវបានដឹងថា ជា «ទីប្រឹក្សា» របស់ប្តីគាត់ (សុន សេន) ។ ឯកសារស្រាវជ្រាវនោះចោទដោយពុំបានបង្ហាញភ័ស្តុតាងថា តាមរយៈគណៈកម្មាធិការកាត់ផ្តាច់ពីគ្នាទាំងពីនេះ «ប៉ុល ពត, នួន ជា, សុន សេន និង យុន យ៉ាត» ជាអ្នកសម្រេចទាំងអស់អំពី«ការសម្លាប់យ៉ាងរង្គាល» ប៉ុន្តែមេដឹកនាំខ្មែរក្រហមដូចមានឈ្មោះខាងលើបានពឹងផ្អែកថែមទៀតលើ «សមាជិកមួយចំនួន» របស់គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលជាសមាជិកនៃគណៈកម្មាធិការសន្តិសុខឬលេខាភូមិភាគ «ដូចជាតាម៉ុក និង សោភឹម»សម្រាប់ការអនុវត្តន៍គោលនយោបាយសម្លាប់រង្គាលរបស់ពួកខ្លួន ។ ឯកសារស្រាវជ្រាវនោះទំនងជាពិពណ៌នាអំពីប្រព័ន្ធមួយដែលតាមរយៈនោះ ប៉ុល ពត បានផ្ទេរអំណាចមួយផ្នែកធំលើបញ្ហាសន្តិសុខទៅ នួន ជា ហើយជាប្រព័ន្ធមួយដែលធ្វើឲ្យបំបិទកាត់ចោលនូវសិទ្ធិរបស់សមាជិកគណៈកម្មាធិការគណៈអចិន្ត្រៃយ៍ ឬគណៈកម្មាធិការមជ្ឈិមដទៃទៀតរួមបញ្ចូលទាំងលេខាភូមិភាគចេញពីការធ្វើការសម្រេចចិត្តមជ្ឈិមក្នុងកិច្ចការសន្តិសុខ ។

នៅពេលដែលសួរក្នុងបទសម្ភាសន៍មួយ៣ខែក្រោយមកដើម្បីបញ្ជាក់ពីឯកសារខែកញ្ញាឆ្នាំ១៩៧៦ អៀង សារី បានចង្អុលបង្ហាញថា តាមពិតមានគណៈកម្មាធិការតែមួយគត់ដែលទទួលខុសត្រូវចំពោះកិច្ចការយោធានិងសន្តិសុខ ។ ទោះបីជាយ៉ាងណា


ប៉ុល ពត


អៀង សារី


នួន ជា


សុន សេន

ក៏ដោយ អៀង សារី បានអះអាងជាថ្មីម្តងទៀតថា ភាពពិតជាក់ស្តែងនៃការធ្វើគោលនយោបាយសន្តិសុខគឺពុំគោរពខ្សែសង្វាក់អាជ្ញាធរផ្លូវការនៃគណៈកម្មាធិការសន្តិសុខនេះឡើយ ហើយថែមទាំងដើររំលងអាជ្ញាធរនៃគណៈកម្មាធិការមជ្ឈិមនិងគណៈកម្មាធិការអចិន្ត្រៃយ៍ ។ នៅពេលសួរថាតើនរណាជាអ្នកធ្វើការសម្រេចចិត្តដែលជាលទ្ធផលបណ្តាលឲ្យមានការសម្លាប់ «មន្ត្រីយោធាមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់(ភ្នាក់ងារសម្ងាត់) និងប្រជាជនក្នុងចំណាត់ប្រភេទដទៃទៀត» នៃរបបសាធារណរដ្ឋខ្មែរនៅក្នុងកំឡុងពេលភ្លាមៗ បន្ទាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ អៀង សារី ឆ្លើយថាការសម្រេចចិត្តនេះត្រូវបានធ្វើឡើង «នៅពេលដែលទីក្រុងភ្នំពេញ ត្រូវបានរំដោះ» ដោយ «មនុស្ស៣នាក់ប៉ុណ្ណោះគឺ ប៉ុល ពត, នួន ជា និងសុន សេន» ដែល «ជាអ្នកគូសវាសអារកាត់វិធានការថា ត្រូវធ្វើយ៉ាងដូចម្តេចអំពីបញ្ហាបញ្ញាជន បញ្ហាទាហាននិងកងអាវុធហត្ថជាតិនិងមន្ត្រីធំៗទាំងអស់ ។ អ្នកទាំង៣នាក់នេះហើយគឺជាអ្នកដែលធ្វើការសម្រេចចិត្តនានា ហើយគ្មាននរណាធំជាងអ្នកទាំង៣នេះទេ» ។ អៀង សារី បន្ថែមទៀតថាៈ

*តាមដែលខ្ញុំដឹងការសម្រេចចិត្តឲ្យសម្លាប់មនុស្សអស់ជាច្រើនពុំត្រូវបានគ្រោងទុកជាមុននោះទេ ក៏ប៉ុន្តែបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ប្រហែលជាអំឡុងថ្ងៃទី២០ ខែ មេសា ឆ្នាំ១៩៧៥ នៅពេលនោះហើយដែលមានការសម្រេចឲ្យធ្វើអ្វីក៏ដោយដែលត្រូវធ្វើដើម្បីកុំឲ្យខ្មែរសាធារណរដ្ឋប្រឆាំងតបនឹងបដិវត្តន៍វិញ ។ យោងទៅតាមអ្វីដែលខ្ញុំត្រូវបានប្រាប់ពួកអ្នកទាំងនេះ (ខ្មែរសាធារណរដ្ឋ) មានផែនការវាយកម្ទេចឲ្យម៉ត់ដោយបម្រុងលួចធ្វើឃាតខ្មែរក្រហមនៅពេលដែលយើងមកដល់ ហើយធ្វើរដ្ឋប្រហារដើម្បីដណ្តើមអំណាចពីយើងតែម្តង ។ នៅពេលដែលខ្ញុំសួរលម្អិត ខ្ញុំត្រូវបានថ្នាក់លើប្រាប់ថាការឆែកឆេរផ្ទះរបស់មន្ត្រីរបបសាធារណរដ្ឋ ឃើញមានគ្រាប់បែក និងអាវុធគ្រប់ទឹកខ្នែងដែលជាផ្នែកនៃការរៀបចំ សម្រាប់ការធ្វើរដ្ឋប្រហារមួយ ។ នៅពេលដែលការជម្លៀសប្រជាជនចេញពីទីក្រុង ចាប់ផ្តើមទើបបានឃើញច្បាស់នូវអ្វីដែលថ្នាក់លើបានប្រាប់ខ្ញុំ ថាវាអ៊ីចឹងមែន ហើយមានការសម្រេចចិត្តបែបនេះមែន ។*

តាមរយៈការអាន «ចម្លើយសារភាពនានា» របស់កម្មាភិបាលកុម្មុយនិស្តដែលក្រោយមកត្រូវបានប្រហារជីវិតពីបទ «ក្បត់ជាតិ» ពិពណ៌នាអំពីបទបញ្ជាទាំងឡាយដែលចេញមកពីការសម្រេចចិត្តបែបនេះ ។ ហេតុដូច្នេះ សូម្បីតែក្នុងពេលជម្លៀសនោះ កងកម្លាំងប្រដាប់អាវុធកុម្មុយនិស្ត «កំពុងតែរកឃើញសត្រូវនៅគ្រប់អង្គភាព» ។ សត្រូវទាំងនេះ «ត្រូវបានចាប់ជាបណ្តើរៗ ជាពិសេសមន្ត្រីជាន់ខ្ពស់មួយចំនួនចាប់ពីឋានៈអនុសេនីយឯកឡើង... ហើយមន្ត្រីសាធារណរដ្ឋទាំងអស់...ត្រូវបានកម្ទេច» ។ មិនយូរប៉ុន្មានបន្ទាប់ពីពេលនោះ «អង្គការបានដាក់ចេញនូវគោលនយោបាយ «កម្ទេច»ជាបន្តបន្ទាប់នូវមន្ត្រីនានា ចាប់ពីឧត្តមសេនីយ៍ ហើយស្រាវជ្រាវតាមចាប់រហូតដល់ថ្នាក់ពលបាល ក៏ដូចជាភ្នាក់ងារស៊ើបអង្កេតរបស់រដ្ឋាភិបាល ប៉ូលិស បុគ្គលិកកងអាវុធហត្ថ និងមន្ត្រីរាជការដែលមានប្រតិកម្ម» ។ ដោយថាហេតុ បញ្ជីសម្លាប់ត្រូវ

បានពង្រីកបញ្ចូលទាំងមនុស្សដែលត្រូវបានចុះឈ្មោះជា «សកម្មជន» ប្រឆាំងនឹងបដិវត្តន៍ ។ ក្នុងខណៈនេះដោយយោងទៅតាម «ចម្លើយសារភាពទាំងនោះ» នីតិវិធីជាប្រចាំមួយត្រូវបានដាក់ចុះឲ្យអនុវត្តចំពោះអតីតមន្ត្រីរដ្ឋបាល ប៉ូលីស និងយោធានៃរបបសាធារណរដ្ឋខ្មែរដែលរបូតប្រុត្រូវបានអនុញ្ញាតឲ្យរួចចេញពីសំណាញ់នៃការជម្លៀសនេះ ហើយទៅរស់នៅតាមជនបទ ។ នីតិវិធីនេះគឺសម្រាប់អាជ្ញាធរកុម្មុយនិស្តនៅតាមមូលដ្ឋានក្នុងការស្រង់ «បញ្ជីជាបន្តបន្ទាប់» នូវឈ្មោះអ្នកទាំងឡាយដែលត្រូវយកទៅកម្ទេចចោល ហើយបញ្ជីទាំងនេះត្រូវបានដាក់ទៅឲ្យគណៈកម្មាធិការបក្សភូមិភាគដែលមាននាទីចុងក្រោយក្នុងការ «ជ្រើសរើស» អ្នកណាដែលត្រូវយកទៅសម្លាប់ ។ នេះហាក់បីដូចជាស្របទៅតាមការសម្រេចចិត្តរបស់គណៈកម្មាធិការមជ្ឈិម ដោយយោងទៅតាមសេចក្តីសម្រេចនោះ «សិទ្ធិក្នុងការសម្រេចកម្ទេចនៅក្នុងនិងក្រៅជួរបក្ស» ត្រូវអនុវត្តន៍នៅ «ថ្នាក់មូលដ្ឋាន» ដោយ «គណៈកម្មាធិការអចិន្ត្រៃយ៍ភូមិភាគ» ។

យោងទៅតាមសេចក្តីថ្លែងការណ៍របស់ អៀង សារី កាលពីខែធ្នូ ឆ្នាំ១៩៩៦ ការធ្វើបន្សុទ្ធកម្មនិង ការប្រហារជីវិតកម្មាភិបាលក្នុងជួរបក្សកុម្មុយនិស្តកម្ពុជាដែលកើតឡើងបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ស្រដៀងគ្នាដែរត្រូវបានត្រួតពិនិត្យដោយ ប៉ុល ពត, នួន ជា និង សុន សេន ដោយមានការជួយជ្រោមជ្រែងក្រៅផ្លូវការពីយុន យ៉ាត ។ អៀង សារី អះអាងបញ្ជាក់ថាទាំងនេះគឺជា «បញ្ហាដែល ប៉ុល ពត, នួន ជា និង សុន សេន បានសម្រេចតែក្នុងចំណោមគ្នាគេទាំង៣នាក់នោះ


អៀង ធីរិទ្ធ
(ប្រពន្ធ អៀង សារី)


ខៀវ សំផន

ប៉ុណ្ណោះ ពុំមានសួរអ្នកដទៃទៀតនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍រួមទាំងរូបខ្ញុំផ្ទាល់» ។ ហេតុដូច្នេះ អៀង សារី បានអះអាងថា÷ ប៉ុល ពត, នួន ជា និង សុន សេន ពុំបានសួរ អៀង សារី អំពីការងារសន្តិសុខទេទោះបី អៀង សារី នៅភ្នំពេញក៏ដោយ ។ មានការភ័ន្តច្រឡំ ពីព្រោះខ្ញុំនៅក្នុងគណៈកម្មការអចិន្ត្រៃយ៍ ហើយខ្ញុំគឺជាប្អូនថ្លៃរបស់ ប៉ុល ពត ប៉ុន្តែការពិតគឺថាខ្ញុំពុំបានដឹងអ្វីទាំងអស់ពីរឿងហ្នឹង» ។

ក៏ប៉ុន្តែក្នុងពេលទន្ទឹមនឹងនេះ អៀង សារី បានចោទថា «របៀបនៃការរៀបចំ» គឺថា «ភូមិភាគនីមួយៗឯករាជ្យ ហេតុនេះភូមិភាគទាំងនោះអាចសម្លាប់នរណាមួយតាមចិត្តពួកគេចង់ ។ ភូមិភាគទាំងនោះចង់ធ្វើអ្វីក៏បានដែរ» ។ ជាឧទាហរណ៍ អៀង សារី បាននិយាយថា «អ្វីៗដែល សោ ភឹម ចង់ធ្វើនៅភូមិភាគរបស់ខ្លួននោះ សម្លាប់ឬធ្វើយ៉ាងម៉េចក៏បាន សោ ភឹម ពុំចាំបាច់សួរថ្នាក់ដឹកនាំខាងលើទេ ។

នៅក្នុងបទសម្ភាសន៍មួយជាមួយអ្នកកាសែត អាលីហ្សាប៉ែត បែកឃ័រ ប្រហែល១២ឆ្នាំមុននេះស្រដៀងគ្នានេះដែរ អៀង សារី បានទទូចថាខ្លួន «ពុំបានដឹង» អំពីការសម្លាប់មនុស្សនៅមន្ទីរ ស-២១ ក្នុងខណៈដែលបក្សកុម្មុយនិស្តនៅកាន់អំណាចនោះទេ

ពីព្រោះខ្លួន «ពុំកាន់ខាងសន្តិសុខ»ទេ ។ ទោះបីជាយ៉ាងណាក៏ដោយ អៀង សារី ផ្តល់នូវសាច់រឿងខុសប្លែកមួយអំពីថានរណាខ្លះពាក់ព័ន្ធនៅក្នុងសេចក្តីសម្រេចលើបញ្ហាសន្តិសុខ និងប្រព័ន្ធនៃការពិភាក្សាផ្ទៃក្នុងនានា ។ អៀង សារី បានប្រាប់អ្នកស្រី បែកឃ័រ ថាបញ្ហាសន្តិសុខត្រូវបានពិភាក្សាក្នុងចំណោម «មេដឹកនាំ៣-៤ នាក់» រួមមាន ប៉ុល ពត, នួន ជា, សោ ភឹម និង សុន សេន ហើយដែលតាម អៀង សារី និយាយ «ក្រោយមករាយការណ៍ទៅគណៈកម្មាធិការអចិន្ត្រៃយ៍» ។ អៀង សារី បានពន្យល់ថា ប្រព័ន្ធពីមុនគឺថាអាចចាប់នរណាម្នាក់ ដោយចោទថា«ជនក្បត់» ប្រសិនបើជននោះត្រូវបានកំណត់ថាជាជនក្បត់បែបនោះដោយមនុស្ស៣នាក់ ប៉ុន្តែក្រោយមក ក្នុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ ១៩៧៨ ប៉ុល ពត បាននិយាយថាមនុស្ស៥នាក់ត្រូវតែរួមគ្នាដាក់កំហុសនរណាម្នាក់ មុនពេលដែលជននោះត្រូវបានចាប់ខ្លួន ។ ទោះបីជាយ៉ាងណាក៏ដោយ អៀង សារី បានចង្អុល ប្រាប់ថា ទោះបីខ្លួនជាសមាជិកក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយរបាយការណ៍នានាអំពីបញ្ហាសន្តិសុខត្រូវបានផ្ញើទៅឲ្យគណៈកម្មាធិការនេះក៏ដោយ ក៏ខ្លួនពុំបានដឹងអំពីការសម្លាប់ជនទាំងឡាយដែលត្រូវបានចាប់ខ្លួននោះឡើយ ។

ហេតុដូច្នេះ អៀង សារី នៅក្នុងបទសម្ភាសន៍កាលពីមុននេះបានទទួលស្គាល់ថា ខ្លួនបានដឹងថាកម្មាភិបាលម្នាក់ឈ្មោះ ឌុច ជាអ្នកចាត់ចែងគ្រប់គ្រងមន្ទីរសន្តិសុខមួយ ដែលត្រូវបានហៅថាមន្ទីរស-២១ ក៏ប៉ុន្តែអៀង សារី អះអាងថាខ្លួនពុំដឹងថាស-២១ នៅឯណានោះទេ ឬថាអ្នកទាំងឡាយដែលត្រូវបានជាប់ឃុំឃាំងនៅទីនោះកំពុងត្រូវបានប្រហារជីវិតឡើយ ។ អៀង សារី បាននិយាយថា ខ្លួនបានគិតខុសថាមន្ទីរស-២១ នៅតាមផ្លូវឆ្ពោះទៅកាន់ព្រលានយន្តហោះពោធិចិនតុងនៅក្រុងភ្នំពេញ ហើយត្រូវបានប្រាប់ថា ភ្នាក់ងារខ្មាំងដែលត្រូវបានចាប់«ត្រូវបញ្ជូនចេញទៅសហករណ៍ដើម្បីអប់រំ» ។ អៀង សារី បាននិយាយថា ក្រោយមកទើបខ្លួនបានដឹងអំពីការសម្លាប់ «ដ៏អមនុស្សធម៌» ដែលត្រូវបានប្រព្រឹត្តឡើងដោយកងសន្តិសុខ ។ អៀង សារី បានទទួលស្គាល់ថានៅពេលចាប់ខ្លួនអ្នកទោសខ្លួនបានជឿលើការចោទប្រកាន់ថាអ្នកទោសទាំងនោះបានប៉ុនប៉ង «ផ្តួលរំលំរដ្ឋអំណាច» ប៉ុន្តែខ្លួនមានអារម្មណ៍ថាវាពុំចាំបាច់ក្នុងការកាប់សម្លាប់អ្នកទាំងនោះដោយសារអ្នកទោសទាំងនោះគ្មានអាវុធក្នុងដៃ ។ អៀង សារី និយាយថា «ជានិច្ចកាលខ្ញុំបាននិយាយថាអ្នកទោសទាំងនោះពុំអាចធ្វើអ្វីបានទេពីព្រោះពួកគេពុំមាន «អំណាចយោធា» ។ ក៏ប៉ុន្តែ អៀង សារី បានអះអាងថា ប៉ុល ពត «បានដឹងថាអ្នកដែលត្រូវបានចោទប្រកាន់នឹងត្រូវបានយកទៅសម្លាប់» ។

ហេតុដូច្នេះ អៀង សារី បានព្យាយាមបញ្ចៀសសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ខ្លួន ពីពេលមុនៗដែលហាក់បីដូចជាធ្វើឲ្យជាប់ពាក់ព័ន្ធនឹងខ្លួនឯងទៅនឹងឧក្រិដ្ឋនៅក្នុងខណៈដែលខ្លួននៅក្នុងជួរអ្នកកាន់អំណាចជាអនុនាយករដ្ឋមន្ត្រីរបបកម្ពុជាប្រជាធិបតេយ្យទទួលបន្ទុកកិច្ចការបរទេស ។ សេចក្តីថ្លែងការណ៍ទាំងនេះរួមសេចក្តីថ្លែងការមួយដែលធ្វើឡើងកាលខែមេសា ឆ្នាំ១៩៧៨ គាត់នៅបាននិយាយថាៈ

*«កាលពីខែមេសា ឆ្នាំ១៩៧៦ និងបន្ទាប់មកម្តងទៀតនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៦ យើងចាប់បានភ្នាក់ងារវៀតណាម ភ្នាក់ងារ កា-ហ្សេ-បេ នៅតាមព្រំដែន ក៏ដូចជានៅក្នុងទីក្រុងភ្នំពេញ ។ ក្នុងឆ្នាំ១៩៧៧...បញ្ហាសន្តិសុខនៅតែតានតឹងដោយសត្រូវរបស់យើងបានបន្តផ្សំគំនិតប្រឆាំងនឹងយើង ។ ជនជាតិកម្ពុជាបានទទួលប្រាក់កាសពីសេ.អ៊ី.អា ចង់ធ្វើរដ្ឋប្រហារមួយ... ។ ទោះបីជាយ៉ាងណាក៏ដោយកាលពីខែមីនា យើងបានចាប់ភ្នាក់ងារសេ.អ៊ី.អាទាំងនេះ ។ ជាថ្មីម្តងទៀតកាលពីខែកញ្ញា យើងចាប់បានក្រុមមនុស្សតូចមួយដែលកំពុងរៀបចំផែនការដើម្បីវាយប្រហាររដ្ឋាភិបាលយើង ។ មន្ត្រីមួយចំនួនកំពុងធ្វើការបម្រើសេ.អ៊ី.អា ចាប់តាំងពីឆ្នាំ១៩៥៨ មកម៉្លេះដោយក្លែងខ្លួនជាជនបដិវត្តន៍គ្រប់ពេលវេលា ។»*

(**នៅមានត**)

**ស៊ីវ ហេគដ័រ**

◆ **របៀបវាយកម្ទេច គោលជំហរកម្មសិទ្ធិសួនតួ ឱ្យអស់រលីងខាងសម្ភារៈសិទ្ធិអំណាច និងសីលធម៌រស់នៅជាដាច់ខាត។**

*(ពាក្យស្លោកខ្មែរក្រហមៈ សៀវភៅទង់បដិវត្តន៍ ឆ្នាំ១៩៧៦)*

# ការវិវត្តន៍ថ្មីៗជុំវិញច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម

កត់ត្រាដោយ ផាត កុសល

## ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០០

**ជំនួបរវាងអគ្គលេខាធិការ កូហ្វី អាណាន់ និងសម្តេច ហ៊ុន សែន នៅទីក្រុងបាងកក**

លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បានជួបជាមួយសម្តេចហ៊ុន សែន នៅទីក្រុងបាងកក ។ បន្ទាប់ពីការជួបពិភាក្សាគ្នាអស់រយៈពេល៣០នាទី ភាគីទាំងសងខាងបានបង្ហាញនូវក្តីសង្ឃឹមថា បញ្ហាខុសប្លែកគ្នាទាំងឡាយលើច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមនឹងអាចត្រូវបានដោះស្រាយ ។ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បានប្រកាសថា នឹងបញ្ជូនក្រុមអ្នកច្បាប់មួយក្រុមទៅក្រុងភ្នំពេញដើម្បីពិភាក្សាដែលនឹងសម្រេចឲ្យបាននូវកិច្ចព្រមព្រៀងមួយជាមួយនឹងរដ្ឋាភិបាលកម្ពុជាលើបញ្ហាច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។ បញ្ហា៤ចំណុចដែលអង្គការសហប្រជាជាតិស្នើសុំយកមកពិភាក្សាដើម្បីឈានដល់ការព្រមព្រៀងគឺៈ

១-បញ្ហាសមាសភាពចៅក្រមខ្មែរ និងបរទេស

២-ការធានា(កិច្ចព្រមព្រៀងអន្តរជាតិ) មួយថាជនទាំងឡាយណាដែលត្រូវចេញដីកាចោទប្រកាន់នឹងត្រូវចាប់ខ្លួន

៣- ការធានាអំពីការកម្រិតលើការលើកលែងទោស

៤-និងឯករាជ្យភាពរបស់ព្រះរាជអាជ្ញាដែលត្រូវបានចាត់ទុកថាជាចំណុចដ៏សំខាន់ ។

## ថ្ងៃពុធ ទី១៥ ខែមីនា ឆ្នាំ២០០០

**ប្រតិភូរបស់អង្គការសហប្រជាជាតិអញ្ជើញមកកម្ពុជាដើម្បីចរចាអំពីច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម**

តាមការិយាល័យអ្នកនាំពាក្យរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិបានឲ្យដឹងថា គណប្រតិភូរបស់អង្គការសហប្រជាជាតិបានចាកចេញពីទីក្រុងញូវយ៉កឆ្ពោះមកប្រទេសកម្ពុជាតាំងពីថ្ងៃអង្គារ៍ ទី១៤ ខែមីនា ឆ្នាំ២០០០ មកម៉្លេះ ហើយមកដល់ប្រទេសកម្ពុជានៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០០ ដើម្បីពិភាក្សាលើបញ្ហាការកាត់ទោសពួកខ្មែរក្រហម ។ សមាសភាពនៃគណប្រតិភូរបស់អង្គការសហប្រជាជាតិរួមមានដូចខាងក្រោមៈ

១-លោក ហេន កូរែល (Hans Corell)

អគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់ជាប្រធានគណៈប្រតិភូអង្គការសហប្រជាជាតិ ។

២- លោក រ៉ាល ហ្សាក់ឃ្លីន (Ralph Zacklin) ជំនួយការអគ្គលេខាធិការនៃការិយាល័យកិច្ចការច្បាប់ជាសមាជិក ។

៣- លោក ឡាក់ខាន់ មេរ៉ូត្រា (Lakhan Mehrotra) ប្រធានការិយាល័យតំណាងអង្គការសហប្រជាជាតិប្រចាំនៅក្រុងហ្សាកាតា ជាសមាជិក ។

៤- លោក ហ្សាស៊ី ថារូ (Shashi Tharoor) នាយកការិយាល័យប្រតិបត្តិរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ជាសមាជិក ។

៥- លោក ចន រ៉េនីងហ្គ័រ (John Renninger) មន្ត្រីទទួលបន្ទុកកិច្ចការអាស៊ីប៉ាស៊ីហ្វិកនៃនាយកដ្ឋានកិច្ចការនយោបាយជាសមាជិក ។

៦-អ្នកស្រី ដាហ្វនី ស្រាហ្គា (Daphne Shraga)មន្ត្រីច្បាប់ជាន់ខ្ពស់នៃការិយាល័យកិច្ចការច្បាប់ ជាសមាជិក ។

៧-លោក ម៉ាក ខ្វតទ័រមែន (Mark Quarterman) មន្ត្រីកិច្ចការនយោបាយនៃការិយាល័យជំនួយការអគ្គលេខាធិការសម្រាប់កិច្ចការនយោបាយ ជាសមាជិក ។

នៅថ្ងៃទី១៥ ខែមីនា ដដែលនេះ សារពត៌មានហៅកាត់ថាអេភី បានរាយការណ៍ថា លោកកូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិបានបញ្ជាក់ច្បាស់ថា តុលាការចម្រុះណាមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវតែឆ្លើយតបនឹងបទដ្ឋានយុត្តិធម៌អន្តរជាតិជាអប្បបរិមា ហើយព្រមានថា «អង្គការសហប្រជាជាតិ ពុំចាប់អារម្មណ៍ក្នុងការបង្កើតតុលាការចម្រុះមួយដោយត្រូវលះបង់តម្រូវការជាចាំបាច់នេះឡើយ ។ ក៏ប៉ុន្តែអ្នកការទូតបស្ចិមប្រទេសប្រចាំនៅអង្គការសហប្រជាជាតិបាននិយាយថាសហរដ្ឋអាមេរិក ប្រទេសបារាំង និងប្រទេស ជប៉ុនបានទទួច

សុំឲ្យលោកអគ្គលេខាធិការ កូហ្វី អាណាន់ ចាប់យកវិធានការដែលអាចបត់បែននិងក្នុងលក្ខណៈច្នៃប្រឌិតល្អប្រសើរជាងនេះ ក្នុងការកំណត់និយមន័យឲ្យបានច្បាស់នូវអ្វី ដែលហៅថាបទដ្ឋានជាអប្បបរិមាទាំងនោះហើយបានជូនយោបល់ធ្វើការសម្រុះសម្រួលគ្នាមួយលើគម្រោងច្បាប់កាត់ទោសខ្មែរក្រហមដើម្បីជាវិធីមួយទម្លាយភាពទាល់ច្រក ។ ឯកអគ្គរដ្ឋទូតបារាំង លោកអាឡាំង ដេហ្សាម៉េដ បានមានប្រសាសន៍ថា បញ្ហានេះជាតុល្យភាពមួយដែលត្រូវគិត ។ យើងត្រូវក្រឡេកមើលនូវអ្វីដែលត្រូវបានធ្វើរួចមកហើយនៅប្រទេសឥណ្ឌូនេស៊ី និងអាហ្វ្រិកខាងត្បូង ហើយព្យាយាមរកដំណោះស្រាយមួយស្រដៀងគ្នានេះ ។

ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកទទួលបន្ទុកខុទ្ទកម្មសង្គ្រាមលោក ដេវីដ សែហ្វ័រ បានមានប្រសាសន៍ថា «ខ្ញុំជឿថា ការព្រមព្រៀងមួយនឹងអាចសម្រេចបានពីការចរចានេះរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ។ យើងគិតថាភាពខុសគ្នាទាំងឡាយដែលនៅសេសសល់រវាងអង្គការសហប្រជាជាតិ និងកម្ពុជាលើបញ្ហាទាំងនេះគឺអាចដោះស្រាយបាន ក៏ប៉ុន្តែភាគីទាំងពីរតម្រូវឲ្យមានការពិភាក្សាឲ្យបានហ្មត់ចត់បំផុត ហើយសម្លឹងមើលទៅអ្វីដែលធ្លាប់បានកើតឡើងរួចមកហើយ» ។

## ថ្ងៃសុក្រ ទី១៧ ខែមីនា ឆ្នាំ២០០០

### ការរីកចំរើនលើការចរចាពីបញ្ហាខ្មែរក្រហម

សារពត៌មានរបស់អេភី បានរាយការណ៍ថាក្រុមចរចារដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបាននិយាយថាពួកខ្លួនសម្រេចបាននូវភាពរីកចំរើននៅក្នុងការបើកការពិភាក្សាលើកដំបូងនៅថ្ងៃសុក្រនេះលើបញ្ហាបង្កើតអង្គជំនុំជម្រះក្តីចំរុះមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ប្រធាននៃក្រុមអ្នកចរចារបស់រដ្ឋាភិបាលកម្ពុជាគឺឯកឧត្តម សុខ អាន បានមានប្រសាសន៍ថាយើងសម្រេចបាននូវការរីកចំរើនទៅមុខលើការទាមទារទាំងបួនចំណុចដែលអង្គការសហប្រជាជាតិបញ្ជាក់ថា ជាការចាំបាច់ដើម្បីឲ្យអង្គការសហប្រជាជាតិចូលរួមនិងធានាយុត្តិធម៌សម្រាប់ជនរងគ្រោះកម្ពុជាដែលបានស្លាប់ក្រោមរបបគ្រប់គ្រងរបស់ពួកខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩ ។

លោក ហេន កូរែល ដែលជាប្រធានគណប្រតិភូរបស់អង្គការសហប្រជាជាតិក៏បានបន្ថែមថា នៅព្រឹកនេះយើងបានពិភាក្សាគ្នាដ៏រីកចំរើន ហើយយើងបានច្បិចយកមួយចំនុចម្តងៗមកនិយាយ ក៏ប៉ុន្តែមិនគួរសង្ឃឹមថា យើងនឹងអាចដោះស្រាយបញ្ហាគ្រប់សព្វទាំងអស់នៅក្នុងរយៈពេលតែមួយព្រឹកនេះបានទេ ។

រីឯអ្នកការទូតមួយចំនួនបាននិយាយថាក្រុមចរចារបស់អង្គការសហប្រជាជាតិដែលមានអំណាចដ៏ខ្ពង់ខ្ពស់បានមកដល់កាលពីថ្ងៃព្រហស្បត្តិ៍ ទី១៦ គឺដើម្បីត្រៀមឈានដល់កិច្ចព្រមព្រៀងមួយ ក៏ប៉ុន្តែរដ្ឋាភិបាលកម្ពុជាបានបង្ហាញនូវសុឆន្ទៈដ៏តិចតួចដើម្បីធ្វើការសម្រុះសម្រួលដោយគ្រាន់តែនិយាយថាអធិបតេយ្យភាពរបស់ខ្លួននឹងត្រូវបានរំលោភ ប្រសិនបើចៅក្រមបរទេសមានអំណាចលើសលប់ ។

## ថ្ងៃសៅរ៍ទី១៨ ខែមីនា ឆ្នាំ២០០០

### ការរីកចំរើននៅថ្ងៃទី២ នៃការចរចា

សារពត៌មានអេភី បានរាយការណ៍ថានៅថ្ងៃសៅរ៍នេះដែលជាថ្ងៃទី២នៃការចរចារវាងភាគីកម្ពុជានិងអង្គការសហប្រជាជាតិមានការរីកចំរើនទៅមុខ ។ ក្នុងពេលដែលចេញពីអង្គប្រជុំលើកទីពីរនេះលោក ហេន កូរែល បានមានប្រសាសន៍ថាយើងបានសម្រេចបាននូវការ «រីកចំរើនដ៏ធំធេង» ហើយថាគាត់មានការសប្បាយចិត្តដែលអង្គប្រជុំបានពិភាក្សាលើបញ្ហាជាច្រើននៅក្នុងរយៈពេលដ៏ខ្លី ។

ឯកឧត្តម សុខ អាន ប្រធានអ្នកចរចាខាងកម្ពុជាបានមានប្រសាសន៍ដែរថា ការបើកអង្គប្រជុំនេះបានអនុញ្ញាតឲ្យមាន «ការយល់កាន់តែប្រសើរឡើង» លើបញ្ហាចម្រូងចម្រាស់ទាំងនោះ ។ លោក ហេន កូរែល បានមានប្រសាសន៍បន្ថែមកាលពីថ្ងៃសៅរ៍នោះដែរថា ជំហានបន្ទាប់នឹងឈានទៅពិភាក្សាអំពីចំណុចលម្អិតបន្ថែមដែលក្រុមទាំងសងខាងនិងពិភាក្សាគ្នាម្តងទៀតនៅថ្ងៃអាទិត្យ ។

សម្តេច ហ៊ុន សែន បានប្រាប់ទៅអ្នកយកពត៌មានបន្ទាប់ពីពិធីសម្ពោធផ្លូវថ្មីមួយនៅខេត្តពោធិសាត់ នៅថ្ងៃ១៨ ខែមីនា ដដែលនេះថា ចាប់ពីពេលនេះតទៅកុំសង្ឃឹមថា ខ្ញុំនឹងឆ្លើយនៅសំណួរអំពីបញ្ហាខ្មែរក្រហមទៀត ។ ក៏ប៉ុន្តែប្រធានក្រុមច្បាប់អង្គការសហប្រជាជាតិ លោកហេន កូរែល បានប្រាប់

អ្នកសារព័ត៌មានថា គាត់នៅតែមានក្តីសង្ឃឹមថានឹងសម្រេចបាន នូវដំណោះស្រាយមួយបន្ទាប់ពីការពិភាក្សាមកទល់ពេលនេះ ។

ទីភ្នាក់ងារព័ត៌មានបារាំង បានរាយការណ៍កាលពីថ្ងៃសៅរ៍នេះដែរថា សម្តេច ហ៊ុនសែន បានមានប្រសាសន៍ចំថ្ងៃទី២ដែលជាថ្ងៃពិភាក្សាដ៏មានសារៈសំខាន់រវាងមន្ត្រីអង្គការសហប្រជាជាតិ និងមន្ត្រីកម្ពុជាថាការធ្វើសមាហរណកម្មប្រទេសកម្ពុជាទៅក្នុងសហគមពិភពលោកគឺជាបញ្ហាអត្ថិភាព ។ សម្តេចក៏បានមានប្រសាសន៍ដែរថា «ខ្ញុំបាននិយាយជាច្រើនដងហើយថា បើសិនជាមានសំណួរអ្វីអំពីខ្មែរក្រហមខ្ញុំនឹងមិនឆ្លើយទេ ។ ឥឡូវសង្គ្រាមបានបញ្ចប់ហើយ បញ្ហាដែលនៅសល់គឺធ្វើសមាហរណកម្មប្រទេសរបស់យើងចូលទៅក្នុងសហគមពិភពលោក ។

## ថ្ងៃអាទិត្យ ទី១៩ ខែមីនា ឆ្នាំ២០០០

### ទស្សនកិច្ចប្រតិភូអង្គការសហប្រជាជាតិទៅកាន់ជើងឯក

ព័ត៌មានរបស់អេភី បានរាយការណ៍ថា នៅពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០០នេះ លោក ហេន កូវែល ដែលជាប្រធានក្រុមចរចារបស់អង្គការសហប្រជាជាតិបានទៅបំពាក់កម្រងផ្កានៅបូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះក្រោមរបបខ្មែរក្រហមនៅជើងឯក ។ នៅរសៀលថ្ងៃដដែលនេះលោក ហេន កូវែល បានមកធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

## នៅថ្ងៃច័ន្ទ ទី២០ ខែមីនា ឆ្នាំ២០០០

### ការចរចាត្រូវរង់ចាំដល់ពង្រាងច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមឆ្លងសភាជាតិសិន

វិទ្យុអេ.ប៊ី.ស៊ី របស់អូស្ត្រាលី បានផ្សាយថាអង្គការសហប្រជាជាតិ និងកម្ពុជាប៉ះទង្គិចគ្នាលើបញ្ហាកាត់ទោសខ្មែរក្រហម ។ គណប្រតិភូរបស់អង្គការសហប្រជាជាតិនៅភ្នំពេញពុំបានសម្រេចកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលកម្ពុជាលើសមាសភាពចៅក្រមនៃតុលាការដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ កិច្ចព្រមព្រៀងលើដំណើរការកាត់ទោសមួយអាចនឹងត្រូវរង់ចាំរហូតទាល់តែសភាជាតិកម្ពុជាបើកអង្គប្រជុំរបស់ខ្លួននៅចុងខែមេសា ឆ្នាំ២០០០ ខាងមុខ ។

ការពិភាក្សារវាងអ្នកចរចារបស់អង្គការសហប្រជាជាតិ និងតំណាងរដ្ឋាភិបាលកម្ពុជាក៏ពុំព្រមព្រៀងអំពីប្រភេទនៃការកាត់ទោសដែលមេដឹកនាំខ្មែរក្រហមនឹងត្រូវទទួល ។ អង្គការសហប្រជាជាតិ ធ្លាប់បានជំទាស់ជាមួយនឹងរដ្ឋាភិបាលកម្ពុជាលើបញ្ហាថាតើ នរណានឹងគ្រប់គ្រងតុលាការមួយដែលនឹងកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលត្រូវបានចោទប្រកាន់ពីបទសម្លាប់រង្គាលនៅក្នុងប្រទេសកម្ពុជានៅក្នុងចន្លោះ ឆ្នាំ១៩៧៥ និង ១៩៧៩ ។

មកទល់នឹងពេលនេះ អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាពុំទាន់បានឈានដល់ការព្រមព្រៀងគ្នាពេញលេញមួយនៅឡើយ ហើយចំណុចនៃការព្រមព្រៀងនានាអាចនឹងត្រូវដាក់ពិភាក្សានៅចំពោះមុខសភាជាតិកម្ពុជា ។

## ថ្ងៃអង្គារ៍ ទី២១ ខែមីនា ឆ្នាំ២០០០

### សេចក្តីសង្ឃឹមរបស់អង្គការសហប្រជាជាតិចំពោះការព្រមព្រៀងគ្នាលើក្របខ័ណ្ឌអង្គជំនុំជម្រះអំពីប្រល័យពូជសាសន៍បានធ្លាក់ចុះ

កាសែត សៅ ឆាយណា ម៉ នីង ផូស បានរាយការណ៍ថា សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភាជាតិ ទ្រង់មានព្រះបន្ទូលថារដ្ឋាភិបាលកម្ពុជាហាក់ដូចជាពុំមានឆន្ទៈចង់ធ្វើការផ្លាស់ប្តូរចំណុចទាំងបួនដែលអង្គការសហប្រជាជាតិបានស្នើសុំឲ្យកែប្រែលើពង្រាងច្បាប់នៃការជំនុំជម្រះមេដឹកនាំខ្មែរក្រហម មុនពេលដែលអង្គការសហប្រជាជាតិយល់ព្រមនឹងចូលរួម ។ ទ្រង់មានព្រះបន្ទូលកាលពីថ្ងៃច័ន្ទ បន្ទាប់ពីជួបជាមួយនឹងបេសកជនពិសេសរបស់អង្គការសហប្រជាជាតិ គឺលោក ហេន កូវែល ថា «អាចមានការធ្វើ វិសោធនកម្មបច្ចេកទេសមួយចំនួន ប៉ុន្តែមិនធ្វើវិសោធនកម្មជាសំខាន់ធំដុំទេ ។ ការចរចាជាមួយនឹងរដ្ឋាភិបាលពុំដំណើរការបានល្អឡើយ ។ ពង្រាងច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានគំរោងថា នឹងដាក់ពិភាក្សានៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០ ។ អ្នកវិភាគលើបញ្ហានេះបាននិយាយថា ការព្រមព្រៀងរវាងភាគីទាំងពីរលើក្របខ័ណ្ឌជាមូលដ្ឋានមួយសម្រាប់អង្គជំនុំជម្រះក្តីនោះជាមុន គឺមានសារៈសំខាន់ដ៏ធំធេង ។ បើគ្មានការព្រមព្រៀងជាមុនបែបនេះទេដំណើរការនេះអាចនឹងមានការលំបាកស្មុគស្មាញកាន់តែច្រើន ។»

## កាលពីព្រឹកថ្ងៃពុធ ទី២២ ខែមីនា ឆ្នាំ២០០០

### ជួបប្រជុំជាមួយសម្តេច ហ៊ុន សែន មុនចាកចេញទៅក្រុងញ៉ូវយ៉ក វិញ

គណៈប្រតិភូអង្គការសហប្រជាជាតិដឹកនាំដោយលោក ហេន កូរែល បានចូលជួបជាមួយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងរយៈពេលជាងមួយម៉ោង ។ បន្ទាប់មកគណៈប្រតិភូបានចាកចេញទៅកាន់ព្រលានយន្តហោះពោធិចិនតុង ។ នៅទីនោះលោក ហេន កូរែល បានផ្តល់បទសម្ភាសន៍ដ៏សង្ខេបមួយអំពីលទ្ធផលនៃបេសកកម្មរបស់ក្រុមអង្គការសហប្រជាជាតិរបស់លោកជាមួយនឹងក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជា ។ នៅឯព្រលានយន្តហោះពោធិចិនតុង ហើយសេចក្តីថ្លែងការណ៍នោះមានអត្ថន័យទាំងស្រុងដូចខាងក្រោមៈ

**សេចក្តីថ្លែងការណ៍របស់លោក ហេន កូរ៉ែល**
**ប្រធានគណៈប្រតិភូរបស់អង្គការសហប្រជាជាតិទៅកាន់អ្នក**
**សារពត៌មានជាតិ និងអន្តរជាតិ**
**ម៉ោង ៩:៤០ព្រឹក ថ្ងៃទី ២២ ខែមីនា ឆ្នាំ២០០០ នៅព្រលាន**
**យន្តហោះពោធិចិនតុង** *(ប្រែសម្រួលក្រៅផ្លូវការដោយ* **ផាត កុសល***)*

***សូមគោរពអស់លោក លោកស្រី ដែលជាអ្នក***
***សារពត៌មានទាំងអស់នៅទីនេះ***

គណៈប្រតិភូរបស់អង្គការសហប្រជាជាតិដែលខ្ញុំមានកិត្តិយសដឹកនាំទើបតែបានបញ្ចប់បេសកកម្មរបស់ខ្លួន ដែលមានរយៈពេលមួយសប្តាហ៍ក្នុងប្រទេសកម្ពុជាដោយមានការជួបប្រជុំមួយជាមួយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នាពេលមុននេះបន្តិច ។ នេះជាទស្សនកិច្ចមួយដ៏មមាញឹកនិងពោរពេញដោយបញ្ហាដែលត្រូវខ្នះខ្នែងដោះស្រាយ ហើយក្នុងរយៈពេលនៃទស្សនកិច្ចនេះគណៈប្រតិភូរបស់យើងបានបើកការចរចាជាលក្ខណៈចំហ និងស្វែងរកភាពរីកចម្រើនមួយជាមួយក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយឯកឧត្តម សុខ អាន អំពីបញ្ហាជំនួយអង្គការសហប្រជាជាតិសម្រាប់តុលាការកម្ពុជាមួយដើម្បីនាំយកមកកាត់ទោសនូវជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដ៏គួរឲ្យភ័យរន្ធត់ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងសម័យកាលនៃ «របបកម្ពុជាប្រជាធិបតេយ្យ» ។

កំប៉ុន្តែយើងពុំទាន់បានឈានដល់កិច្ចព្រមព្រៀងទាំងស្រុងមួយនៅឡើយទេ ។ មានបញ្ហាពីរ-បីទៀតដែលធ្វើឲ្យភាគីទាំងពីរនៅឃ្លាតពីគ្នានៅឡើយ ។ កំប៉ុន្តែភាគីទាំងពីរបានធ្វើឲ្យមានការរីកចម្រើនដ៏សន្ធឹកសន្ធាប់ ហើយខ្ញុំផ្ទាល់មានការសប្បាយចិត្តយ៉ាងខ្លាំងនឹងបញ្ជាក់ជូនថាភាគីទាំងពីរបានបោះជំហានទៅមុខច្រើនហើយនៅលើផ្លូវមួយឆ្ពោះទៅរកភាពជោគជ័យជាងកាលពីមួយសប្តាហ៍មុននេះ ។

ខ្ញុំសូមបញ្ជាក់ថា ការចរចាទាំងនេះគឺជាការចរចាដែលក្នុងនោះបញ្ហាទាំងអស់ត្រូវបានពិភាក្សាយ៉ាងពេញលេញ និងព្យាយាមរកដំណោះស្រាយនានា ។ នៅក្នុងករណីមួយចំនួនភាគីទាំងសងខាងបានសុខចិត្តផ្លាស់ប្តូរគោលជំហររបស់ខ្លួនដើម្បីទទួលយកការព្រួយបារម្ភស្របច្បាប់នានារបស់ភាគីម្ខាងទៀត ។

មកទល់ពេលនេះ ខ្ញុំបានបញ្ជាក់យ៉ាងច្បាស់ដោយគ្មានបន្សល់ទុកនូវក្តីមន្ទិលសង្ស័យអ្វីទាំងអស់ដល់ភាគីចរចាកម្ពុជារបស់ខ្ញុំ អំពីលក្ខខណ្ឌជាកំហិតនានាដែលក្នុងលក្ខខណ្ឌទាំងនោះអង្គការសហប្រជាជាតិមានកាតព្វកិច្ចត្រូវធ្វើនៅក្នុងកិច្ចខិតខំប្រឹងប្រែងដែលមិនធ្លាប់មានពីមុនមក ។ ភាគីចរចាកម្ពុជាបានពន្យល់ត្រឡប់មកវិញថាភាគីកម្ពុជាពុំអាចសម្រេចកិច្ចព្រមព្រៀងចុងក្រោយមួយជាមួយភាគីអង្គការសហប្រជាជាតិរបស់យើងបានក្នុងពេលនេះទេ ត្រូវរង់ចាំរហូតដល់សភាជាតិកម្ពុជាបានពិភាក្សាលើបញ្ហានីតិកម្មដ៏ចាំបាច់ចប់សព្វគ្រប់សិន ។ ជាការពិតណាស់ប្រសិនបើពង្រាងច្បាប់នេះពុំទាន់ត្រូវបានបញ្ជូនទៅរដ្ឋសភាជាតិទេនោះប្រហែលជាងាយស្រួលជាងនេះ ។ ទោះបីជាយ៉ាងណាក៏ដោយជាធម្មតាយើងត្រូវគោរពសិទ្ធិអធិបតេយ្យភាពរបស់ប្រទេសកម្ពុជាដែលជារដ្ឋសមាជិកមួយរបស់អង្គការសហប្រជាជាតិក្នុងការដោះស្រាយបញ្ហានានាដែលនៅសេសសល់នៅក្នុងដំណើរការរដ្ឋធម្មនុញ្ញរបស់ខ្លួន ។

ភាគីកម្ពុជាបានសុំឲ្យផ្អាកការចរចានានារវាងភាគីទាំងពីរ ។ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការងាររបស់អាជ្ញាធរកម្ពុជាគណៈប្រតិភូអង្គការសហប្រជាជាតិរបស់យើងបានផ្តល់ជូនដល់រាជរដ្ឋាភិបាលកម្ពុជានូវសំណើដ៏ក្បោះក្បាយមួយដែលបញ្ជាក់គ្រប់ទិដ្ឋភាពទាំងអស់នៃបញ្ហាដែលនៅចំពោះមុខក្រុមរបស់យើង ។ គណៈប្រតិភូអង្គការសហប្រជាជាតិរបស់យើងមានជំនឿទុកចិត្តថា ចំណុចលម្អិតនៃសំណើទាំងនោះនឹងត្រូវបានរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋសភាជាតិយកមកពិចារណាយ៉ាង



លោក ហេន កូវែល

ពេញលេញនៅពេលដែលរាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋសភាជាតិកម្ពុជាពិចារណាការបង្កើតឡើងនូវតុលាការនេះដែលត្រូវតែជាឧបករណ៍យុត្តិធម៌មួយគួរឲ្យជឿទុកចិត្តបានដែលនឹងតម្រូវឲ្យមានការគោរពពីសហគមអន្តរជាតិ ហើយនិងការជឿជាក់របស់ប្រជាជនកម្ពុជា ។

មុនពេលវិលត្រឡប់ទៅកាន់ក្រុងញូវយ៉កវិញ ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់របស់ខ្ញុំចំពោះគណៈប្រតិភូនៃរាជរដ្ឋាភិបាលកម្ពុជាដែលបានចូលរួមក្នុងការចរចារបស់យើងក្នុងស្មារតីកិច្ចសហប្រតិបត្តិការមួយ ។ ខ្ញុំក៏សូមបញ្ជាក់បន្ថែមអំពីថាតើសមាជិកគណៈប្រតិភូរបស់ខ្ញុំ និងខ្លួនខ្ញុំផ្ទាល់មានអារម្មណ៍យ៉ាងក្តុកក្តួលជ្រាលជ្រៅប៉ុណ្ណា ក្នុងពេលទស្សនកិច្ចនៅជើងឯកកាលពីថ្ងៃអាទិត្យកន្លងទៅនេះ ។ ដូចដែលខ្ញុំបាននិយាយនៅពេលនោះរួចមកហើយថាស្រមោលវាលពិឃាតមានវត្តមានពេញក្នុងបន្ទប់ប្រជុំរបស់យើង ។ គឺដើម្បីជនរងគ្រោះកម្ពុជាក្នុងប៉ុន្មានឆ្នាំនៃអំពើដ៏គួរឲ្យភ័យរន្ធត់ទាំងនោះហើយដែលលោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានបញ្ជូនក្រុមយើងមកទីនេះហើយក៏ដើម្បីជនរងគ្រោះកម្ពុជាទាំងនោះហើយដែលខ្ញុំរង់ចាំឲ្យមានដំណោះស្រាយដ៏ឆាប់រហ័សមួយចំពោះបញ្ហាពីរ-បីទៀតដែលនៅសេសសល់ដើម្បីផ្តល់យុត្តិធម៌មួយនៅទីបញ្ចប់ ។ សូមអរគុណ!

◆◆◆ កាសែតរ៉យទ័រ បានរាយការណ៍ក្នុងថ្ងៃ២២ ខែមីនា ដែរថា ឯកឧត្តម ឱម យិនទៀង ដែលជាទីប្រឹក្សាជាន់ខ្ពស់របស់សម្តេច ហ៊ុន សែន បានមានប្រសាសន៍ថា «យើងសង្ឃឹមថាបន្ទាប់ពីច្បាប់នេះ ត្រូវបានអនុម័តដោយរដ្ឋសភាជាតិ រាជរដ្ឋាភិបាលនឹងមានបញ្ហាច្បាស់លាស់មួយនៅក្នុងដៃដើម្បីពិភាក្សាជាមួយអង្គការសហប្រជាជាតិ» ។

ឯកឧត្តម សុខ អាន ដែលជាប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជាបានមានប្រសាសន៍ថា«យើងមានសុទិដ្ឋិនិយមហើយសង្ឃឹមថាយើងនឹងឈានទៅសម្រេចបានកសម្រុះសម្រួលមួយជាមួយអង្គការសហប្រជាជាតិនៅពេលក្រោយ» ។

លោក ហែន កូវែល បានមានប្រសាសន៍ថា«នេះជាបញ្ហាផ្ទៃក្នុងមួយ ។ ប្រសិនបើភាគីទាំងសងខាងពុំអាចឈានដល់កិច្ចព្រមព្រៀង ជាការពិតណាស់ពេលនោះរដ្ឋអធិបតេយ្យមួយត្រូវសម្រេចថាត្រូវជ្រើសរើសយកផ្លូវមួយណាដោយខ្លួនឯង» ។

**(រូបថត និងជំនួយការយកពត៌មានៈ ទ្រី សុភក្តិ)**

# ការយល់ដឹងរបស់ខ្ញុំចំពោះបញ្ហាខ្មែរក្រហមៈ អតីតកាល និងបច្ចុប្បន្ន


ដាស៊ីលដែលមានអាយុ១ខួប ថតនៅជំរំ ខៅអ៊ីដាង ប្រទេសថៃ

បន្ទាប់ពីឃ្លាតឆ្ងាយពីប្រទេសកម្ពុជាតាំងពីអាយុ ១ខួប ខ្ញុំហាក់បីដូចជាយល់ថា ជាភ័ព្វសំណាងណាស់ដែលខ្ញុំពុំមានការចងចាំផ្ទាល់ខ្លួនអំពីរបបខ្មែរក្រហម ។ ក៏ប៉ុន្តែម្តាយរបស់ខ្ញុំធ្លាប់បានប្រាប់ខ្ញុំអំពីការចងចាំនិងការឈឺចាប់របស់គាត់ជាច្រើនរាប់មិនអស់ ។ ខ្ញុំពិតជាពុំបានដឹងនិងប៉ះពាល់ផ្លូវចិត្តអ្វីទាំងអស់ដោយរបបដ៏ភ័យរន្ធត់នៅក្នុងប្រទេសរបស់ខ្ញុំរហូតដល់ខ្ញុំបានចូលរៀនអនុវិទ្យាល័យ ។ ខ្ញុំគ្រាន់តែដឹងថាខ្មែរក្រហមសម្លាប់មនុស្សយ៉ាងសាហាវ និងអមនុស្សធម៌បំផុតក្នុងចន្លោះ ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ ខ្ញុំពុំបានដឹងអំពីស្ថិតិនៃហេតុការណ៍ជាច្រើនអំពីផ្នត់គំនិតពិត និងជំនឿផងទាំងពួងដែលជាប់ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៃរបបនេះថ្នាក់កំពូល រហូតដល់ជនរងគ្រោះតូចតាចបំផុតយ៉ាងណានោះទេ ។ នៅពេលដែលខ្ញុំសួរម្តាយរបស់ខ្ញុំនូវសំណួរជាច្រើនអំពីអ្វីដែលបានកើតឡើង ម្តាយខ្ញុំឆ្លើយមកវិញសង្កត់តែពីបញ្ហាថា ខ្ញុំពុំទាន់ធំល្មមនឹងស្តាប់រឿងដែលគាត់អាចប្រាប់នោះទេ ។ ដូច្នេះខ្ញុំពុំបានទទួលចម្លើយអ្វីអំពីម្តាយខ្ញុំសោះឡើយ ។ នៅពេលដែលខ្ញុំធំដឹងក្តីបន្តិច ម្តាយខ្ញុំបង្ហើបឲ្យដឹងរឿងច្រើនជាងមុន ។ សាច់រឿងរបស់គាត់ប្រែពីភាពធម្មតាទៅជាចម្លើយកំបុតៗ ហើយក្លាយទៅជាការរៀបរាប់អំពីរឿងរ៉ាវផ្ទាល់ខ្លួន និងមានលក្ខណៈពិស្តារជាងមុនៗ ។ នៅថ្ងៃមួយពេលដែលខ្ញុំដាក់ខ្លួនសម្រាកលើគ្រែម្តាយខ្ញុំបានប្រាប់ខ្ញុំអំពីប្រភេទអាហារផ្សេងៗ ដែលគាត់ទទួលទានជំនាន់ប៉ុល ពត ហើយសុទ្ធសឹងតែជាប្រភេទអាហារ ដែលខ្ញុំពុំដែលនឹកគិតដល់និងអំពីការលំបាកដែលគាត់ធ្វើពលកម្មពេញៗមួយថ្ងៃនៅតាមវាលស្រែ ។ ម្តាយខ្ញុំប្រាប់ថានៅពេលយប់មានឡានប្រភេទឡានកងទ័ពចិនមកដឹកស្រូវជាសម្ងាត់ទៅបាត់អស់នូវស្រូវដែលម្តាយខ្ញុំប្រូតបាន ។ គាត់ធ្វើការដូចមនុស្សយន្ត ។ រឿងរ៉ាវទាំងនេះគ្រាន់តែជាពត៌មានលម្អិតគួរឲ្យព្រឺព្រួចមួយចំនួនតូចប៉ុណ្ណោះ ដែលគាត់បានបន្ទុំចិត្តប្រាប់ខ្ញុំ ។ ពេញមួយឆ្នាំសិក្សានៅអនុវិទ្យាល័យរបស់ខ្ញុំការយល់ដឹងជុំវិញបញ្ហាខ្មែរក្រហម គឺបានមកពីម្តាយរបស់ខ្ញុំទាំងអស់ ។ នៅពេលដែលខ្ញុំឈានចូលវិទ្យាល័យ ហើយបានសិក្សាអំពីប្រវត្តិសាស្ត្រពិភពលោកដែលជាផ្នែកមួយនៃកម្មវិធីសិក្សាថ្នាក់ទី៩នៃវិទ្យាល័យ វេកហៀល នៅអាលីងតុន រដ្ឋវឺជីញៀរ ខ្ញុំបានគិតថាខ្ញុំច្បាស់ជារៀនអំពីខ្មែរក្រហម ។ ប៉ុន្តែពេញមួយកម្មវិធីសិក្សាថ្នាក់របស់ខ្ញុំត្រូវរៀនទ្វីបទាំងបួននៃពិភពលោកពេញបួនត្រីមាស គឺនៅអាមេរិកឡាទីន អាហ្វ្រិច អឺរ៉ុបនិងទ្វីបអាស៊ី ។ ប្រសិនបើអំពើប្រល័យពូជសាសន៍មកលើជនជាតិជ្វីហ្វត្រូវបានបង្រៀន ហើយចាត់ទុកថាជាទិដ្ឋភាពដ៏អសីលធម៌និងគួរឲ្យអាម៉ាស់បំផុតរបស់មនុស្សជាតិ អ៊ីចឹងនោះការប្រព្រឹត្តដោយពួកខ្មែរក្រហមដែលមានទំហំប្រហាក់ប្រហែលគ្នានេះដែរប្រាកដជាយកមកបង្រៀនដែរ ក៏ប៉ុន្តែការគិតរបស់ខ្ញុំប្រែជាខុសទៅវិញ ។ ខ្ញុំពុំបានរៀនអំពីកម្ពុជាទេក្រៅតែពីទីតាំងភូមិសាស្ត្រកម្ពុជាដែលមិត្តរួមថ្នាក់ខ្ញុំទាំងអស់ប្រហែលជាភ្លេចអស់បាត់ទៅហើយ ។ ចំពោះមិត្តភក្តិរបស់ខ្ញុំប្រទេសកម្ពុជាពុំមានអ្វីសំខាន់សម្រាប់ខ្លួនគេឡើយ ។ នៅពេលនោះហើយដែលខ្ញុំចាប់ផ្តើមបង្រៀនខ្លួនខ្ញុំអំពីប្រវត្តិសាស្ត្ររបស់ប្រទេសខ្ញុំ ដែលជាប្រវត្តិសាស្ត្រសម្រាប់ពិភពលោក ។ នៅពេលនោះហើយ ដែលខ្ញុំចាប់ផ្តើមដឹងជាលើកដំបូងអំពីចិត្តសាស្ត្រដែលគួរឲ្យរំខានចិត្តនៃ «បដិវត្តន៍» ។ខ្ញុំបានអានសៀវភៅទាក់ទងនឹងរបបខ្មែរក្រហម ប៉ុន្តែនៅតែពុំយល់អំពីគោលដៅដាច់ខាតរបស់ប្រទេសដ៏ថ្មីសន្ធាងមួយដែលរបបខ្មែរក្រហមបង្កើតឡើង ដែលជារឿងមួយដ៏ចម្លែកបានចាប់ផ្តើមជាថ្មីពីឆ្នាំសូន្យ ហើយគ្រប់គ្រងប្រទេសតាមឥទ្ធិពលរបស់ម៉ៅ ។ ខ្ញុំមិនយល់ថាតើរបបនេះដំណើរការតាមរបៀបណាលើឆាកអន្តរជាតិបើគ្មាន

អ្នកចេះដឹងនៅសល់ ។ ទោះបីជាខ្ញុំយល់អំពីភាពសមហេតុសមផលរបស់ខ្មែរក្រហមថាអ្នកទន់ខ្សោយក្មេងៗ ហើយអត់បានរៀនចេះដឹងគឺជាមនុស្សដែលស្រួលបំផុតក្នុងការដឹកច្រមុះក៏ដោយ ។ អ្វីដែលពិតជាធ្វើឲ្យខ្ញុំជឿងឆ្ងល់បំផុតនោះគឺថាមានពេលមួយនោះមានក្មេងស្រីស្រុកស្រែតូចមួយ ហើយបន្ទាប់មកក្មេងស្រីនោះក៏ស្លាប់ ឬត្រូវបានក្លាយទៅជាមេពេជ្ឈឃាតទៅវិញ ។ នៅមានសំណួរជាច្រើនទៀតដែលពុំទាន់ទទួលបានឆ្លើយ ហើយនៅពេលដែលខ្ញុំធ្វើការស្រាវជ្រាវបន្ថែមទៀតខ្ញុំកាន់តែជឿងឆ្ងល់ តក់ស្លុត និងវង្វេងវង្វាន់ក្នុងអារម្មណ៍កាន់តែខ្លាំងឡើង ។ តាមពិតជាលើកដំបូងដែលខ្ញុំបានសង្កេតនិងស្គាល់ឈ្មោះ«ប៉ុលពត» នៅលើក្រដាសកិច្ចការដែលសាលាដាក់ឲ្យធ្វើនៅវិទ្យាល័យ គឺនៅពេលដែលឈ្មោះនេះលេចចេញនៅក្នុងឃ្លាមួយនៃកិច្ចការទាំងមូល ។ចម្លែកមែនទែននៅពេលដែលខ្ញុំផ្តោតអានប្រយោគនោះខ្ញុំសើចតិចៗម្នាក់ឯងដោយហួសចិត្ត ។ ក្រោយមកទើបខ្ញុំសម្រេចចិត្តវិលមកប្រទេសកម្ពុជាវិញ ជាលើកដំបូងក្នុងរដូវក្តៅឆ្នាំ១៩៩៩ ។ ពេលនោះហើយទើបខ្ញុំបានយល់ដឹងពិតអំពីកម្ពុជា និងអតីតកាលរបស់ប្រទេសខ្ញុំ ។ បន្ទាប់ពីការទៅលេងឪពុកមាររបស់ខ្ញុំរួចមក ទើបខ្ញុំបានដឹងថាអ្វីដែលខ្ញុំបានដឹងទាំងអស់ពីមុនមកអំពីប្រទេសកម្ពុជា គឺគ្រាន់តែជាចំណេះដឹងសើរៗទាក់ទិននឹងរបបដែលដឹកនាំដោយ ប៉ុល ពត ប៉ុណ្ណោះ ។ បន្ទាប់ពីនោះខ្ញុំបានដឹងអំពីបញ្ហានាពេលបច្ចុប្បន្នជាច្រើនដែលពាក់ព័ន្ធជាមួយនឹងកម្ពុជា ជាពិសេសបញ្ហានានាដែលពាក់ព័ន្ធជាមួយខ្មែរក្រហមកិច្ចការស្រាវជ្រាវឯកសារខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកម្ពុជា រួមទាំងគម្រោងសាងសង់វិទ្យាស្ថានមជ្ឈមណ្ឌលឯកសារថ្មីមួយ និងការវិវត្តន៍ជុំវិញសម្រាប់អង្គជំនុំជម្រះក្តីមួយ ដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។

ខ្ញុំបានទទួលអត្ថបទជាច្រើនអំពីបញ្ហាខ្មែរក្រហមដែលត្រូវបានបញ្ជូនតាមរយៈប្រព័ន្ធអ៊ិធឺរនិត អំពីឪពុកមាររបស់ខ្ញុំ ។ ការអានអត្ថបទជាបន្តបន្ទាប់បានអនុញ្ញាតឲ្យខ្ញុំស្ទើរតែស៊ាំទៅនឹងប្រធានបទទាំងនោះ ដូចជាបញ្ហាចរចាច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមរវាងសម្តេចហ៊ុន សែន និងអង្គការសហប្រជាជាតិ ។ អត្ថបទភាគច្រើនពាក់ព័ន្ធជាមួយនឹងការជជែកវែកញែកដ៏លំបាកស្មុគស្មាញ និងអូសបន្លាយរវាងអង្គការសហប្រជាជាតិ និងសម្តេចហ៊ុន សែន និងមន្ត្រីរដ្ឋាភិបាលដទៃទៀតអំពីចំណុចលម្អិតរបស់តុលាការអំពីបញ្ហាថា នរណា (កម្ពុជា ឬអង្គការសហប្រជាជាតិ) ជាអ្នកគ្រប់គ្រងលើការស៊ើបអង្កេតការតែងតាំងចៅក្រមខ្មែរ និងបទេសព្រមជាមួយបញ្ហាដទៃទៀត ដូចជាមេដឹកនាំខ្មែរក្រហមដែលត្រូវបានផ្តល់ការលើកលែងទោស និងអំពីការការពារសាក្សីជាដើម ។ ចំពោះខ្លួនខ្ញុំផ្ទាល់ប្រាកដជាគាំទ្រអង្គការនិងការឲ្យហេតុផលរបស់សហប្រជាជាតិ ។ តុលាការកានេះគួរមានអ្នកស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិ និងសំខាន់ជាងនេះគឺភាពលើសលប់របស់អង្គការសហប្រជាជាតិ ពីព្រោះជាការពិតណាស់ថា ប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ន គឺទន់ខ្សោយ ។ ហេតុដូច្នេះ ងាយស្រួលនឹងទទួលឥទ្ធិពលនយោបាយ និងភាពពុករលួយណាស់ ។ មិនតែប៉ុណ្ណោះមានបញ្ហានៃការលើកលែងទោសដែលត្រូវបានផ្តល់ឲ្យក៏ប៉ុន្តែការផ្តល់នូវការលើកលែងទោសគឺពុំ



យុត្តិធម៌ និងធ្វើដោយសេរី ហេតុដូច្នេះហើយពុំមានសុពលភាព ដោយមូលហេតុថាការលើកលែងទោសទាំងនោះ ពុំមែនសម្រាប់មនុស្សដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចនៅក្នុងករណីនេះទេ ។ ការប្រព្រឹត្តបែបនេះពុំអាចត្រូវអត់ទោស និងបន្ទាប់មកបំភ្លេចចោលងាយៗបែបនេះឡើយ ។ ចំពោះការអះអាងថាតុលាការជំនុំជម្រះក្តី មេដឹកនាំខ្មែរក្រហមនឹងនាំមកនូវការបែកបាក់ជាថ្មីដល់ប្រទេសយើងជាដំបូងខ្ញុំត្រូវទុកការអស់សំណើចនិងការភ្ញាក់ផ្អើលមួយកន្លែងសិនហើយសុំសួរទៅវិញថា ហេតុអ្វីបានអាចនិយាយបែបនេះទៅកើត ។ តើភ្លេចហើយ ឬថាមិនយូរប៉ុន្មានមុននេះប្រជាជនកម្ពុជាប៉ុន្មាននាក់ដែលមិនត្រឹមតែត្រូវបានរើសអើងស្អប់ខ្ពើម ប៉ុន្តែថែមទាំងត្រូវបានសម្លាប់យ៉ាងសាហាវឃោរឃៅដែរនោះ? ការផ្សះផ្សាជាតិអាចចេញផ្លែផ្កា លុះត្រាណាបើមានការបិទទំព័រព្រឹត្តិការណ៍ដ៏គួរឲ្យតក់ស្លុតនេះ ដោយវិធីដ៏មានសុពលភាព និងបរិសុទ្ធ ។ ការបិទទំព័រដ៏ជូរចត់នេះនឹងមកដល់នៅពេលដែលមានតុលាការ ដែលនឹងពិតជាអាចរកយុត្តិធម៌ជូនព្រលឹងជនរងគ្រោះជិត២លាននាក់ ហើយនិងមិត្តភក្តិគ្រួសារដែលនៅរស់ ។ តុលាការនេះនឹងជាមេរៀនដ៏ពិតប្រាកដមួយចំពោះកូនខ្មែរ និងសហគមអន្តរជាតិ ។ កំហុសធ្ងន់ដល់កម្រិតនេះត្រូវតែផ្តល់នូវមេរៀនដ៏ស័ក្តិសមមួយ ហើយអ្នកដែលប្រព្រឹត្តអំពើទាំងនោះត្រូវទទួលនូវផលវិបាកទាំងនោះដោយខានមិនបាន ។ ប្រសិនបើសួរអតីតមេដឹកនាំខ្មែរក្រហមថាតើត្រូវដាក់ទោសយ៉ាងដូម្តេចនោះ មេខ្មែរក្រហមទាំងនោះច្បាស់ជាឆ្លើយថាដាក់ទោសបន្តិចបន្តួច ឬក៏សុំខមាទោស ។ ចំពោះការដាក់ទោសមេដឹកនាំខ្មែរក្រហម ដែលគួរទទួលការសាទរគឺអាស្រ័យទៅនឹងកម្រិតនៃការចូលរួមនៅក្នុង «ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅកម្ពុជា» ហើយគួរតែត្រូវថ្កោលទោសចំពោះជនរងគ្រោះដែលនៅរស់ផ្ទាល់ ។ ការស្លាប់ភ្លាមៗពុំមែនជាដំណោះស្រាយ ។ ត្រូវអនុញ្ញាតឲ្យសាធារណជនបានឃើញស្តាប់និងនិយាយតាមចិត្តឲ្យអស់ចិត្តចំពោះជនដៃដល់ដែលបានសម្លាប់ក្រុមគ្រួសាររបស់ខ្លួន ។ ចំណុចសំខាន់គឺមេខ្មែរក្រហមទាំងនោះចាំបាច់ត្រូវដឹងអំពីភាពសាហាវឃោរឃៅនៃអ្វីដែលខ្លួនបានប្រព្រឹត្តថាតើមានអារម្មណ៍ដឹងកំហុសខ្លួនដែរឬទេ?



សេចក្តីសង្ឃឹមដ៏ខ្ពស់បំផុសរបស់ខ្ញុំ គឺតុលាការនេះនឹងមិនក្លាយជាព្រឹត្តិការណ៍ដ៏អាម៉ាស់មួយ ហើយនិងមិនមែនជាការប្រឌិតឡើងគ្មានយុត្តិធម៌ពិតប្រាកដ ។អ្នកទាំងឡាយដែលពាក់ព័ន្ធចាំបាច់ត្រូវនាំខ្លួនឲ្យចេញមុខជាសាធារណៈដើម្បីប្រឈមមុខនឹងប្រជាជនកម្ពុជានិងពិភពលោក ។ **ពៅ ដាសុីល**

## ការកែតម្រូវចំពោះទស្សនាវដ្តីស្វែងរកការពិត លេខ១ ខែមករា ឆ្នាំ២០០០

នៅផ្នែកឯកសារទំព័រទី២៣ បន្ទាត់ទី២ នៃអត្ថបទក្រោមចំណងជើងថា «តើ ទីវ មុី ចូលបម្រើសុី.អាយ.អេ ធ្វើសកម្មភាពអ្វីខ្លះប្រឆាំងនឹងរបបខ្មែរក្រហម?» សូមកែពី «ឆ្នាំ១៩៩៧» ទៅជា «ឆ្នាំ១៩៧៧» ។

ខ្ញុំបាទសូមអភ័យ ទោសចំពោះកំហុសដោយអចេតនានេះ និងសូមអរគុណចំពោះលោក ហង្ស បូ សាស្ត្រាចារ្យប្រវត្តិសាស្ត្រនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានជួយកែតម្រូវកំហុសខាងលើ ។

**ឆាំង យុ**

រឿងក្តីពីណូចេ ដោយ រីដ ប្រូដឌី

# ព្រឹត្តិការណ៍ដ៏សំខាន់

# ប្រទេសឈីលី បានជំរុញឱ្យយកអតីតជនផ្តាច់ការមកធ្វើការកាត់ទោស

(ក្រុងញូវយ៉ក ថ្ងៃទី ២ ខែមីនា ឆ្នាំ២០០០)

អង្គការឃ្លាំមើលសិទ្ធិមនុស្សបានចេញសេចក្តីប្រកាសថា ការចាប់ខ្លួនអតីតប្រមុខរដ្ឋប្រទេសឈីលី អូហ្គាស្តូ ពីណូចេ បានបង្ហាញពីការវិវត្តន៍ជាអចិន្ត្រៃយ៍មួយក្នុងបុព្វហេតុសិទ្ធិមនុស្ស ទោះបីមានសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអង់គ្លេស ដែលអនុញ្ញាតឲ្យគាត់ត្រឡប់ទៅប្រទេសឈីលីវិញយ៉ាងណាក៏ដោយ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សក៏បានអំពាវនាវឲ្យសភាឈីលីរាំងខ្ទប់សំណើធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដែលមានបំណងផ្តល់ឲ្យអតីតប្រមុខរដ្ឋទាំងអស់នូវអភ័យឯកសិទ្ធិអចិន្ត្រៃយ៍រួចពីការកាត់ទោស ។

លោក រីដ ប្រូដឌី នាយកផ្នែកជំរុញលើកកម្ពស់សិទ្ធិមនុស្សនៃអង្គការឃ្លាំមើលសិទ្ធិមនុស្សបាននិយាយថា «បើពីណូចេមិនត្រូវបានកាត់ទោសនៅប្រទេសអេស្ប៉ាញទេ នោះវានឹងធ្វើឲ្យជនរងគ្រោះរាប់ពាន់នាក់ខកចិត្តខ្លាំងណាស់» ។ លោកបានបន្ថែមទៀតថា «ការចាប់ខ្លួនពីណូចេនិងការបដិសេធការទាមទារអភ័យឯកសិទ្ធិរបស់គាត់បានផ្លាស់ប្តូរការគិតគូររបស់ជនផ្តាច់ការនៅជុំវិញពិភពលោករួចទៅហើយ ។ រឿងក្តីពីណូចេជាការចាប់ផ្តើមនៃការបញ្ចប់ភាពរួចទោសរបស់មេដឹកនាំផ្តាច់ការទាំងអស់នោះ» ។

អង្គការឃ្លាំមើលសិទ្ធិមនុស្សបានកត់សម្គាល់ថា «គំរូរបស់ពីណូចេបានចាក់ឫសគល់ក្នុងប្រទេសដទៃទៀតរួចទៅហើយ» ។ នេះជាការលើកទឹកចិត្តដល់សេចក្តីសម្រេចថ្ងៃ៣ខែកុម្ភៈ របស់ចៅក្រមសេណេហ្គាល ដែលធ្វើការផ្តន្ទាទោសអតីតជនផ្តាច់ការ ហ៊ីសេន ហាប្រេ អំពីបទវាយដំធ្វើទារុណកម្ម ។ លោក ប្រូដឌី បាននិយាយថា «ការផ្លាស់ប្តូរដ៏ធំមួយគឺវិធីដែលពិភពលោកនាពេលបច្ចុប្បន្នដោះស្រាយការរំលោភបំពានធ្ងន់ធ្ងរ» ។

រឿងក្តីពីណូចេបានបញ្ជាក់ឡើងវិញពីគោលការណ៍ថា អំពើឃោរឃៅរំលោភបំពានលើសិទ្ធិមនុស្សជា«ដែនសមត្ថកិច្ចសកល» ហើយអាចធ្វើការកាត់ទោសនៅគ្រប់ទីកន្លែងក្នុងពិភពលោក ។ សេចក្តីសម្រេចពីររបស់សភាជាន់ខ្ពស់របស់ចក្រភពអង់គ្លេសបានបង្ហាញថា ពីណូចេ ពុំមានអភ័យឯកសិទ្ធិរួចពីការកាត់ទោសទេទោះបីគាត់ធ្លាប់ជាប្រមុខរដ្ឋនាសម័យដែលបទល្មើសត្រូវបានប្រព្រឹត្តក៏ដោយ ។

អង្គការឃ្លាំមើលសិទ្ធិមនុស្សក៏បានអំពាវនាវឲ្យមានការប្រុងប្រយ័ត្នចំពោះសំណើវិសោធនកម្មរដ្ឋធម្មនុញ្ញក្នុងប្រទេសឈីលី ដែលអាចផ្តល់ឲ្យអតីតប្រមុខរដ្ឋទាំងអស់នូវអភ័យឯកសិទ្ធិអចិន្ត្រៃយ៍ ។ មានការរំពឹងថា សភាឈីលីនឹងចេញវិធានការថ្មីនៅដំណាច់ខែមីនានេះ ។

លោក ចូសេ មីហ្គែល វីវ៉ាន់កូ នាយកប្រតិបត្តិនៃអង្គការឃ្លាំមើលសិទ្ធិមនុស្សសម្រាប់ទ្វីបអាមេរិកបាននិយាយថា «ច្បាប់នេះនឹងផ្តល់នូវគំរូដ៏អាក្រក់មួយ ។ វាមិនត្រឹមតែធ្វើឲ្យការយកពីណូចេទៅកាត់ទោសកាន់តែលំបាកទេ វាថែមទាំងធ្វើឲ្យស្ថាប័នប្រជាធិបតេយ្យប្រទេសឈីលីចុះខ្សោយទៀតផង» ។

ឧត្តមសេនីយ៍ ពីណូចេ បានរៀបចំសម្រាប់ខ្លួនគាត់នូវឋានៈជាព្រឹទ្ធសមាជិកមួយជីវិតនាពេលដែលគាត់ចាកចេញពីអំណាចនៅឆ្នាំ១៩៩០ ដើម្បីធ្វើឲ្យប្រាកដនូវអភ័យឯកសិទ្ធិរបស់គាត់រួចពីការកាត់ទោស ។ ប៉ុន្តែចាប់តាំងពីអតីតជនផ្តាច់ការរូបនេះត្រូវបានចាប់ខ្លួននៅទីក្រុងឡុង តុលាការឈីលីបានបង្ហាញពីឆន្ទៈរបស់ខ្លួនកាន់តែច្បាស់ឡើងក្នុងការធ្វើការប្តឹងគាត់ ។

ប្រសិនបើពីណូចេត្រូវបានឲ្យរួចខ្លួនពីការកាត់ទោសដោយហេតុផលសុខភាពនៅពេលគាត់ត្រឡប់មកវិញ អ្នកច្បាប់និងសកម្មជនសិទ្ធិមនុស្សឈីលីរំពឹងថានឹងធ្វើការប្តឹងដើម្បីដកអភ័យឯកសិទ្ធិរបស់គាត់ទាំងស្រុង ។ សំណើវិសោធនកម្មអាចធ្វើឲ្យកិច្ចការនេះកាន់តែស្មុគស្មាញថែមទៀត ។ ច្បាប់ថ្មីរបស់ឈីលីអាចផ្តល់ឲ្យមន្ត្រីសាធារណៈរបស់ប្រទេសនេះនូវអភ័យឯកសិទ្ធិដ៏ធំធេងបំផុតក្នុងទ្វីបអាមេរិក ។

ក្នុងពេលដែលប្រទេសឈីលីកំពុងតែស្ថិតក្នុងពេលវិស្សមកាលរដូវក្តៅប្រចាំឆ្នាំ លោកប្រធានាធិបតី អេដួអាដូ ហ្វ្រេ បានផ្តល់ឲ្យសំណើវិសោធនកម្មខាងលើនូវឋានៈ «ប្រញាប់ខ្លាំង» នៅថ្ងៃទី១៩ ខែមករា ហើយសំណើនេះត្រូវបានសភាជាន់ទាបអនុម័តដោយពុំបានធ្វើការកែប្រែអ្វីទាំងអស់នៅថ្ងៃទី២៥ ខែមករា ។ គម្រោងនឹងត្រូវអនុម័តក្នុងរយៈពេល៦០ថ្ងៃ ដោយសម័យប្រជុំពេញអង្គនៃសភាឈីលីទាំងពីរ ។ ដូច្នេះគម្រោងច្បាប់នេះអាចក្លាយជាច្បាប់នៅសប្តាហ៍ចុងក្រោយនាខែមីនានេះ ។



## គ្រួសាររបស់ខ្ញុំក្រោមរបប ប៉ុល ពត

បំណងដ៏សំខាន់បំផុត ដែលមនុស្សក្នុងលោកយើងនេះតែងតែនោះគឺសេចក្តីសុខ ភាពសំបូររុងរឿងនិងការរស់នៅ ជួបជុំក្រុមគ្រួសារញាតិសន្តានរបស់ខ្លួន ។ ជាអកុសលក្រុមគ្រួសាររបស់ខ្ញុំបានជួបប្រទះនូវភាពឈឺចាប់និងការនិរាសព្រាត់ប្រាស់មួយដែលលំបាកពិពណ៌នាជាតួអក្សរ ។ ការព្រាត់ប្រាសនេះកើតឡើងនៅក្នុងរបបខ្មែរក្រហមក្នុងចន្លោះឆ្នាំ ១៩៧៥ - ១៩៧៩ ។ ក្នុងខណៈនោះខ្ញុំមានអាយុប្រហែល១០ឆ្នាំ ជាកូនប្រុសប្អូនបង្អស់ក្នុងចំណោមបងប្អូនប្រុសពីរនាក់និងស្រីម្នាក់ ។ ប៉ារបស់ខ្ញុំឈ្មោះ រស់ សមណ្ឌរៈ គឺជាមន្ត្រីរាជការម្នាក់ក្នុងក្រសួងសុរិយោដីក្រុងភ្នំពេញនៃរបបសាធារណរដ្ឋខ្មែរ ។ ម្តាយរបស់ខ្ញុំឈ្មោះ ឈឹម គុង គឺជាអ្នកលក់ដូរគ្រឿងត្បូង ។ បងប្រុសរបស់ខ្ញុំឈ្មោះ រស់ សមណ្ឌរៈរុងរឿង ជាសិស្សនៅវិទ្យាល័យ ១៨មីនា ។ បងស្រីរបស់ឈ្មោះ រស់ សមណ្ឌរៈ បុទុមរ័ត្ន ជាសិស្សនៅវិទ្យាល័យបាក់ទូក ។

តាមពិតទៅប៉ារបស់ខ្ញុំគឺមានខ្សែស្រឡាយខ្លះដែរនឹងខ្សែស្រឡាយស៊ីសុវត្ថិ ។ ចំណែកឯម៉ាក់របស់ខ្ញុំវិញ គាត់ជាកូនចិនកាត់ខ្មែរ ។ ទោះបីជាប៉ារបស់ខ្ញុំជាមន្ត្រីម្នាក់របស់របបសាធារណរដ្ឋខ្មែរក៏ដោយ គាត់បានបម្រើចលនាខ្មែររំដោះក្នុងឋានៈជាកម្លាំងបង្កប់ "**សីហនុនិយម**" ដែលមានតួនាទីក្នុងការផ្តល់ស្បៀង លុយកាក់ និងថ្នាំដង្កូវឲ្យទៅកម្លាំងតស៊ូនៅក្នុងព្រៃ ។

អំពើដែលគាត់បានធ្វើទាំងប៉ុន្មានខាងលើនេះ គឺបានផ្តល់លទ្ធផលមកវិញ ក្រោយថ្ងៃរំដោះរបស់ពួកខ្មែរក្រហមគឺរូបគាត់ផ្ទាល់ព្រមទាំងម៉ាក់របស់ខ្ញុំត្រូវពួកវាយកទៅសម្លាប់ ។ ចំណែកឯបងប្រុសនិងបងស្រីខ្ញុំពីរនាក់ទៀតត្រូវបានស្លាប់ដោយការអត់អាហារយ៉ាងអណោចអធមជាទីបំផុត ។

**១) ថ្ងៃទី ១៧ មេសា ឆ្នាំ១៩៧៥:**

អ្នកជិតខាងជាច្រើនដែលមានលំនៅដ្ឋាននៅជិតផ្ទះរបស់ខ្ញុំគឺមានសភាពសប្បាយអឺងកងខុសប្លែកពីធម្មតា ពីព្រោះយល់ថា សង្គ្រាមត្រូវបានបញ្ចប់ ។ ប្រហែលជាម៉ោង ៩:៣០ នាទីព្រឹក ក្នុងខណៈដែលរូបខ្ញុំកំពុងតែអង្គុយលេងលើកាំជណ្តើរមុខផ្ទះខ្ញុំបានឮសូរសម្លេងផ្ទុះក្តាំង១! ខ្ទាំង១និងមានផ្សែងខ្មៅហុយឡើងលើផងខ្ញុំក៏ស្ទុះរត់ចូលទៅក្នុងផ្ទះហើយសួរប៉ារបស់ខ្ញុំថាៈ

-សម្លេងអីផ្ទុះប៉ា! ខ្ញុំភ័យដល់ហើយ ។

-ប៉ាខ្ញុំឆ្លើយថា សម្លេងគ្រាប់បែកផ្ទុះណា៎កូន ប៉ុន្តែមិនអីទេកូន ព្រោះគ្រាប់នេះវាជាគ្រាប់ខាងយើងទេ ស្រុកយើងសាន្តត្រាណហើយកូន អស់សង្គ្រាមហើយសំបូរសប្បាយទៀតណា៎ ។ ក្រោយពីប៉ារបស់ខ្ញុំនិយាយថាស្រុកយើងសាន្តត្រាណអស់សង្គ្រាមហើយសំបូរសប្បាយនោះ ខ្ញុំនៅតែនឹកគិតក្នុងចិត្តតែម្នាក់ឯងថា ស្រុកអស់សង្គ្រាម! ចុះហេតុអ្វីក៏មានសម្លេងគ្រាប់ផ្ទុះទៀត? រំពេចនោះខ្ញុំក៏ស្ទុះចេញទៅខាងក្រៅរបងមុខផ្ទះ ស្រាប់តែខ្ញុំឃើញមនុស្សប្រុសបីនាក់ ក្នុងសម្លៀកបំពាក់ខ្មៅប្រដាប់ដោយអាវុធគ្រប់ដៃមូរជើងខោទាំងបីនាក់កំពុងឈរនៅខាងមុខផ្ទះមួយដែលជាផ្ទះរបស់មេទាហាននៃរបបសាធារណរដ្ឋខ្មែរ ហើយបានលើកកាំភ្លើងវែងបាញ់ទៅលើទ្វាររបងបីគ្រាប់ ព្រមទាំងនិយាយថា ផ្ទះនេះជាផ្ទះរបស់អាយ៉ងអាមេរិកកាំង ជាពួកក្បត់ជាតិ ក្បត់ប្រជាជន តើពួកអ្ហែងទៅណាបាត់អស់ហើយចេញមកជួបអញមួយភ្លែត! ក្រោយពីឮសំដីនេះព្រមទាំងបានឃើញនូវទង្វើរបស់ខ្មែរក្រហមមក ខ្ញុំមានអារម្មណ៍ដូចជារន្ធត់បន្តិច

ក្តៅបន្តិច ព្រោះថាខ្ញុំមិនដែលឃើញគេបាញ់កាំភ្លើង និងប្រើសម្តីស៊ាហាវឃោរឃៅយ៉ាងនេះដោយផ្ទាល់ភ្នែកសោះពីមុនមក ។ ពេលនោះខ្ញុំក៏ស្ទុះចូលក្នុងផ្ទះព្រមទាំងចាក់សោរទ្វារបងផង ហើយដើរតម្រង់ទៅរកប៉ារបស់ខ្ញុំដែលគាត់កំពុងតែជួសជុលឡាន ក្នុងរោងឡានចំហៀងផ្ទះព្រមទាំងសួរគាត់ថាទាហានអាវខ្មៅបីនាក់នោះ ជាទាហានខាងណាប៉ា បានជាកាចយ៉ាងនេះប៉ា!? ប៉ាខ្ញុំឆ្លើយមកវិញ យ៉ាងរហ័សថា កុំនិយាយព្រោកកូន ពួកគេគឺជាទាហានរំដោះ របស់សម្តេចឪយើងពួកគេជាមនុស្សល្អណាកូនកុំភ័យអីគេមិនធ្វើអីយើងទេណា! គឺពួកគេរកអ្នកណាដែលក្បត់នឹងគេតែប៉ុណ្ណោះ ។ ទន្ទឹមនឹងប៉ាខ្ញុំកំពុងនិយាយជាមួយខ្ញុំនេះ ទាហានទាំងបីនាក់ក៏បានដើរមកដល់មុខផ្ទះរបស់ខ្ញុំ ហើយក៏ស្រែកខ្លាំងៗថា បើកទ្វារមកសុំចូលផង! រំពេចនោះប៉ារបស់ខ្ញុំបានស្ទុះទៅបើកទ្វាររបងយ៉ាងលឿនហើយក៏អញ្ជើញពួកគេឲ្យចូលមកអង្គុយលេងខាងមុខផ្ទះ ជនម្នាក់ក្នុងចំណោមពួកគេទាំងបីបានសួរមកកាន់ប៉ារបស់ខ្ញុំថាៈ អ៊ឹងឯងអត់មានបើកវិទ្យុទេអី! ។ ប៉ាខ្ញុំគាត់ក៏ឆ្លើយទៅវិញថា អត់បានបើកផងក្អួយ! ព្រោះជាប់ដៃជួសជុលឡានណាក្អួយ! ប៉ុន្តែទន្ទឹមនឹងនោះដែរប៉ាខ្ញុំក៏បានស្រែកហៅបងប្រុសរបស់ខ្ញុំឲ្យយកវិទ្យុចេញមកបើកខាងក្រៅផ្ទះ ។ ចន្លោះពេលដែលបងប្រុសខ្ញុំកាន់វិទ្យុចេញមកក្រៅនោះជនអាវខ្មៅម្នាក់បានសួរមកប៉ាខ្ញុំថាៈ អ៊ឹងឯងធ្វើទាហានលន់ នល់ ឬ? ប៉ារបស់ខ្ញុំបានឆ្លើយថាៈ អត់ទេក្អួយ! អ៊ំធ្វើនៅក្រសួងសុរិយោដីទេ! វាសួរទៀតថាៈ ស្អីទៅក្រសួងសុរិយោដី! ភ្នែកទាំងគូរបស់ពួកវាបានសម្លឹងយ៉ាងមុតមកលើប៉ារបស់ខ្ញុំតាំងពីក្បាលរហូតដល់ចុងជើង ។ បន្ទាប់មកប៉ារបស់ខ្ញុំក៏បាននិយាយទៅកាន់ពួកវាថាៈ ពិសារទឹកកកឲ្យត្រជាក់បំពង់កសិនទៅក្អួយ! ក្រសួងសុរិយោដីគឺជាផ្នែកមួយខាងមើលដីធ្លីផ្ទះសម្បែងក្នុងការសាងសង់ ឲ្យស្របទៅតាមច្បាប់ណាក្អួយ! ។ និយាយឲ្យត្រង់ទៅគ្រួសារអ៊ំក៏បានចូលរួមយ៉ាងសកម្មក្នុងចលនារំដោះជាតិដែរ ទោះបីជាអ៊ំមិនដែលកាន់អាវុធតស៊ូនៅក្នុងព្រៃដូចក្អួយៗក៏ដោយ ប៉ុន្តែអ៊ំបានចូលរួមវិភាគទានជាលុយកាក់ស្បៀងអាហារ និងថ្នាំពេទ្យជារៀងរាល់ខែដល់កម្លាំងរបស់យើងនៅក្នុងព្រៃ ។ ក្នុងខណៈដែលប៉ារបស់ខ្ញុំកំពុងនិយាយមានគ្នាវាម្នាក់ដែលមានអាយុចំណាស់ជាងគេក្នុងចំណោមពួកវាបានមើលមុខប៉ារបស់ខ្ញុំហាក់បីដូចជាចង់សួរមកប៉ាខ្ញុំអ៊ីចឹង ។ រំពេចនោះវាក៏សួរមកកាន់ប៉ាខ្ញុំថាតើខាងយើងមានដែលចារលិខិតបញ្ឆោកអីអោយ



មកអ៊ំដែរឬទេ? ។ ប៉ារបស់ខ្ញុំបានឆ្លើយថាៈ ឲ្យមួយសន្លឹកដែរតែដោយសារកាលនោះមានគេមកឆែកផ្ទះម្តងហើយប្រពន្ធខ្ញុំក៏បានយកវាទៅលាក់តែឥឡូវនេះ វង្វេងដៃបាត់ទៅហើយក្អួយអើយ! ប៉ុន្តែមិនអីទេបើយើង គេចាត់ទុកថាជាអ្នកមានគុណបំណាច់ច្បាស់ជាគេមិនភ្លេចយើងទេក្អួយអើយ! ពិសេសអ៊ំមិនចង់បានអីទេ ឲ្យតែស្រុកយើងសាន្តត្រាណសម្បូរសប្បាយនោះវាជាការប្រសើរទៅហើយ ។ ទន្ទឹមនឹងការនិយាយឆ្លងឆ្លើយគ្នាទៅវិញទៅមកនោះ បងប្រុសខ្ញុំបានកាន់វិទ្យុមកដល់ក្រៅព្រមទាំងមកបើកសម្លេងស្រាប់តែម្តង ហើយក៏ប៉ះចំសេចក្តីថ្លែងការណ៍មួយដែលមានសម្លេងទន់ហើយមួយៗ (ខ្ញុំមិនស្គាល់ឈ្មោះនរណាកំពុងនិយាយនោះទេព្រោះខ្ញុំនៅក្មេងពេក) ស្តីពីជ័យជំនះនៃការរំដោះទីក្រុងភ្នំពេញ និងប្រទេសទាំងមូលគឺបានមកពីការចរចានិង

បង្រួបបង្រួមគ្នារវាងខ្មែរនិងខ្មែរ ។ ប៉ាំរបស់ខ្ញុំមានទឹកមុខញញឹមរួសរាយចំណែកឯពួកវាទាំងបីនាក់គឺមានទឹកមុខស្មើដដែល ប៉ុន្តែស្របនឹងពេលនោះដែរ ស្រាប់តែមានសេចក្តីថ្លែងការណ៍មួយទៀតមកកាត់នឹងសេចក្តីថ្លែងការណ៍ដំបូងដែលមានសម្លេងខ្លាំងៗដាច់ៗថាៈ ជ័យជំនះនេះមិនមែនបានមកពីការចរចានិងបង្រួបបង្រួមគ្នាទេគឺបានមកពីការតស៊ូដោយចុងអាវុធនិងចុងអាវុធទេ ។ ក្រោយពីស្តាប់ចប់សេចក្តីថ្លែងការណ៍នោះមកប៉ាំរបស់ខ្ញុំបានផ្លាស់ប្តូរទឹកមុខខុសប្លែក ម៉ាក់របស់ខ្ញុំសម្លឹងមើលមកប៉ាំខ្ញុំដោយការងឿងឆ្ងល់ និងបងប្រុស និងបងស្រីរបស់ខ្ញុំបានសម្លឹងមកម៉ាក់ខ្ញុំដោយការងឿងឆ្ងល់និងការភ័យភិត ព្រោះផ្ទៃមុខប៉ាំរបស់ខ្ញុំ ហាក់បីដូចជាពោរពេញទៅដោយភាពអស់សង្ឃឹម ។ មួយសន្ទុះក្រោយមកជនអាវខ្មៅទាំងបីបានងើបឈរឡើងហើយពីរនាក់បានយួរកាំភ្លើងដើរឆ្ពោះទៅមុខផ្ទះផ្នែកខាងក្រៅរបងហើយអាម្នាក់ទៀតបានដើរមកជិតឡានដែលប៉ាំខ្ញុំកំពុងតែជួសជុលនោះ ហើយយកដៃមួលគម្របធុងទឹកឡាន ហើយនិយាយថា «ក្រុមគ្រួសាររបស់អ៊ឹនិងអ្នកឯទៀតនឹងត្រូវចេញពីផ្ទះទាំងអស់ហើយនិងពុំដឹងថាតើនៅពេលណាទេនឹងត្រូវវិលចូលវិញនោះ ។ អ្វីដែលខ្ញុំនិយាយគឺជាការពិត! អ៊ឹចាំទុកទៅ! អ្វីដែលគេនិយាយថាៈគ្រាន់តែចេញបណ្តោះអាសន្ន២ឬ៣ថ្ងៃខ្លាចអាមេរិកទម្លាក់គ្រាប់បែកនោះពុំមែនជាការពិតទេ ។» បន្ទាប់មកទាហានទាំងបីនាក់បានដើរចេញពីផ្ទះរបស់ខ្ញុំវិញ ដោយពុំមាននិយាយពាក្យថាលាមួយម៉ាត់សោះ ។ បន្ទាប់ពីដើរចេញបានប្រហែលជា ៥០ម៉ែត្រពីផ្ទះអាគ្នាវាម្នាក់ដែលមានវ័យក្មេងជាងគេបានលើកកាំភ្លើងខ្លីរបស់វាបាញ់ឡើងទៅលើចំនួន៤-៥គ្រាប់ហើយស្រែកថាអ្នកនៅម្តុំនេះស្អែកត្រូវតែចេញឲ្យអស់ពីទីនេះ ។ ភាពសប្បាយរីករាយបានក្លាយជាការអស់សង្ឃឹមអ្នកជិតខាងផ្ទះរបស់ខ្ញុំដែលធ្លាប់តែឮសូរសម្លេងអ៊ូអរកងរំពងនោះក៏បានប្រែក្លាយទៅជាស្ងាត់ជ្រងំ ផ្ទៃមេឃមួយភាគធំនៃភាគខាងជើងឆៀងខាងលិចទីក្រុងភ្នំពេញ ពោរពេញទៅដោយអណ្តាតភ្លើងក្រហមច្រាល ។ នៅក្នុងផ្ទះ ម៉ាក់ខ្ញុំរលីងរលោងទឹកភ្នែកកំពុងតែរៀបចំសម្លៀកបំពាក់ចូលទៅក្នុងការ៉ុង ចានឆ្នាំង ស្បៀងអាហារដើម្បីរៀបចំដាក់ចូលទៅក្នុងឡានសម្រាប់ការធ្វើដំណើរចាកចេញពីលំនៅដ្ឋាននៅព្រឹកថ្ងៃស្អែកនេះ ។

## ២) ការជម្លៀសខ្លួនជាជនបញ្ញើៈ

គ្រួសាររបស់ខ្ញុំបានជម្លៀសខ្លួនចេញពីក្រុងភ្នំពេញជាមួយនិងកូនរថយន្តមួយ ដែលផ្ទុកពោរពេញទៅដោយការ៉ុងសម្លៀកបំពាក់ ចានឆ្នាំង និងស្បៀងអាហារ តាមបណ្តោយផ្លូវជាតិលេខ២ ។ មនុស្សរាប់សែននាក់បានធ្វើដំណើរតាមបណ្តោយផ្លូវយ៉ាងណែនតាន់តាប់ដោយគ្មានទិសដៅ ។ គ្រួសារខ្លះដែលមានជាប់ពាក់ពន្ធ័នឹងនិន្នាការនយោបាយពុំអាចធ្វើដំណើរទៅស្រុកកំណើតរបស់ខ្លួនក៏ធ្វើដំណើរទៅទីកន្លែងផ្សេងៗ គ្រួសារខ្លះដែលមានសមាជិកក្នុងគ្រួសារជាទាហានឬប៉ូលិស ហើយត្រូវបានពួកអាវខ្មៅស្គាល់ច្បាស់ ក៏ត្រូវបានចាប់ខ្លួនតាមផ្លូវជាបណ្តើរៗ ។ អ្នកជំងឺខ្លះត្រូវបានស្លាប់តាមផ្លូវ ស្ត្រីមានផ្ទៃពោះខ្លះត្រូវបានឆ្លងទន្លេតាមផ្លូវ ។ លុះធ្វើដំណើរអស់រយៈពេលប្រហែលជាមួយសប្តាហ៍ គ្រួសាររបស់ខ្ញុំក៏សម្រេចចិត្តស្នាក់នៅជាបណ្តោះអាសន្ននៅក្នុងស្រុកគិរីវង្ស ខេត្តតាកែវ ដែលពេលនោះខ្ញុំពុំបានចាំច្បាស់ថានៅក្នុងភូមិឈ្មោះអ្វីនោះទេ ។ ប្រធានភូមិបាននាំគ្រួសារខ្ញុំទៅផ្ញើនឹងគ្រួសារអ្នកមូលដ្ឋានម្នាក់ ។ ក្រោយពីបានស្នាក់នៅអស់រយៈពេលជាងមួយខែក្នុងភូមិនោះមកអង្គការឃុំរបស់ពួកខ្មែរក្រហមបានស្នើសុំឡានរបស់ប៉ាំខ្ញុំដាក់ជាសម្បត្តិសមូហភាពដើម្បីដោះយកសំបកកង់និងពោះវៀនធ្វើជាស្បែកជើងពាក់ ។ ប៉ាំរបស់ខ្ញុំត្រូវបានពួកវាចាត់តាំងឲ្យទៅកាប់ឫស្សីដើម្បីត្បាញជាព្រួលនិងរនាបផ្ទះ ។ ចំណែកឯម៉ាក់របស់ខ្ញុំត្រូវបានប្រធាននារីភូមិជ្រើសតាំងឲ្យទៅស្ទូង និងកាប់ឆ្ការព្រៃធ្វើជាចម្ការសម្រាប់ដាំបន្លែបន្លែផ្សេងៗនៅលើទីទួលក្នុងភូមិ ។ បងប្រុសនិងបងស្រីរបស់ខ្ញុំវិញ ត្រូវបានចាត់តាំងឲ្យទៅលើកទំនប់និងជីកប្រឡាយនៅតាមការដ្ឋានចល័តនានា ។ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបែកគ្នាតាំងពីព្រលឹមរហូតព្រលប់ងងឹតព្រាលៗទើបបានជួបមុខគ្នា ។ តាំងតែពីដើមមកគ្រួសារខ្ញុំមិនដែលស្គាល់អ្វីដែលហៅថាការលំបាកឬការអត់ឃ្លាននោះទេតែដល់ពេលជួបប្រទះរឿងយ៉ាងនេះម៉ាក់ខ្ញុំត្រូវខំស៊ុះស្មុរបេះបន្លែបន្លែផ្សេងៗដែលគាត់បានស្គាល់តាមរយៈស្រុកភូមិ ដើម្បីយកមកផ្សំគ្នាជាមួយរបបអាហារ ។ ចំណែកបងប្រុសនិងបងស្រីខ្ញុំវិញ កាលពីមុនមកពុំ

ដែលពុកនិងដឹងអំពីរបៀបនៃការរកចាប់ក្តាមខ្យងនោះ ក៏ពួកគាត់បានព្យាយាម មើលគេនិងរៀនសូត្រតាមគេទោះបីជាពួកមូលដ្ឋានចាស់និយាយប្រាសផ្ទេះថា «ពួកអាអ្នកភ្នំពេញជាពួកអាល្ងង់ចេះតែស៊ីមិនចេះធ្វើ» យ៉ាងណាក៏ដោយ ។ រៀងរាល់យប់ក្រោយពីការទទួលទានអាហារក្រោមពន្លឺភ្លើងចង្រ្កានរួចមកខ្ញុំតែងតែសង្កេតឃើញប៉ារបស់ខ្ញុំអង្គុយតែម្នាក់ឯងនៅក្នុងផ្ទះដែលធ្វើអំពីដើមឫស្សីកម្ពស់ ពីដីប្រហែលកន្លះម៉ែត្រក្រាលទៅដោយរនាបឫស្សី និងប្រក់ស្លឹកត្នោតតែប៉ុណ្ណោះ ។ ចំណែកឯម៉ាក់របស់ខ្ញុំវិញ គេងនៅជិតពួកខ្ញុំដៃរបស់គាត់បានអង្អែលក្បាលរបស់ខ្ញុំទាំងទឹកភ្នែករលីងរលោងព្រមទាំងពោលថា «ម៉ាក់ ហត់នឿយណាស់កូន! ចាប់ពីពេលនេះទៅកូនៗត្រូវចេះមើលថែទាំខ្លួនដោយខ្លួនឯង ពួកយើងនឹងត្រូវព្រាត់ប្រាស់គ្នាតែមិនដឹងនៅពេលណា» ។ ក្រោយពីខ្ញុំបានឮម៉ាក់ខ្ញុំនិយាយយ៉ាងនេះមកខ្ញុំហាក់បីដូចជាមានអារម្មណ៍ថាខ្លួនរបស់ខ្ញុំស្រាលបំផុត ហើយបានកំពុងតែហោះហើរទៅយ៉ាងឆ្ងាយពីក្រុមគ្រួសារ ហើយខ្ញុំក៏បានគិតទៀតថា «ចុះបើខ្ញុំត្រូវបែកពីឪពុកម្តាយបងប្អូន តើខ្ញុំត្រូវរស់យ៉ាងដូចម្តេចទៅ?» ។ ទន្ទឹមនឹងការគិតវិលវល់ជុំវិញបញ្ហានេះមកខ្ញុំក៏គេងលក់ទៅ ទាំងម៉ាក់របស់ខ្ញុំកំពុងនិយាយតែម្នាក់ឯង ។





ក្រោយពីរស់នៅក្នុងភូមិខាងលើបានប្រហែលជា២ខែមក គ្រួសាររបស់ខ្ញុំព្រមទាំងគ្រួសារផ្សេងៗទៀតប្រហែលជាជាងដប់គ្រួសារត្រូវបានពួកវាប្រមូលយកទៅកាន់វត្តអង្គរទំលាប់ ។ ដោយការហូបចុកពុំឆ្អែតធ្វើការហួសកម្លាំង និងគ្មានថ្នាំសង្កូវគ្រប់គ្រាន់ ប៉ារបស់ខ្ញុំក៏ធ្លាក់ខ្លួនឈឺគ្រុនក្តៅ ម៉ាក់ខ្ញុំត្រូវហើមជើងទាំងពីរ ចំណែកបងស្រីរបស់ខ្ញុំវិញបានកើតជំងឺទាចទឹក ឯខ្ញុំនិងបងប្រុសធ្លាក់ខ្លួនស្គមកំព្រឹង ។ ម៉ាក់ខ្ញុំបានប្រមែលប្រមូលយកកេរអាកររបស់គាត់ខ្លះទៅដូរយកថ្នាំពេទ្យនិងអង្ករពីអ្នកមូលដ្ឋានចាស់ដែលនៅក្នុងភូមិវត្តអង្គរទំលាប់ ដើម្បីយកមកព្យាបាលប៉ានិងបងស្រី ។ ទោះបីជាប៉ារបស់ខ្ញុំធ្លាក់ខ្លួនឈឺយ៉ាងនេះក្តីក៏ខ្ញុំពុំដែលឮគាត់និយាយថាលំបាកណាស់ ឬក៏ឈឺចាប់ក្នុងខ្លួនណាស់នោះទេ ។ ក្រោយពីបានថ្នាំសង្កូវ និងអង្ករខ្លះដែលបានពីការដោះដូរនោះមកជំងឺរបស់ប៉ា និងបងស្រីបានធូរស្រាលមួយកម្រិតធំ ។ លុះក្រោយមកខ្ញុំឮស្ករប្រធានភូមិ បានប្រមូលប្រជាជនដែលរស់នៅក្នុងកន្លែងវត្តអង្គរទំលាប់មកប្រជុំប្រាប់ថា៖ អ្នកដែលនៅទីនេះទាំងអស់ត្រូវអង្គការផ្លាស់ឲ្យទៅនៅកន្លែងថ្មីមួយទៀតពីព្រោះទីនេះគ្រាន់តែផ្ញើឲ្យនៅបណ្តោះអាសន្នទេ ហើយមិនបាច់ យកអីទៅច្រើនពេកទេ ព្រោះនៅទីនោះអង្គការបានរៀបចំឲ្យសព្វគ្រប់អស់ហើយ ហើយជាពិសេសបើអ្នកណាដែលធ្លាប់ធ្វើអីពីមុននៅក្នុងរបបសាធារណរដ្ឋខ្មែរនោះត្រូវរាយការណ៍មកអង្គការ អង្គការនឹងឲ្យចូលធ្វើនៅកន្លែងដើមវិញហើយអ្នកណាធ្លាប់រស់នៅឯណាត្រូវឲ្យវិលទៅកាន់កន្លែងនោះវិញ ។

## ៤) គុកឥតជញ្ជាំង៖

មិនយូរប៉ុន្មាន គ្រួសាររបស់ខ្ញុំព្រមទាំងរាប់រយគ្រួសារផ្សេងទៀតត្រូវបានបញ្ជូនតាមរថភ្លើងឆ្ពោះទៅកាន់ខេត្តបាត់ដំបង ។ បន្ទាប់មកគ្រួសាររបស់ខ្ញុំត្រូវបានដឹកតាមរថយន្តត្រាក់ទ័របន្ត

ឆ្ពោះមកកាន់ភ្នំត្រលោក ដែលស្ថិតនៅក្នុងភូមិរំដួល ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង ។ នៅតាមជើងភ្នំនេះមានប្រជាជនទាំងថ្មីនិងអ្នកមូលដ្ឋានចាស់ប្រហែលជាងដប់គ្រួសារតែប៉ុណ្ណោះ នៅទីនោះប្រជាជនថ្មីត្រូវពួកវាឲ្យកាប់ឆ្ការព្រៃដើម្បីដាំដូចជាដំឡូងមី ដំឡូងជ្វា និងបន្លែផ្សេងៗ ។ ចំណែកពួកអ្នកមូលដ្ឋានចាស់គឺទុកសម្រាប់ទុកត្រួតត្រាមើលប្រជាជនថ្មី និងចិញ្ចឹមដង្កូវនាងធ្វើសូត្រដើម្បីត្បាញ ។ លុះនៅទីនោះមួយរយៈធំមកទើបយើងដឹងថា អ្នកដែលពួកវាយកឲ្យមកនៅទីនេះគឺជាអ្នកដែលត្រូវបានដាក់ទោស ។ ប៉ាខ្ញុំត្រូវបានបញ្ជាឲ្យចូលព្រៃឡើងភ្នំរកផ្ដៅនិងវល្លិ៍ ដើម្បីត្បាញជាកញ្ច្រែ ល្អី បង្គី....។ល។ ចំណែកម៉ាក់ខ្ញុំខ្មែរក្រហមឲ្យកាប់ឆ្ការព្រៃនិងគាស់គល់ឈើធំៗដើម្បីបានយកផ្ទៃដីសម្រាប់ធ្វើចម្ការ ។ បងប្រុសនិងបងស្រីរបស់ខ្ញុំត្រូវបញ្ជូនឲ្យទៅលើកទំនប់ជីកប្រឡាយនៅឯកងចល័តស្រួច ។ ចំណែកខ្ញុំវិញត្រូវឃ្វាលគោ និងកាប់ដើមទន្ទ្រានខែត្រ មកចិញ្ច្រាំលាយជាមួយលាមកគោធ្វើជីដាក់ស្រែចម្ការ ។ ចាប់ពីពេលនោះមកគ្រួសារខ្ញុំចាប់ផ្ដើមបែកខ្ញែកគ្នា ។ ប៉ានិងម៉ាក់ខ្ញុំត្រូវទៅបាត់តាំងពីព្រឹករហូតដល់ព្រលប់ទើបត្រឡប់មកវិញ បងៗរបស់ខ្ញុំត្រូវបានបញ្ជូនទៅកាន់កងចល័តស្រួចបាត់មិនដឹងថាតើនៅទីណានោះទេ ។ ពួកយើងទទួលបានរបបអាហារក្នុង១ថ្ងៃគឺមានតែបបររាវៗមួយចានចង្កឹះម្នាក់តែប៉ុណ្ណោះ ។ នៅពេលយប់ត្រូវបានគេហាមមិនឲ្យនិយាយគ្នា មិនឲ្យមានពន្លឺភ្លើង ចង្ក្រានឆេះប្រសិនបើអ្នកណាហ៊ានធ្វើខុសនឹងបទបញ្ជានេះ អ្នកនោះនឹងត្រូវបញ្ជូនឲ្យទៅកាប់ឫស្សី ។ អ្នកដែលគេបញ្ជូនឲ្យទៅកាប់ឫស្សីមិនងាយបានត្រឡប់មកវិញទេ «មានន័យថា យកទៅសម្លាប់ចោល» ។



ដូច្នេះនៅទីនោះមានសភាពស្ងាត់ ជ្រងំដូចទឹកប់ខ្មោចអឺបឹងទាំងថ្ងៃទាំងយប់ ។

គ្រួសារខ្ញុំស្ថិតនៅទីនោះអស់រយៈពេលប្រហែលជា១ឆ្នាំក្នុងក្ដីឈឺចាប់និងការអត់ឃ្លាន ។ ប៉ាខ្ញុំក៏ចាប់ផ្ដើមទទួលនូវជំងឺគ្រុនចាញ់ ។ ម៉ាក់ក៏ចាប់ផ្ដើមឈឺឡើងវិញនូវជំងឺហើមដៃហើមជើង ។ ចំណែកខ្ញុំត្រូវកើតនូវជំងឺកមរមាស់ពេញទាំងខ្លួនប្រាណនិងស្គមសល់តែស្បែកដណ្ដប់ឆ្អឹងតែប៉ុណ្ណោះ ។ ជាអកុសលជាងនេះទៅទៀតម៉ាក់របស់ខ្ញុំបានទទួលដំណឹងមួយយ៉ាងរន្ធត់បំផុតមកថា បងស្រីខ្ញុំដែលនៅឯកងចល័តឯណោះបានស្លាប់បាត់ទៅហើយ ។ មិនយូរប៉ុន្មានផងប៉ារបស់ខ្ញុំក៏ត្រូវពួកវាយកទៅសម្លាប់ចោលដោយអយុត្តិធម៌បំផុត ដោយវាបានចោទគាត់ថាជាអាយ៉ងរបស់អា លន់ ណុល ជាពួកអារដ្ឋការក្បត់ ។ ខ្ញុំនៅចាំបានថាតាំងតែពីមុនពេលដែលពួកវាយកគាត់ទៅសម្លាប់ម្ល៉េះ ទោះបីជាគាត់ត្រូវពួកវាបង្ខំឲ្យធ្វើការគ្មានពេលសម្រាកគ្មានអាហារគ្រប់គ្រាន់ ហើយជាពិសេសទៅទៀតខ្លួនគាត់ផ្ទាល់កំពុងតែមានជំងឺក្នុងខ្លួនក៏គាត់មិនដែលត្អូញប្រាប់ប្រពន្ធកូនមួយម៉ាត់ដែរ ។ ប៉ុន្តែគាត់ហាក់បីដូចជាដឹងខ្លួនមុន គាត់បាននិយាយផ្ដាំខ្ញុំថា «ប្រសិនបើអត់ពីប៉ាទៅកូនត្រូវមើលថែទាំម្ដាយនិងបង យើងគង់តែស្លាប់ទាំងអស់គ្នាទេ គ្រាន់តែពុំដឹងអ្នកណាទៅមុនអ្នកណាទៅក្រោយប៉ុណ្ណោះ» ។ គាត់ធ្លាប់បាននិយាយប្រាប់ខ្ញុំដែរថាគាត់ស្ដាយណាស់! គាត់សែនស្ដាយណាស់នូវពាក្យដែលបងប្រុសគាត់ម្នាក់ជាមេទាហានជើងគោក និងប្អូនប្រុសពៅម្នាក់ទៀតជាអាកាសយានិកយោធានៃរបបសាធារណរដ្ឋខ្មែរ ។

**(នៅមានត)**

**រស់ សុមណ្ឌៈ ឧុឡៅ**

*លិខិតពីខេត្តក្រចេះ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០*

## គោរពជូន លោកប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ជាទីគោរពរាប់អានដ៏ខ្ពង់ខ្ពស់

ជាបឋម ខ្ញុំបាទសូមសម្តែងនូវអំណរគុណ និងពរស្វាគមន៍ដោយស្មោះស្ម័គ្របំផុតចំពោះលោកប្រធានមជ្ឈមណ្ឌលនិងសហការីទាំងអស់នៃមជ្ឈមណ្ឌលឯកសារកម្ពុជានូវទឹកចិត្តសោមនស្សរីករាយយ៉ាងក្រៃលែងបំផុត ក្រោយពីទទួលបានលិខិតរបស់លោក និងទស្សនាវដ្តី «ស្វែងរកការពិត» ពោរពេញដោយខ្លឹមសារដ៏ជ្រាលជ្រៅ ។

លោកប្រធានមជ្ឈមណ្ឌលជាទីស្នេហា! ថ្វីត្បិតតែរូបខ្ញុំពុំដែលបានជួបលោកផ្ទាល់ក៏ពិតមែន ប៉ុន្តែខ្ញុំធ្លាប់បានសហការដោយស្មោះជាមួយលោក ផាត កុសល ជាអនុប្រធានមជ្ឈមណ្ឌល កាលចុះស្រាវជ្រាវផ្ទាល់នៅបណ្តាទីតាំងសំខាន់ៗនៅក្នុងខេត្តក្រចេះយើងខ្ញុំ ។ ខ្ញុំមានការរំភើបចិត្ត និងរំជួលចិត្តយ៉ាងខ្លាំងក្រោយពីបានអានបណ្តាអត្ថបទ និងរូបភាពដែលមានក្នុងទស្សនាវដ្តី ដោយរូបខ្ញុំផ្ទាល់ជាជនរងគ្រោះម្នាក់ដោយរបបខ្មែរក្រហមបានកាប់សម្លាប់ឪពុកម្តាយ ឪពុកក្មេក និងម្តាយក្មេកនិងប្រពន្ធ កូនប្រុស ស្រី ៣នាក់ ដោយចោទថាខ្មែរ កាហ្សេបេ មានចំនួនសរុបជាង១០នាក់នៅខេត្តក្រចេះ ។ ខ្ញុំមានសេចក្តីត្រេកអរ និងទឹកចិត្តរីករាយរួមជាមួយអ្នកអានជាច្រើនប្រមាណ ៨០នាក់ ក្រោយទទួលការយល់ដឹងច្បាស់ថា «ទស្សនាវដ្តីស្វែងរកការពិតជាទស្សនាវដ្តីឯករាជ្យខាងផ្លូវនយោបាយដែលមានរូបលោកជានាយក ហើយមានច្បាប់អន្តរជាតិជាច្រើនរួបរួមសម្រេចបាននូវបណ្តាអត្ថបទទាំងអស់នេះ» ពិសេសគឺការដែលបង្កឲ្យមានឯកសារគ្រប់គ្រាន់ឈានទៅដល់ការបើកតុលាការកាត់ទោសរបបប្រល័យពូជសាសន៍មួយនៅកម្ពុជាក្នុងពេលខាងមុខជាចាំបាច់ ។ នោះគឺជាបំណងប្រាថ្នាដ៏ទទូចរបស់ប្រជាពលរដ្ឋខ្មែរដែលកំពុងមានជីវិតរស់រាននៅបច្ចុប្បន្ន ក៏ដូចជាវិញ្ញាណក្ខន្ធលោកឪពុកអ្នកម្តាយដែលបានបាត់បង់ជីវិតក្រោមរបបទមិឡអន្យតិរ្ថិយប្រល័យពូជសាសន៍ឯង ដើម្បីឲ្យវិញ្ញាណក្ខន្ធអស់លោក-អ្នកទាំងនោះបានស្ងាប់ក្នុងសុគតិភពនាស្ថានបរលោក ។ម្យ៉ាងទៀតក្នុងន័យទាមទារយុត្តិធម៌ទាំងផ្លូវលោក និងផ្លូវធម៌ទាំងច្បាប់ធម្មជាតិ និងច្បាប់អន្តរជាតិ ដែលសាកលលោកបានឃើញនិងដឹងឮច្បាស់លាស់បំផុតនោះ ។ លោកប្រធានជាទីរាប់អានខ្ពង់ខ្ពស់! បញ្ហាតុលាការកាត់ទោសមេក្លោងខ្មែរក្រហមដែលមានយន្តការដឹកនាំជាតិមាតុភូមិឲ្យធ្លាក់ក្នុងជ្រោះដ៏ជ្រៅនៃរណ្តៅមរណៈនេះជាប្រការដែលត្រូវមានជាចាំបាច់បំផុតមិនអាចលើកលែងបាន ។ ប្រការនេះជាប្រការដែលមនុស្សជាតិលើសកលលោក ពិសេសក្នុងសហស្សវត្សរ៍ថ្មីទាមទារឲ្យកើតមានការកាត់ទោសនេះ ដូចជាៈ ការកាត់ទោសឧត្តមសេនីយ ពីណូចេ,.. និងមេដឹកនាំប្រទេសផ្សេងទៀត ដែលអនុវត្តន៍របបផ្តាច់ការហ្វាស៊ីសនោះ ។ ចំណុចដែលត្រូវធ្វើមិនអាចពន្យាពេលឲ្យអូសបន្លាយបានទាល់តែសោះនោះ គឺមិនត្រូវទុកឲ្យមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យនោះធ្លាក់ទៅក្នុងជរាភាពឬស្លាប់បាត់បង់តាមធម្មជាតិឬប្រការផ្សេងទៀត ។ ពោលគឺត្រូវមានតុលាការកាត់ទោសឲ្យបានឆាប់មុនពេលដែលពួកគាត់ទទួលមរណភាព ។ បញ្ហាដែលកំពុងចោទនៅពេលចំពោះមុខនោះរដ្ឋាភិបាលក៏បានលើកឡើងដែរថាតើតុលាការជាតិឬតុលាការអន្តរជាតិ?



ចៅក្រមជាតិខ្មែរប៉ុន្មាន និងចៅក្រមអន្តរជាតិប៉ុន្មាន? នីតិវិធីត្រូវធ្វើបែបណានោះ ខ្ញុំបាទពុំហ៊ានបញ្ចេញយោបល់ទេ ព្រោះបញ្ហានេះស្ថិតក្នុងភាពស្មុគស្មាញ និងចាក់ស្រេះយ៉ាងខ្លាំង ព្រោះវាទាក់ទងយ៉ាងច្រើនដល់មេដឹកនាំនៃប្រទេសមួយចំនួនទាំងប្រទេសមហាអំណាចផងដែរ ។ ឧទាហរណ៍ៈ លោក បែនសុន សម័យ មេធាវីការពារតាម៉ុក បានធ្វើបទសម្ភាសន៍តាមទូរទស្សន៍ថា... តាម៉ុកនឹងឆ្លើយពាក់ព័ន្ធរហូត រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិកទៀត តាមឯកសារដែលមាន...និងថ្នាក់ដឹកនាំនៃប្រទេសមួយចំនួនទៀតផង... ។ល ។និង ។ល ។ ចំពោះការផ្ដល់យោបល់ ឬដំបូន្មានថាតើត្រូវធ្វើដូចម្ដេចឲ្យបានប្រសើរ និងមានប្រសិទ្ធភាពបំផុតក្នុងការបម្រើសាធារណជន និងជាពិសេសចំពោះជនរងគ្រោះលើបញ្ហាប្រវត្តិសាស្ត្រ និងការកាត់ទោសរបបខ្មែរក្រហមនោះខ្ញុំបាទពុំមានយោបល់ប្លែក ឬដំបូន្មានអ្វីឲ្យលើសពីផែនការ ឬកម្មវិធីដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំហើយនោះឡើយ ។ ដើម្បីបំពេញបន្ថែមខ្លះៗលើបណ្ដាចំណុចដែលបានពេញចិត្តហើយនៅលើទំព័រនៃទស្សនាវដ្ដីនេះ ខ្ញុំបាទសូមមានសំណូមពរខ្លះៗលើការផ្សារបោះពុម្ពដូចមានចំណុចខ្លះខាងក្រោមនេះ ÷ ១-សំណូមពរសុំឲ្យខ្នាតអក្សរពុម្ពបានធំជាងនេះបន្តិចងាយស្រួលក្នុងការមើលអាន ព្រោះថាបើអ្នកមានអាយុចាប់ពី៤៥ឆ្នាំឡើង បើគ្មានវ៉ែនតាពង្រីកមើលទេនោះមិនអាច មើលឃើញបានឡើយ ។ ២-ចំពោះរូបថតដែលមានផ្ដិតជាប់នៅលើទំព័រ សូមមានចំណងជើងខ្លីសង្ខេបពីក្រោមតាមការគួរមិនចាំបាច់ដាក់ខាងក្រោយក្របដែលមានអាចតាមដានមើលដោយឆ្លងទំព័រឆ្ងាយ ។ ៣-ទស្សនាវដ្ដីគួរបង្កើតទំព័រខាងចុង «មតិអ្នកអាន» ដែលប្រមូលយោបល់ពីគ្រប់មជ្ឈដ្ឋាន និងគ្រប់ស្រទាប់ទាំងកម្មករ កសិករ-បញ្ញវ័ន្ត-ព្រះសង្ឃ និងជនជាតិ... បានបញ្ចេញទស្សនៈ និងគំនិតហើយបានផ្សាយនៅលើទំព័រទស្សនាវដ្ដីផង ។ ៤-គួរតែបន្ថែមបរិមាណចំនួនទស្សនាវដ្ដីឲ្យបានដល់លោកគ្រូមេគណៈខេត្ត មួយក្បាល ព្រោះខេត្តមានតែជាង២០ ម៉្លោះហើយមេគណៈខេត្ត (មន្ត្រីជាប្រធានសង្ឃខេត្តមានតែមួយអង្គប៉ុណ្ណោះក្នុងខេត្តនីមួយៗ) ព្រោះបណ្ដាវត្តនៅប្រទេសកម្ពុជាសុទ្ធតែបានទទួលរងផលធ្ងន់ធ្ងរពីរបប ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ហើយវត្តភាគច្រើនសុទ្ធតែក្លាយជាគុក ជាមណ្ឌលឧក្រិដ្ឋកម្ម ជាមណ្ឌលប្រមូលផ្ដុំនៃអំពើទារុណកម្មច្រើនបែបច្រើនយ៉ាង ឧទាហរណ៍ វត្តចំពុះក្អែក ខេត្តកណ្ដាល វត្តជ្រោយអំពិល ឃុំចំបក់ ខេត្តក្រចេះ អណ្ដូងទឹកវត្ត ជាកន្លែងទម្លាក់សាកសពរាប់រយនាក់... ។ល ។ ៥-សំណូមពរផ្ទាល់ខ្លួន សុំលោកនាកយកមេត្តាផ្ដល់ឲ្យខ្ញុំជារៀងរាល់ខែផង ដើម្បីតាមដាននៅលេខក្រោយៗទៀតដោយខ្ញុំបាទនឹងរួមសហការជាប់ជានិច្ចទាំងការផ្ដល់ឯកសារជូនក៏ដូចជាអត្ថបទផ្សេងៗទៀតដែលជាប់ទាក់ទងលើការផ្សារនេះតាមលទ្ធភាពដែលខ្ញុំបាទអាចជួយ ឧបត្ថម្ភបានឲ្យអស់ពីលទ្ធភាព និងសមត្ថភាពរបស់ខ្លួន ។ នៅទីបញ្ចប់នេះ ខ្ញុំបាទសូមថ្លែងនូវអំណរគុណសាជាថ្មីម្ដងទៀតចំពោះ លោកនាយកនិងសហសេវិក និងសូមឲ្យបេសកកម្មជាប្រវត្តិសាស្ត្រនេះឈានទៅសម្រេចជោគជ័យ ។ ទីចុងបញ្ចប់ សូមគោរពជូនពរជ័យ សិរីសួស្ដី មហាបវរសូមមានឋាមពលសុខភាពល្អសម្រេចបន្តគ្រប់ភារៈ ។ សូមបួងសួងអស់ទេវតា នៅសួគ៌កាមាសូមថ្នមថ្នាក់ លោក ឆាំង យុ ឈ្នះឧបសគ្គ ឈ្នះចោរអប្បលក្ខណ៍ជានិច្ចនិរន្តរ៍ ។

**អ៊ុច ស៊ុនឡាយ**

**នាយកការិយាល័យសារពត៌មាន សាលាខេត្តក្រចេះ**

---

**គោរពជូនលោក អ៊ុច ស៊ុនឡាយ**

បទចម្រៀងរំដួលក្រចេះគឺជាបទមួយដែលខ្ញុំស្ដាប់ស្ទើរជារៀងរាល់ថ្ងៃ ។ ខេត្តក្រចេះតែងដក់ជាប់នៅក្នុងជំរៅចិត្តរបស់ខ្ញុំជានិច្ច ។ បុគ្គលិកទាំងអស់និងខ្ញុំបាទនៅមជ្ឈមណ្ឌលឯកសារកម្ពុជា សូមសំដែងនូវសេចក្ដីអរគុណជាពន្លឹកដល់លោកនិងខេត្តក្រចេះដែលតែងតែយកចិត្តទុកដាក់ជួយសហការដល់ការស្រាវជ្រាវរបស់យើងខ្ញុំ ។ ខ្ញុំបាទនឹងព្យាយាមឆ្លើយតបទៅគ្រប់សំណើរបស់លោកទៅតាមសមត្ថភាពនិងពេលវេលាដែលអាចធ្វើទៅបាន ។ ទន្ទឹមនឹងនេះដែរផ្នែកមួយនៃទស្សនាវដ្ដីស្វែងរកការពិតគឺទំព័រវេទិកាពិភាក្សាជាសាធារណៈដែលមានតួនាទីប្រហាក់ប្រហែលនឹងលិខិតមិត្តអ្នកអាន ។ នៅក្នុងទំព័រនេះខ្ញុំបាទស្វាគមន៍គ្រប់ការចូលរួមយោបល់ទាំងអស់ពីសំណាក់មិត្តអ្នកអានដោយមិនប្រកាន់និន្នាការនយោបាយ ពណ៌សម្បុរ វណ្ណៈ ភេទ និងអាយុ ។

ខ្ញុំបាទសូមជូនពរលោក និងខេត្តក្រចេះទាំងមូលសូមប្រកបបានតែសេចក្ដីសុខសុភមង្គលជារៀងរហូត ។ សូមទឹកទន្លេមេគង្គដែលហូរប្រោះខេត្តក្រចេះនាំមកនូវការអភិវឌ្ឍន៍ និងការរីកចំរើនថ្មីដល់ខេត្តក្រចេះ ។ ដោយសេចក្ដីគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំនិង បុគ្គលិកទាំងអស់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

**ឆាំង យុ**

ចម្រៀងខ្មែរក្រហម

# អង្គការបដិវត្តន៍ជាដួងព្រលឹងនៃប្រជាជនកម្ពុជាគ្រប់ជនជាតិ

មាគ៌ាបដិវត្តន៍រះចែងចាំង ភ្លឺដូចសូរ្យសែងពីទិសបូព៌ា
ចាំងបោលរស្មីនឹងគន្ធា ជូនដល់ប្រជាជនប្រុសស្រី ។
វាយឈ្នះចក្រពត្តិអាមេរិក ជាមហាអំណាចក្នុងលោកិយ
វាយទាំងបរិវារកញ្ជះដាច់ថ្លៃ ឲ្យវាបរាជ័យអស់ពីកម្ពុជា ។
រំដោះយើងខ្ញុំគ្រប់ជនជាតិ ឲ្យឃ្លាតចាកផុតពីវេទនា
ផុតការជិះជាន់ឆក់ប្លន់មោហោ យើងខ្ញុំធូរធារមានមុខមាត់ថ្មី ។
អង្គការបដិវត្តន៍បានអប់រំ បំប៉ីនបន្ទុំសតិអារម្មណ៍នយោបាយ
ព្រមទាំងចាត់តាំងរឹងប៉ឹងឥតបី អង្គការវិន័យបានឲ្យខ្ពស់ ។
អង្គការដឹកនាំយើងគ្រប់គ្នា បង្កើនផល្ហាបានផុលផុស
លើកទំនប់ជីកប្រឡាយគ្រប់ភូមិទាំងអស់ ដើម្បីធ្វើម្ចាស់លើទឹកដីគ្រប់ផ្នែក ។
កែប្រែជីវភាពប្រជា គ្រប់គ្រាន់ធូរធាររាល់ថ្ងៃប្លែកៗ
ស៊ីចុកស្លៀកពាក់រស់នៅដើរដេក ជីវភាពល្អប្លែកមានសិទ្ធិសេរី ។
អង្គការបដិវត្តន៍ជាដួងព្រលឹង ជាទីពុំនឹងប្រជាជនប្រុសស្រី
កម្មករពលករបានសុខសួស្តី ម្ចាស់ទឹកម្ចាស់ដីម្ចាស់ភ័ព្វវាសនា ។
អង្គការបដិវត្តន៍មានគុណ គុណធ្ងន់មហាធ្ងន់ជាងភ្នំសុមេរា
ធ្ងន់ជាងជីវិតយើងខ្ញុំរាល់គ្នា យើងខ្ញុំប្ដេជ្ញាដើរតាមតៗ ។
យើងខ្ញុំប្ដេជ្ញាកសាងកម្ពុជាថ្មី ប្រជាធិបតេយ្យថ្លៃបវរ
ស្រោងឡើងបញ្ចាង់លើដីអង្គរ សប្បាយសម្បូររុងរឿងអើយ ។

**កត់ត្រាចងក្រងជាឯកសារ**

**សើ សាយ្យាណា**

***ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃ ដល់មន្ទីរស្រុក និងឃុំ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ទស្សនាវដ្ដីចំនួន១០០០ក្បាលជារៀងរាល់លេខ និងដាក់លក់តាមបណ្ដាទីរួមខេត្តនិងក្រុង មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល***

*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number 3, March 2000
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; and the Canada Funds, Canadian Embassy, Phnom Penh, Cambodia